ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៨ លេខ ២ ខែមិថុនា ២០១៤ តម្លៃ ១.៥០០៛

# ចំណងទាក់ទងរវាងរដ្ឋ ជាមួយអ្នកស្រាវជ្រាវកម្ពុជា

## សេចក្តីផ្តើម

កម្ពុជា បានឆ្លងកាត់ការប្រែប្រួលធំៗមួយចំនួន បន្ទាប់ពីអង្គការសហប្រជាជាតិបានរៀបចំការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ ដែលបានត្រួសត្រាយផ្លូវ សម្រាប់ការផ្លាស់ប្តូរជាច្រើននាពេលថ្មីៗនេះ។ កម្ពុជាបានចាកចេញពីស្ថានភាពមានសង្គ្រាម មកពង្រឹងសន្តិភាព, ពីសេដ្ឋកិច្ចបែបសង្គមនិយមតាមផែនការប្រមូលផ្តុំ មកជាសេដ្ឋកិច្ចទីផ្សារសេរី, និងពីរបបឯកបក្ស មកជារបបប្រជាធិបតេយ្យសេរីពហុបក្ស, ប៉ុន្តែគុណភាពនៃការផ្លាស់ប្តូរ ជំរុញដោយកត្តាខាងក្រៅទាំងនេះ នៅតែមាន ការលើកយកមកជជែកវែកញែកនៅឡើយ។ ការផ្លាស់ប្តូរសំខាន់មួយក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅនេះ គឺ កំណើនឯកសារសិក្សាស៊ីជម្រៅ និងការស្រាវជ្រាវស្តីពី ប្រទេសកម្ពុជាដោយអ្នកស្រាវជ្រាវនៅប្រទេសកម្ពុជា។ ប៉ុន្តែការស្រាវជ្រាវដោយអ្នកជំនាញការក្នុងស្រុកនេះ មានបរិមាណតិចតួច បើធៀបនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់។ ម្យ៉ាងទៀត ការរួមចំណែក និងការជះឥទ្ធិពលទៅលើគោលនយោបាយ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងរដ្ឋ នៅមានកម្រិតទាប ហើយសាធារណជនកម្ពុជា ក៏ទទួលបានព័ត៌មានតិចស្តីពីបញ្ហាសង្គម សេដ្ឋកិច្ច និងនយោបាយ។



វេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍ មានការចូលរួមពីអ្នកស្រាវជ្រាវកម្ពុជាជាង ២៥០នាក់ ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវថ្មីៗ ផ្តល់មតិយោបល់ត្រឡប់ និងពិចារណាលើសមិទ្ធផលនានា ព្រមទាំងគិតគូរបង្កើតអនុសាសន៍គោលនយោបាយសម្រាប់អនាគតរបស់ប្រទេសកម្ពុជា។ (ភ្នំពេញ ខែតុលា ឆ្នាំ២០១៤)

ការស្រាវជ្រាវនៅកម្ពុជា អនុវត្តដោយអ្នកស្រាវជ្រាវកម្ពុជាភាគច្រើនអាចរកបាន និងប្រើប្រាស់ ដោយអ្នកស្រាវជ្រាវបរទេស និងប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេស។ ក្នុងនេះ អ្នកស្រាវជ្រាវកម្ពុជា មានឧត្តមភាពច្រើនក្នុងការអនុវត្ត និងបកស្រាយនូវការសិក្សាស្រាវជ្រាវរយៈពេលវែង និងមានភស្តុតាងច្បាស់លាស់នៅក្នុងប្រទេសរបស់ខ្លួន ហើយបានរួមចំណែកយ៉ាងសំខាន់នៅក្នុងមជ្ឈដ្ឋានសិក្សាស្រាវជ្រាវនៅកម្ពុជា ដែលបច្ចុប្បន្នកំពុងតែគ្របដណ្តប់ដោយជនបរទេស។ ប៉ុន្តែអ្នកស្រាវជ្រាវកម្ពុជា ក៏ត្រូវជួបនឹងបញ្ហាប្រឈមជាច្រើន ទាំងក្នុងការអនុវត្តការស្រាវជ្រាវជាក់ស្តែង និងការដោះស្រាយជីវភាពក្នុងលក្ខណៈជាអ្នកស្រាវជ្រាវ។

អត្ថបទនេះ វាយតម្លៃពីស្ថានភាពនៃការស្រាវជ្រាវផ្នែកសង្គម និងឧបសគ្គ ដែលអ្នកស្រាវជ្រាវកម្ពុជាត្រូវប្រឈមមុខ ចាប់តាំងពីចុងបញ្ចប់សម័យខ្មែរក្រហម ដោយពិនិត្យពីចំណងទាក់ទងរវាងកិច្ចការនយោបាយផ្សេងៗ នៃការកសាងរដ្ឋ ហើយនិងទំនាក់ទំនងរវាងអ្នកស្រាវជ្រាវ ទៅនឹងរចនាសម្ព័ន្ធនៃអំណាចសព្វថ្ងៃ។ ការស្រាវជ្រាវពីមុនៗ បានរួមវិភាគទានដ៏មានតម្លៃដល់ការពិភាក្សាអំពី ស្ថានភាពនៃការស្រាវជ្រាវនៅកម្ពុជាក៏ពិតមែន ប៉ុន្តែច្រើនផ្តោតតែទៅលើកត្តាស្ថាប័ន និងវប្បធម៌ ដើម្បីពន្យល់ពី

---

អត្ថបទនេះ រៀបរៀងដោយ បណ្ឌិត អេង នេត្រា ជាអ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួលកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈនៃវិទ្យាស្ថាន CDRI។ គួរយោងឯកសារនេះថា៖ Dr Eng Netra (2014), “Engagement Between the State and Cambodian Researchers”, *Cambodia Development Review,* 18(2):1-5.

## មាតិកា

ចំណងទាក់ទងរវាងរដ្ឋ ជាមួយអ្នកស្រាវជ្រាវ ........................ ១
តើការទទួលបានឱកាសមានលក្ខណៈមិនស្មើភាពគ្នាប៉ុណ្ណានៅកម្ពុជា ? ........................ ៦
ការផ្តោតលើសមាសភាគបីនៃភាពងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុនៅកម្រិតឃុំ និងដែនរងទឹកភ្លៀង ... ១២
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ........................ ១៨
– ស្ថានភាពក្នុងប្រទេស ........................ ២០
ផ្នែកស្រាវជ្រាវ ........................ ២៥
សេចក្តីប្រកាសអំពីការផ្លាស់ប្តូរថ្នាក់ដឹកនាំ វិទ្យាស្ថាន CDRI .. ២៨

ដំណើរការលូតលាស់អន់ខ្សោយ នៃការស្រាវជ្រាវផ្នែកសង្គម។ ទោះយ៉ាងនេះក្តី អ្នកនិពន្ធបានព្យាយាមវែកញែកថា បញ្ហាផ្សេងៗ ដែលអ្នកស្រាវជ្រាវកម្ពុជា និងស្ថាប័នស្រាវជ្រាវនៅកម្ពុជា បាននិងកំពុងជួបប្រទះ វាជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងវិធីសាស្ត្រ និងតម្រូវការ ក្នុងកិច្ចប្រឹងប្រែងកសាងរដ្ឋក្នុងរយៈពេល ៣០ឆ្នាំកន្លងទៅនេះ។ ក្នុងទស្សនៈនេះ ការផ្លាស់ប្តូរ និងទិសដៅទៅថ្ងៃអនាគត នៃការស្រាវជ្រាវផ្នែកសង្គមនៅកម្ពុជា មិនអាចស្វែងយល់បានឡើយ បើសិនគ្រាន់តែពិនិត្យពីបញ្ហាផ្នែកស្ថាប័ន និងបច្ចេកទេស ដោយមិនកំណត់ពីទិដ្ឋភាពផ្នែកនយោបាយ ដែលអ្នកស្រាវជ្រាវកម្ពុជាកំពុងជួបប្រទះនោះ។

## នយោបាយនៃការកសាងរដ្ឋ និងផលប៉ះពាល់ទៅលើអ្នកស្រាវជ្រាវកម្ពុជា

ដើម្បីពិនិត្យពីស្ថានភាពនៃការស្រាវជ្រាវ និងបញ្ហាដែលអ្នកស្រាវជ្រាវកម្ពុជាកំពុងប្រឈមមុខ គេចាំបាច់ត្រូវកំណត់ពីបរិបទ ដែលអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវត្រូវបំពេញតួនាទីរបស់ខ្លួននៅក្នុងដំណើរការកសាងរដ្ឋនៅកម្ពុជា បន្ទាប់ពីសម័យខ្មែរក្រហមបានបញ្ចប់។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាថ្មីមួយដឹកនាំដោយគណបក្សប្រជាជនបដិវត្តកម្ពុជា (ក្រោយមកប្តូរឈ្មោះជា គណបក្សប្រជាជនកម្ពុជា) ត្រូវបានបង្កើតឡើងដោយអាជ្ញាធរវៀតណាម ដែលបានចូលមកក្នុងប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨។ រដ្ឋាភិបាលថ្មីត្រូវប្រឈមមុខនឹងបញ្ហាធំៗសម្បើម ក្នុងការកសាងឡើងវិញនូវប្រទេសមួយ ដែលមានសេដ្ឋកិច្ចបាក់បែកខ្ទេចខ្ទាំ, មានសង្គមមួយដែលពោរពេញដោយការតក់ស្លុត និង អំពើហិង្សា, មានប្រព័ន្ធស្ថាប័នរដ្ឋមួយដែលដាច់ដោចអស់, និងមានការកាត់ផ្តាច់ឲ្យនៅឯកោពីលោកខាងលិច។

ក្នុងទសវត្សរ៍១៩៨០ ថ្នាក់ដឹកនាំកម្ពុជាបានផ្តោតកម្លាំងលើការកសាងប្រព័ន្ធការិយាធិបតេយ្យឡើងវិញ, ការបង្កើតបណ្តាញបក្សតាំងពីថ្នាក់មជ្ឈឹមដល់ថ្នាក់មូលដ្ឋាន, និងការគ្រប់គ្រងលើគ្រោះថ្នាក់ នៃការបះបោរបង្កឡើងដោយកងទ័ពខ្មែរក្រហមដែលនៅសេសសល់ និងក្រុមសម្ព័ន្ធមិត្តដែលធ្វើប្រតិបត្តិការចេញពីទីជម្រកសុវត្ថិភាពក្នុងប្រទេសថៃ (Chandler 1991; Grant 1998)។ ក្នុងអំឡុងពេលនោះ រដ្ឋាភិបាលកម្ពុជាពឹងផ្អែកជាខ្លាំងទៅលើសមភាគីវៀតណាមរបស់ខ្លួន ទាំងសម្រាប់ការជួយមតិ ហិរញ្ញប្បទាន និងកិច្ចការពារផ្សេងៗ ក្នុងកិច្ចការប្រចាំថ្ងៃរបស់រដ្ឋ។ ឯកសារ "បន្ទាប់ពីសម័យខ្មែរក្រហម" (*After the Khmer Rouge*) របស់ Evan Gottesman បានកត់ត្រានូវការយល់ដឹងខ្លះៗពីគោលនយោបាយ និងដំណើរការសម្រេចចិត្តនៅក្នុងរដ្ឋកម្ពុជានាពេលនោះ។ Gottesman បានបញ្ជាក់ថា ដំណើរការកំណត់គោលនយោបាយ មានលក្ខណៈជាការសម្រេចចិត្តធ្វើឡើងពីថ្នាក់លើបញ្ជាទៅថ្នាក់ក្រោម និងពុំមានការពិគ្រោះយោបល់ និងតម្លាភាពទេ ពោលគឺ មនុស្សមួយក្រុមតូចមួយទទួលបានសិទ្ធិអំណាចធំធេង និងដាច់ណាត់ធ្វើការសម្រេចចិត្ត ក្នុងបញ្ហានយោបាយ និងសកម្មភាព (Gottesman 2005:247-253)។ សំខាន់ជាងនេះទៀត ការសម្រេចចិត្ត និងគោលនយោបាយត្រូវបានធ្វើឡើងដើម្បីបម្រើ និងការពារ ផលប្រយោជន៍ថ្នាក់ដឹកនាំនៃរបបនោះ ជាជាងតាមការគិតគូរឲ្យបានស្របច្បាប់ និងសមហេតុសមផល។

ដំណើរការសម្រេចចិត្ត មិនមានលក្ខណៈប្រជាធិបតេយ្យនេះត្រូវបានជំរុញឡើងដោយថ្នាក់ដឹកនាំកំពូលៗរបស់កម្ពុជា ដែលនៅកាន់អំណាចមកទល់បច្ចុប្បន្ន ដោយបញ្ជាក់ហេតុផលថា វាចាំបាច់សម្រាប់ ស្ថានភាពប្រទេសនៅពេលនោះ។ មន្ត្រីនៅកម្រិតអនុវត្ត ជាពិសេសនៅថ្នាក់ក្រោមជាតិ បានទទួលសិទ្ធិអំណាចឲ្យធ្វើ "អ្វីដែលសក្តិសម" សម្រាប់តំបន់របស់ខ្លួន ឲ្យតែមន្ត្រីទាំងនោះ នៅរក្សាចំណងទាក់ទងជិតស្និទ្ធជាបុគ្គលជាមួយមេកើយខ្លួន និងបង្កើតចំណូលដ៏ចាំបាច់ តាមរយៈការរកកម្រៃក្រៅផ្លូវការ ដើម្បីផ្គត់ផ្គង់បណ្តាញរបស់ពួកគេ។ តួយ៉ាង Gottesman (2005:233) បានបង្ហាញថា គោលនយោបាយតាមបែបសង្គមនិយមមួយចំនួនរបស់រដ្ឋាភិបាល ដូចជា គម្រោងក៥[1] ជាដើម នៅទីបញ្ចប់ក៏បង្កើតបាន និងជួយទ្រទ្រង់ដល់ប្រព័ន្ធធំមួយ នៃបណ្តាញខ្សែខ្នងឆ្លងកាត់បណ្តាក្រសួង អាជ្ញាធរមូលដ្ឋាន និងកងទ័ព។ កិច្ចប្រឹងប្រែងជាផ្លូវការនៅពេលនោះ ផ្តោតចម្បងទៅលើ ការបង្កើត និងទាញយកអត្ថប្រយោជន៍ផ្ទាល់ខ្លួនចេញពីគោលនយោបាយ និងសកម្មភាពរបស់រដ្ឋ ដោយធ្វើឲ្យខូចខាតដល់ការកសាង និងការប្រើប្រាស់សមត្ថភាពរដ្ឋក្នុងការសម្រេចចិត្ត និងការអនុវត្តគោលនយោបាយ ដោយផ្អែកលើបទបញ្ញត្តិច្បាប់ ដើម្បីបម្រើផលប្រយោជន៍របស់ប្រជាជនទូទៅ (Ayres 2000; Hughes 2003)។ តាមគំនិតរបស់រដ្ឋាភិបាល ការអនុវត្តបែបនេះមានប្រសិទ្ធភាពល្អព្រោះវាមិនគ្រាន់តែជួយឲ្យរបបនេះរស់រានប៉ុណ្ណោះទេ ហើយថែមទាំងបម្រើផលប្រយោជន៍របស់បក្ស និងថ្នាក់ដឹកនាំបក្សដែលជាសមាជិករដ្ឋាភិបាលផងដែរ។

ស្ថានភាពដូចខាងលើ បានបន្តកើតមានក្នុងទូទាំងទសវត្សរ៍១៩៩០ និងរហូតមកទល់បច្ចុប្បន្ន ទោះបីមានអន្តរាគមន៍ពីអ្នកផ្តល់ជំនួយអន្តរជាតិ ដែលបានចូលមកកម្ពុជាក្រោយពេលបញ្ចប់សង្គ្រាមត្រជាក់ក្នុងឆ្នាំ១៩៨៩ និងពីអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) ដែលបានកាន់អំណាចរួមគ្នាជាមួយរដ្ឋាភិបាលកម្ពុជា ស្របតាមសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ (Hughes 2003; Un 2005)។ នៅដើមទសវត្សរ៍១៩៩០ ទីប្រឹក្សាបច្ចេកទេសអន្តរជាតិ និងធនធានជាច្រើន បានហូរពីបស្ចិមប្រទេសចូលមកកម្ពុជា ក្នុងកិច្ចប្រឹងប្រែងកសាងប្រទេសឡើងវិញ។ ប៉ុន្តែកិច្ចប្រឹងប្រែងទាំងនោះត្រូវរាំងស្ទះជារឿយៗ ដោយសារបញ្ហានយោបាយក្នុងស្រុក។

ការសិក្សាពី "ការកសាងរដ្ឋនៅកម្ពុជា" ដោយ Sok Say ខាងផ្នែកព្រៃឈើ និងការនេសាទ បានរកឃើញថា ទោះបីជាសមត្ថភាពរដ្ឋនៅកម្ពុជា បានរីកចម្រើនយឺតៗតាំងពីឆ្នាំ១៩៩៣មកក្តី ក៏វានៅទន់ខ្សោយនៅឡើយក្នុងផ្នែកជាច្រើន ដោយសារ

[1] គម្រោង ក៥ បានអនុវត្តឡើងពីឆ្នាំ១៩៨៥-៨៩ ក្នុងលក្ខណៈជាកិច្ចប្រឹងប្រែងមួយមានប្រើកម្លាំងពលកម្មយ៉ាងច្រើន នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីការពារព្រំដែនកម្ពុជា-ថៃ តាមរយៈការកសាងលេណដ្ឋាន និងរបងឫស្សី និងការបង្កើតចំការមីន។

"វត្តមានពាសពេញ នូវការទាញយកប្រយោជន៍ពីរដ្ឋ ពីសំណាក់អាជីវករ និងប្រជាពលរដ្ឋជាទូទៅ, ការជ្រៀតជ្រែករបស់អ្នកនយោបាយ ទៅក្នុងការងាររការិយាធិបតេយ្យ និងស្ថាប័នរដ្ឋក្នុងនាម និងដើម្បីបម្រើផលប្រយោជន៍អតិថិជនរបស់ខ្លួន" (Sok 2012: 301)។ ស្រដៀងគ្នានេះដែរ សៀវភៅ "សហគមន៍ត្រូវពឹងពាក់គេ (Dependent Communities)" និពន្ធដោយ Caroline Hughes បង្ហាញពីរបៀបដែលជនមានអំណាចក្នុងស្រុកក្នុងបរិបទនៃប្រទេសទីម័រ និងកម្ពុជា (ដែលទើបបញ្ចប់ទំនាស់ និងត្រូវពឹងពាក់លើជំនួយ) បានខិតខំដោះស្រាយ និងបង្កើតយុទ្ធសាស្ត្រ ដែលហាក់ដូចជាអនុលោមតាមការទាមទាររបស់ម្ចាស់ជំនួយអន្តរជាតិ ខណៈដែលពួកគេនៅតែរក្សាលទ្ធភាពធ្វើសកម្មភាពបានតាមចំណង់ (Hughes 2009)។ Hughes បានបញ្ជាក់ថា ថ្នាក់ដឹកនាំកម្ពុជាសម្រេចបាននូវវត្ថុបំណងនេះ តាមការផ្លាស់ប្តូរសិទ្ធិអំណាចសម្រេចចិត្តពិតប្រាកដ ពីស្ថាប័នរដ្ឋទៅឲ្យបុគ្គលស្មោះត្រង់ និងជាទីទំនុកចិត្តនៅក្នុងបណ្តាញផ្ទាល់របស់គណបក្សប្រជាជនកម្ពុជា (គបជ) ហើយនៅឆ្ងាយពីឥទ្ធិពល និងការចូលរួមរបស់ម្ចាស់ជំនួយអន្តរជាតិ និងសាធារណជនកម្ពុជា។ គោលនយោបាយ និងការសម្រេចចិត្ត ក៏ក្លាយជារបស់អ្នកមានទ្រព្យមានអំណាច និងជាបញ្ហាលាក់កំបាំង។

ជាលទ្ធផល ការធ្វើគោលនយោបាយ និងការចែករំលែកនូវគំនិតគិតគូរ មិនរំពឹងថានឹងកើតចេញមកពីជំនាញការនៅក្នុងវិស័យនេះឡើយ។ ការសម្រេចចិត្ត និងការបង្កើតគោលនយោបាយ គឺធ្វើឡើងទៅតាមបំណង និងចំណង់របស់ថ្នាក់ដឹកនាំនយោបាយកំពូលៗរបស់កម្ពុជា និងនៅក្នុងបណ្តាញខ្សែខ្នងរបស់គណបក្សប្រជាជនកម្ពុជា ជាជាងតាមការជជែកវែកញែកជាសាធារណៈ ពីសំណាក់អ្នកតំណាងក្រុមមនុស្សខុសៗគ្នា, ជំនាញការ និងនិន្នាការនយោបាយផ្សេងៗ។ ទោះបីគណបក្សប្រឆាំងដែលរួបរួមគ្នានោះ ទទួលបានសម្លេងឆ្នោតក្នុងចន្លោះពី ៣៩% ទៅ ៤៥% ក្នុងការបោះឆ្នោតថ្នាក់ជាតិចាប់តាំងពីឆ្នាំ១៩៩៣ មកក្តី ក៏ពួកគេនៅតែមានតួនាទីបន្ទាប់បន្សំប៉ុណ្ណោះ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ។

តាំងពីដើមរៀងមក ការសម្រេចចិត្តនៅកម្ពុជា តែងតែចំណុះឲ្យផលប្រយោជន៍នៃបណ្តាញខ្សែខ្នងរបស់របបគ្រប់គ្រង ដែលមានន័យថា អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ មានឱកាស និងលទ្ធភាពតិចតួច ក្នុងការកំណត់របៀបវារៈសម្រាប់ការកសាងគោលនយោបាយ, ការចូលរួម និងការជះឥទ្ធិពលទៅលើដំណើរការសម្រេចចិត្ត។ រដ្ឋកម្ពុជា និងថ្នាក់ដឹកនាំនៅកម្ពុជា ក៏មិនឲ្យតម្លៃដល់ ការចូលរួមចំណែក និងតួនាទីដែលអ្នកស្រាវជ្រាវក្នុងស្រុកអាចបំពេញបាន នៅក្នុងដំណើរការកសាងរដ្ឋ និងកសាងគោលនយោបាយ។ ប៉ុន្តែក្នុងនេះ គួរកត់សម្គាល់ជាសំខាន់ថា មានករណីលើកលែង និងការប្រែប្រួលខុសគ្នាមួយចំនួន ពីវិស័យគោលនយោបាយមួយទៅវិស័យមួយទៀត ទៅតាមចរិតលក្ខណៈ នៃវិស័យគោលនយោបាយទាំងនោះ និងផលប្រយោជន៍ចាក់ឫសនៅក្នុងនោះ។[២]

## "វប្បធម៌កម្ពុជា" ជាឧបសគ្គរាំងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅកម្ពុជា?

វិធីសាស្ត្របែបមានមេកើយក្នុងការកសាងរដ្ឋនេះ បានជះឥទ្ធិពលខ្លាំងទៅលើទំនាក់ទំនងរវាងរដ្ឋ នឹងអ្នកស្រាវជ្រាវ និងគ្រឹះស្ថានសិក្សានៅកម្ពុជា ព្រមទាំងសមត្ថភាពអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវក្នុងស្រុក ដូចមានពិភាក្សានៅខាងក្រោម។ ឥទ្ធិពលពិតៗនៃវិធីសាស្ត្របែបនេះ មិនទាន់មានការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ នៅក្នុងឯកសារសិក្សាស្រាវជ្រាវមុនៗ ស្តីពីការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅកម្ពុជា។ របាយការណ៍ថ្មីៗមួយរបស់អ្នកស្រាវជ្រាវកម្ពុជា និងបរទេសមួយក្រុមដែលទទួលការងារស្រាវជ្រាវពី សមាគមមជ្ឈមណ្ឌលស្រាវជ្រាវក្នុងស្រុក ហៅថា វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា គឺជាឧទាហរណ៍ដ៏ល្អមួយ។ នៅក្នុងបញ្ហាប្រឈមរបស់ស្ថាប័នស្រាវជ្រាវសាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវនៅកម្ពុជា របាយការណ៍នេះបានលើកពី "កង្វះថវិកា" "កង្វះគ្រឿងសម្រួលការ និងហេដ្ឋារចនាសម្ព័ន្ធ" និង "កង្វះវប្បធម៌ស្រាវជ្រាវ" (Kwok et al. 2010)។ របាយការណ៍បានបញ្ជាក់ម្តងហើយម្តងទៀតថា ឧបសគ្គដែលអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវនៅកម្ពុជា កំពុងប្រឈមមុខគឺ "កង្វះវប្បធម៌ស្រាវជ្រាវ" (Kwok et al.: 29, 34)។ ទស្សនៈដូច្នេះ ក៏ឃើញមាននៅក្នុងការសិក្សាដទៃទៀតដែលវាយតម្លៃពីស្ថានភាពនៃការស្រាវជ្រាវនៅកម្ពុជាដែរ (Pit and Ford 2004; Chet 2009)។ ជារឿយៗ "វប្បធម៌កម្ពុជា" ដែលគេពណ៌នាថាជានិន្នាការពីកំណើតក្នុងការទទួលយកនូវឋានានុក្រម, ការមិនអត់ឱនឲ្យមានអ្វីខុសប្លែកពីគេ, ភាពស្ពឹកស្រពន់ និងកង្វះចរិតចង់ដឹងចង់ឮនោះ គេបានយកមកប្រើប្រាស់ក្នុង ការសិក្សាពីមុនៗ ដើម្បីពន្យល់ពីចំណុចខ្សោយ នៅក្នុងដំណើរការធ្វើប្រជាធិបតេយ្យភាវូបនីយកម្មនៅកម្ពុជា និងការកសាងសង្គមស៊ីវិល និងអភិបាលកិច្ចដោយមានការចូលរួម ជាដើម។

ឧបសគ្គផ្នែកវប្បធម៌នេះ ក៏គេបានអះអាងឡើងដែរ ក្នុងករណីផ្សេងទៀតនៅអាស៊ីអាគ្នេយ៍។ តួយ៉ាង Duncan McCargo បានវែកញែកថា កង្វះការស្រាវជ្រាវ និងការបោះពុម្ពផ្សាយនៅអាស៊ីអាគ្នេយ៍ ដោយអ្នកស្រាវជ្រាវក្នុងតំបន់វាផុសជាសំខាន់ចេញពី "វប្បធម៌សិក្សាស្រាវជ្រាវ" នៅក្នុងតំបន់ ដែលក្នុងនោះ ជំហរវិជ្ជាជីវៈ និងកេរ្តិ៍ឈ្មោះរបស់អ្នកស្រាវជ្រាវ "ជាប់ពាក់ព័ន្ធតិចតួចណាស់ ទៅនឹងការចូលរួមសកម្មក្នុងការស្រាវជ្រាវថ្មីៗ" (McCargo 2006:11)។ អ្នកសិក្សាស្រាវជ្រាវដទៃទៀតមិនឯកភាពតាមនេះទេ ហើយបានជជែកវែកញែកថា ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅក្នុងប្រទេសទាំងនោះ មានជាប់ទាក់ទងដោយផ្ទាល់ ទៅនឹងកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ, ការប្រើប្រាស់អំណាចរដ្ឋ និងគន្លងអភិវឌ្ឍន៍ជាក់លាក់នីមួយៗ (Zeleza 2002; Hadiz and Dhakidae 2005; Goh 2011)។ តួយ៉ាង Hadiz និង Dahkidae បានលើកថា "ភាពក្រខ្សត់" នៃការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គម នៅឥណ្ឌូនេស៊ី បណ្តាលមកពី "លក្ខណៈត្រូវអនុវត្ត

---

[២] Hughes and Conway (2003) បានកត់ត្រាពីដំណើរការសម្រេចចិត្ត និងកសាងគោលនយោបាយនៅកម្ពុជា និងបង្ហាញពីលទ្ធផលខុសៗគ្នានៃដំណើរការទាំងនោះ នៅក្នុងវិស័យគោលនយោបាយផ្សេងៗ រាប់តាំងពីវិស័យផ្តល់សេវាកម្ម រហូតដល់វិស័យត្រូវការធនធានច្រើន។

ជាក់ស្តែងនៃវិទ្យាសាស្ត្រសង្គម ដែលបានក្លាយជាឧបករណ៍សម្រាប់បម្រើរបបការិយាធិបតេយ្យ" និងដែលរដ្ឋនៅតែបន្តអូសទាញមកដើម្បីជំរុញរបៀបវារៈជាក់លាក់នានា (2005:17)។

ដូចនៅកម្ពុជាដែរ "កង្វះធនធាន" "កង្វះជំនួយគាំទ្រផ្នែកស្ថាប័ន" និង "កង្វះហេដ្ឋារចនាសម្ព័ន្ធ" ប្រហែលអាចចាត់ទុកជាបញ្ហាបច្ចេកទេស និងបញ្ហាផ្នែកស្ថាប័នបាន ប៉ុន្តែលទ្ធភាពទទួលបានធនធាន, គ្រឿងសម្រួលការ ហេដ្ឋារចនាសម្ព័ន្ធ ហើយនិងរបៀបរបបផ្នែកស្ថាប័ន ដែលអំណោយផលដល់អាជីព និងសមត្ថភាពស្រាវជ្រាវ គឺសុទ្ធតែជាលទ្ធផលនៃការសម្រេចចិត្តផ្នែកនយោបាយ ថាតើនរណាគួរទទួលបានអ្វី នៅពេលណា និងតាមវិធីណា។ ជាក់ស្តែង ការពង្រឹងសមត្ថភាពផ្នែកលើការស្រាវជ្រាវដ៏សំខាន់នេះ មិនមែនជាអាទិភាពរបស់រដ្ឋាភិបាល និងគណបក្សកាន់អំណាចដែលមានភាពពេញច្បាប់ និងយុទ្ធសាស្ត្រផ្នែកនយោបាយបន្តផ្តោតលើ "សមត្ថភាពរបស់ខ្លួនក្នុងការធ្វើអ្វីៗឲ្យបានសម្រេច" តាមរយៈអភិបាលកិច្ចបែបមេកើយ និងយុទ្ធសាស្ត្របែបប្រជាជននិយម នៃកម្មវិធីអភិវឌ្ឍន៍ជនបទមានប្រយោជន៍ច្រើនខាងនយោបាយរបស់ខ្លួននោះទេ។ ក្នុងបរិបទនេះ ប្រភេទនៃ ការចូលរួមចំណែក និងសមត្ថភាព ដែលរបបនេះចង់បាន គឺការកៀងគរប្រមូលធនធាន និងបញ្ជូនវាទៅបង្ហើយគម្រោង ហេដ្ឋារចនាសម្ព័ន្ធ ដែលឧបត្ថម្ភដោយ គណបក្សប្រជាជនកម្ពុជា ដើម្បីជាថ្នូរនឹងការគាំទ្រផ្នែកនយោបាយ នៅតាមតំបន់ជនបទ។ ជាលទ្ធផល គឺ "អវត្តមានស្ទើរតែទាំងស្រុងនូវមូលនិធិរបស់រដ្ឋាភិបាល និងការឲ្យតម្លៃដល់ការស្រាវជ្រាវនៅកម្ពុជា (Chet 2009:161)។

## ការអូសទាញអ្នកស្រាវជ្រាវកម្ពុជាទៅក្នុងរដ្ឋ

អ្នកស្រាវជ្រាវកម្ពុជា មិនគ្រាន់តែត្រូវគេដាត់ចេញពីកិច្ចការខាងសេដ្ឋកិច្ច និងនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគេអូសទាញបញ្ចូលទៅក្នុងប្រព័ន្ធការិយាធិបតេយ្យរបស់រដ្ឋ និងបណ្តាញផ្ទាល់ខ្លួន របស់គណបក្សប្រជាជនកម្ពុជាទៀតផង។ Gottsman បង្ហាញថា អ្នកមានការអប់រំល្អ និងបញ្ញាវ័ន្តនានាត្រូវបានបង្ខិតបង្ខំ ឲ្យគោរពតាមបន្ទាត់នយោបាយរបស់រដ្ឋ និងគណបក្ស ហើយស្ថិតក្រោមការពិនិត្យតាមដានជាប់រហូតអំពីភក្តីភាពខាងនយោបាយ (Gottesman 2005:348)។ ការអនុវត្តបែបនេះ នៅតែមានជានិច្ច ដរាបណាអំណាចសេដ្ឋកិច្ច និងនយោបាយ បន្តប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃពួកថ្នាក់ដឹកនាំនៅកម្ពុជា និងបណ្តាញដ៏ភក្តីរបស់ពួកគេ នៅតាមលំដាប់ខ្ពស់ៗនៃរចនាសម្ព័ន្ធរបស់បក្ស (Heder 2005; Hughes and Kheang 2011; Pak 2011; Un 2011)។

រដ្ឋាភិបាល បានបង្កើតប្រព័ន្ធដ៏ល្អិតល្អន់ស្មុគស្មាញមួយនៃការផ្តល់កិត្តិយស និងគោរមងារ ហើយប្រើវាដើម្បីផ្តល់រង្វាន់ដល់បុគ្គលនៅក្នុងប្រព័ន្ធការិយាធិបតេយ្យ, យោធា, សង្គមស៊ីវិល, និងវិស័យអាជីវកម្ម ដែលសុខចិត្តគាំទ្រ និងរួមចំណែកជំរុញរបៀបវារៈរបស់រដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា។ តួយ៉ាង ការតែងតាំង និងតម្លើងឋានៈឲ្យសាកលវិទ្យាធិការរដ្ឋ និងបុគ្គលិកថ្នាក់ខ្ពស់ក្នុងស្ថាប័នសិក្សាស្រាវជ្រាវ ជាសេចក្តីសម្រេចរបស់រដ្ឋាភិបាល ហើយវាជាប់ទាក់ទងតិចតួចនឹងលទ្ធផលការងារ ប៉ុន្តែជាប់ទាក់ទងច្រើននឹងទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេ និងការគាំទ្រអំពីមន្ត្រីរដ្ឋាភិបាលមានឋានៈខ្ពស់ (Chet 2009:159)។ ទោះបីសព្វថ្ងៃ មានការជ្រើសរើសយកអ្នកមានការអប់រំ និងបណ្តុះបណ្តាលល្អកាន់តែច្រើននាក់ បញ្ចូលទៅក្នុងប្រព័ន្ធការិយាធិបតេយ្យរបស់រដ្ឋក្តី ក៏អ្នកទាំងនេះមានឥទ្ធិពលតិចតួចទៅលើការបង្កើត និងអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចផ្សេងៗ ពីព្រោះយុទ្ធសាស្ត្រនៃការជ្រើសតាំងនេះ គឺសំដៅធានាឲ្យមានភក្តីភាព និងការគាំទ្រពីក្រុមអ្នកវិជ្ជាជីវៈ និងមានការអប់រំខ្ពស់។ ដោយសារមូលហេតុនេះ ការសិក្សាស្រាវជ្រាវដែលគេគិតថាមានលក្ខណៈរសើបខ្លាំង ឬក៏រដ្ឋមិនអាចទទួលយកបាន កម្រឃើញមានធ្វើ ឬបោះពុម្ពផ្សាយនៅកម្ពុជាណាស់។ ដូច្នេះគេត្រូវសង្កត់ធ្ងន់លើ ការស្រាវជ្រាវទាក់ទងនឹង គោលនយោបាយជាក់ស្តែង អាចអនុវត្តបាន ជាជាងការស្រាវជ្រាវពីបញ្ហាស្នូល និងធ្វើការវិភាគស៊ីជម្រៅ។

***ការស្រាវជ្រាវ មិនមែនដើម្បីបញ្ជាក់ថា អ្នកស្រាវជ្រាវកម្ពុជាទាំងអស់គ្នា សុទ្ធតែត្រូវអាជ្ញាធរអូសទាញបាន ឬក៏នៅកម្ពុជា គ្មានការស្រាវជ្រាវស៊ីជម្រៅណាមួយ បានធ្វើឡើងនោះទេ។ តាមពិត គឺមាន ការស្រាវជ្រាវឯករាជ្យ និងស៊ីជម្រៅ ដែលអ្នកស្រាវជ្រាវកម្ពុជា បានធ្វើឡើងនៅក្រៅ ស្ថាប័នរដ្ឋ និងសាកលវិទ្យាល័យរដ្ឋ។***

## តួនាទី និងឥទ្ធិពលរបស់ម្ចាស់ជំនួយអន្តរជាតិ ទៅលើការស្រាវជ្រាវផ្នែកសង្គមរបស់កម្ពុជា

ការពិភាក្សាដ៏សំខាន់ ពីស្ថានភាពដូចខាងលើនៃការស្រាវជ្រាវ មិនមែនដើម្បីបញ្ជាក់ថា អ្នកស្រាវជ្រាវកម្ពុជាទាំងអស់គ្នា សុទ្ធតែត្រូវអាជ្ញាធរអូសទាញបាន ឬក៏នៅកម្ពុជាគ្មានការស្រាវជ្រាវស៊ីជម្រៅណាមួយ បានធ្វើឡើងនោះទេ។ តាមពិត គឺមានការស្រាវជ្រាវឯករាជ្យ និងស៊ីជម្រៅ ដែលអ្នកស្រាវជ្រាវកម្ពុជា បានធ្វើឡើងនៅក្រៅស្ថាប័នរដ្ឋ និងសាកលវិទ្យាល័យរដ្ឋ។ ការសិក្សាស្រាវជ្រាវនោះ អាចអនុវត្តទៅបានដោយសារជំនួយទ្រទ្រង់ និងធនធាន ពីម្ចាស់ជំនួយអន្តរជាតិ ដែលដើរតួនាទីយ៉ាងសំខាន់ និងមានឥទ្ធិពលខ្លាំង ក្នុងការកំណត់អាទិភាពស្រាវជ្រាវ, ការកសាងសមត្ថភាពស្រាវជ្រាវ, និងការជំរុញឲ្យមានជាអនុសាសន៍គោលនយោបាយ និងការធ្វើសកម្មភាពឆ្លើយតបនឹងលទ្ធផលស្រាវជ្រាវ។

ឧទាហរណ៍លេចធ្លោមួយ គឺ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលបានកកើតឡើង

ក្នុងឆ្នាំ១៩៩០ ក្នុងលក្ខណៈជាអង្គការស្រាវជ្រាវឯករាជ្យពីការអភិវឌ្ឍ ដើម្បីផ្តល់លទ្ធផលស្រាវជ្រាវខាងគោលនយោបាយស្តីពីអាទិភាពនានាសម្រាប់ការអភិវឌ្ឍកម្ពុជា។ អ្នកស្រាវជ្រាវទាំង៣៦រូប នៅ CDRI សុទ្ធតែមានសញ្ជាតិកម្ពុជា ហើយភាគច្រើនបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិត មកពីបរទេស ដែលបង្ហាញពីការផ្លាស់ប្តូរយ៉ាងសំខាន់មួយ ក្នុងសមត្ថភាពស្រាវជ្រាវនៅកម្ពុជា។ អ្នកស្រាវជ្រាវមានការបណ្តុះបណ្តាលខ្ពស់ចំនួនច្រើននាក់ដូច្នេះ ជួយឲ្យ CDRI អាចធ្វើការសិក្សាស្រាវជ្រាវប្រកបដោយគុណភាពក្នុងផ្នែកជាច្រើន តាំងពី សេដ្ឋកិច្ច កសិកម្ម រហូតដល់អភិបាលកិច្ច និងកំណែទម្រង់វិស័យសាធារណៈ។ ក្នុងច្រើនឆ្នាំកន្លងទៅនេះ CDRI បានចេញផ្សាយយ៉ាងទូលំទូលាយនូវឯកសារ ស្តីពី ស្ថានភាពនៃការអភិវឌ្ឍនៅកម្ពុជា និងបានដឹកនាំវេទិកាសាធារណៈជាច្រើននៅកម្ពុជា និងនៅក្នុងតំបន់ ដើម្បីធ្វើការពិភាក្សាជាសាធារណៈ អំពីអនាគតប្រទេសកម្ពុជា។ CDRI ជាវិទ្យាស្ថានឯករាជ្យ ហើយធ្វើការសិក្សាស្រាវជ្រាវដែលអាចមានលទ្ធផលទិតៀនដល់គោលនយោបាយ និងដំណើរការរបស់រដ្ឋាភិបាល ពីព្រោះវិទ្យាស្ថានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាជិកជាជនកម្ពុជាផង និងជនបរទេសផង។ CDRI រក្សាខ្ជាប់នូវឯករាជ្យភាព និងគុណភាពការងាររបស់ខ្លួន ព្រោះជាលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីទទួលបានមូលនិធិពីម្ចាស់ជំនួយអន្តរជាតិ ដែលបច្ចុប្បន្នជាប្រភពចំណូលចម្បង សម្រាប់ប្រតិបត្តិការ និងសកម្មភាពស្រាវជ្រាវរបស់វិទ្យាស្ថាន។

នាពេលថ្មីៗនេះ មានស្ថាប័ន និងមជ្ឈមណ្ឌលស្រាវជ្រាវមួយចំនួនទៀតបានកកើតឡើង ដើម្បីចាប់យកឱកាសល្អនៃកំណើនតម្រូវការការស្រាវជ្រាវ និងការប្រឹក្សាយោបល់ នៅកម្ពុជា។ ជាក់ស្តែង សព្វថ្ងៃមានឯកសារច្រើនណាស់ (ទោះបីជាមានគុណភាពខុសគ្នាខ្លាំងយ៉ាងណាក្តី) ដែលកំពុងផ្សព្វផ្សាយក្នុងវិស័យអាជីវកម្មផ្តល់ការប្រឹក្សាយោបល់នេះ។ ការងារផ្តល់ការប្រឹក្សាយោបល់ដ៏សម្បូរនៅកម្ពុជា ដែលសង្កត់ធ្ងន់លើការស្រាវជ្រាវគោលនយោបាយចំពោះមុខនោះ វាបានប៉ះពាល់គួរឲ្យកត់សំគាល់ទៅលើសមត្ថភាពស្រាវជ្រាវដែលមានតិចតួចស្រាប់ និងការកសាងសមត្ថភាពស្ថាប័ន។ អ្នកស្រាវជ្រាវដែលមានស្នាដៃល្អកំពុងត្រូវស្រូបចូលទៅក្នុងការងារផ្តល់ការប្រឹក្សាយោបល់ ដែលមានប្រាក់កម្រៃខ្ពស់។ ទាំងស្ថាប័នស្រាវជ្រាវរដ្ឋ និងឯកជនក៏ត្រូវគេអូសទាញឲ្យផ្តល់អាទិភាពខ្ពស់ទៅលើ "ការស្រាវជ្រាវផ្តល់ការប្រឹក្សាយោបល់" ហើយកំណត់វាជាសកម្មភាពស្នូលមួយរបស់ខ្លួនដើម្បីអាចរស់រានបាន (Kwok al. 2010)។ បទពិសោធន៍ក្នុងប្រទេសដទៃទៀតបង្ហាញថា នៅពេលសមត្ថភាព និងរបៀបរបបស្រាវជ្រាវដោយម៉ត់ចត់ នៅមិនទាន់កសាងបានរឹងមាំនោះ ការពឹងផ្អែកខ្លាំង និងការសង្កត់ធ្ងន់ ទៅលើការស្រាវជ្រាវផ្តល់ការប្រឹក្សាយោបល់ វាធ្វើឲ្យចុះខ្សោយដល់ គុណភាព និងសមត្ថភាពរបស់សាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវ ដើម្បីធ្វើការស្រាវជ្រាវក្នុងរយៈពេលវែង និងធ្វើការអភិវឌ្ឍសមត្ថភាព (Hadiz and Dhakidae 2005; McCargo 2006)។

## សេចក្តីសន្និដ្ឋាន

អត្ថបទនេះ បង្ហាញពីឧបសគ្គធំៗដែលអ្នកស្រាវជ្រាវកម្ពុជាត្រូវប្រឈមមុខក្នុងការស្រាវជ្រាវនៅកម្ពុជា។ ការផ្លាស់ប្តូរក្នុងនយោបាយ សេដ្ឋកិច្ច និងសង្គម ដែលបានសង្កេតឃើញក្នុងប៉ុន្មានឆ្នាំថ្មីៗ បានបើកច្រកមួយចំនួនសម្រាប់ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងសម្លេងទិតៀននៅពេលដែលអ្នកសិក្សាស្រាវជ្រាវកម្ពុជាទទួលបានការគាំទ្រ និងឱកាស ដើម្បីធ្វើការស្រាវជ្រាវដោយប្រយ័ត្នប្រយែង។ ជំហរដ៏គួរឲ្យសង្ឃឹម ប៉ុន្តែនៅទន់ខ្សោយរបស់អ្នកស្រាវជ្រាវកម្ពុជា ក្នុងការសិក្សាពីកម្ពុជា និងការសិក្សាលើឯកសារអន្តរជាតិ អាចផុសចេញពីឧបសគ្គផ្នែករចនាសម្ព័ន្ធ ដែលអ្នកស្រាវជ្រាវកម្ពុជាត្រូវប្រឈមមុខក្នុងការអនុវត្តការស្រាវជ្រាវជាក់ស្តែង និងការបន្តអាជីពជាអ្នកស្រាវជ្រាវដ៏ម៉ត់ចត់។

ជនកម្ពុជាដែលមកធ្វើការស្រាវជ្រាវនៅកម្ពុជា ហើយចេះភាសាខ្មែរ និងយល់ដឹងច្បាស់ពីទំនៀមទម្លាប់ក្នុងស្រុក តែងមានឧត្តមភាពធំធេងក្នុងការប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗ។ អ្នកស្រាវជ្រាវកម្ពុជា មានលទ្ធភាពច្រើនជាងក្នុងការធ្វើឲ្យអ្នកផ្តល់ព័ត៌មានកើនទំនុកចិត្ត ហើយនិយាយប្រាប់ដោយត្រង់ៗ និងងាយក្តាប់បានជាង ពីអ្វីដែលកំពុងកើតមានជាក់ស្តែង បើធៀបនឹងអ្នកស្រាវជ្រាវបរទេស ដែលត្រូវជួបការលំបាកផ្នែកភាសា និងមានការយល់ដឹងតិចជាង អំពីរបៀបរបបក្នុងស្រុក។ ប៉ុន្តែចំណុចនេះ អាចធ្វើឲ្យអាជ្ញាធរដែលព្យាយាមបិទបាំងសកម្មភាពរបស់ខ្លួននោះ កើតការសង្ស័យលើអ្នកស្រាវជ្រាវ។ ដោយហេតុថាថ្នាក់ដឹកនាំកម្ពុជាបន្តគ្របដណ្តប់លើ និងការពារទំនាក់ទំនងបែបចៅហ្វាយនាយ-កូនចៅរបស់ខ្លួន (តាមរយៈការប្រើប្រាស់បណ្តាញផ្ទាល់ខ្លួន និងបណ្តាញឋានានុក្រម) ក្នុងការកំណត់របៀបវារៈ និងធ្វើសេចក្តីសម្រេចផ្សេងៗ ដូច្នេះហើយហិរញ្ញប្បទានរបស់រដ្ឋាភិបាល សម្រាប់ស្ថាប័នស្រាវជ្រាវមានតិចតួចណាស់ ហើយសម្លេងទិតៀន ក៏កម្រទទួលបានការគាំទ្រដែរ។ ក្នុងស្ថានភាពបែបនេះ ការស្រាវជ្រាវនៅកម្ពុជាទទួលបានហិរញ្ញប្បទានជាសំខាន់ពីជំនួយបរទេស និងអង្គការអន្តរជាតិ ហើយទំនងត្រូវបន្តពឹងផ្អែកលើជំនួយទាំងនេះ ក្នុងរយៈពេលវែងទៅមុខទៀត។

ស្ថានភាពនៃការស្រាវជ្រាវនៅកម្ពុជា មានការផ្លាស់ប្តូរយឺតៗ។ បើធៀបនឹងម្ភៃឆ្នាំមុន ចំនួននិស្សិតកម្ពុជាដែលបញ្ចប់ការសិក្សាថ្នាក់ឧត្តម បានកើនឡើងយ៉ាងទៀងទាត់ ហើយក្នុងនោះ មានច្រើននាក់កំពុងធ្វើការស្រាវជ្រាវខាងផ្នែកសង្គម។ ទោះយ៉ាងណាក្តី ទិសដៅទៅអនាគតនៃការស្រាវជ្រាវផ្នែកសង្គមនៅកម្ពុជា មិនមែនមានត្រឹមតែកំណើនចំនួនអ្នកស្រាវជ្រាវក្នុងស្រុក ដែលមានសញ្ញាប័ត្រអនុបណ្ឌិត និងបណ្ឌិតនោះទេ។ សំខាន់បំផុត គឺត្រូវមានការបង្កើត និងផ្តល់ឲ្យអ្នកស្រាវជ្រាវក្នុងស្រុកនូវ បរិយាកាសសង្គម នយោបាយ និងសេដ្ឋកិច្ចអំណោយផលមួយ ដែលលើកកម្ពស់ការទទួលស្គាល់, ស្វ័យភាព និងការគិតគូរច្នៃប្រឌិតរបស់អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវនៅកម្ពុជា។

តទៅទំព័រ ១១

# តើការទទួលបានឱកាសមានលក្ខណៈមិនស្មើភាពគ្នាប៉ុណ្ណានៅកម្ពុជា?

## សេចក្ដីផ្ដើម

ក្នុងអត្ថបទនេះ អ្នកនិពន្ធវាស់វែងពីវិសមភាពនៃឱកាសទទួលបានសេវាថែទាំសុខភាពជាមូលដ្ឋាន ការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា។ អត្ថបទនេះក៏ព្យាយាមកំណត់ពីកត្តាចម្បងៗ ដែលរួមចំណែកបង្កវិសមភាពនាពេលបច្ចុប្បន្ន។ ការសិក្សាមុនៗពីវិសមភាពនៅកម្ពុជា ច្រើនផ្ដោតតែលើរូបភាពម្ខាង ពោលគឺសមភាពនៃផលសម្រេចបាន។ ពិតណាស់ វិសមភាពនៃឱកាសវាជះឥទ្ធិពលទៅលើផលសម្រេច ដែលប្រជាជនគ្រប់ស្រទាប់មានសិទ្ធិទាមទារ។ ប៉ុន្តែការប្រឹងប្រែងធ្វើការអភិវឌ្ឍ សម្រាប់គ្រប់គ្នា បានជំរុញឲ្យយើងមើលទៅឆ្ងាយជាងការវិភាគតែលើផលសម្រេចបាន ហើយពិនិត្យច្បាស់លាស់ពីសមភាពនៃឱកាសទទួលបានផលសម្រេច។

វិសមភាពក្នុងការទទួលបានសេវាមូលដ្ឋាន និងគ្រឿងសម្រួលការ អាចផុសចេញពីភាពខុសគ្នាក្នុងការខិតខំ ឬការប៉ិនប្រសប់ ឬឱកាសសម្រាប់បុគ្គលម្នាក់ៗ។ វិសមភាពដោយសារភាពខុសគ្នាក្នុងការខិតខំ ឬភាពប៉ិនប្រសប់ វាពិបាកដោះស្រាយណាស់។ អ្នកប៉ិនប្រសប់ខ្លាំង ឬអនុវត្តការងារដោយប្រឹងប្រែងបំផុត តែងសម្រេចបានផល ឬទទួលបានអត្ថប្រយោជន៍ពីសេវាផ្សេងៗ ច្រើនជាងអ្នកប្រឹងប្រែងតិចតួច ឬមិនប៉ិនប្រសប់។ ក្នុងសង្គមភាគច្រើន ប្រជាជនតែងយល់ឃើញថា វិសមភាពបែបនេះអាចទទួលយកបាន ព្រោះវា "យុត្តិធម៌" ហើយដែលអ្នកប្រឹងប្រែងធ្វើការទទួលបានលទ្ធផលល្អជាង។

រីឯឱកាសមិនស្មើភាពគ្នា ក្នុងការទទួលបានសេវាវិញ គេតែងចាត់ទុកជារឿង "អយុត្តិធម៌" ឬមិនអាចទទួលយកបាន នៅក្នុងសង្គម ហើយគួរតែកែតម្រូវវិញ។ ឧបមាថា កុមារម្នាក់កើតក្នុងគ្រួសារក្រីក្រមួយ នៅក្នុងតំបន់មិនសូវមានការអភិវឌ្ឍ ដូច្នេះកុមារនោះ អាចមិនមានលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋាន ព្រោះគ្មានសាលារៀននៅក្បែរនោះ ឬក៏ក្រុមគ្រួសារក្រីក្រពេកមិនអាចឲ្យកុមារទៅរៀនបាន។ ក្នុងរឿងនេះ បញ្ហាចោទមិនមែនជាភាពប៉ិនប្រសប់ ឬការប្រឹងប្រែងឡើយ ប៉ុន្តែជាឱកាសទទួលបានសេវា។ ស្ថានភាពនេះ វាហួសពីសមត្ថភាពគ្រប់គ្រងរបស់កុមារ ដូច្នេះមិនត្រូវក្លាយជាកត្តាកំណត់ថា កុមារត្រូវបានរៀន ឬមិនបានរៀននោះទេ។ គោលដៅផ្នែកគោលនយោបាយចម្បង គឺ ការកាត់បន្ថយវិសមភាពឱកាស ដើម្បីជួយឲ្យប្រជាជនគ្រប់ស្រទាប់ មានលទ្ធភាពស្មើគ្នាក្នុងការទទួលបានសេវាមូលដ្ឋាន ដូចជា ការអប់រំ ការថែទាំសុខភាព និងហេដ្ឋារចនាសម្ព័ន្ធ។

អត្ថបទនេះ ពិពណ៌នាពីវិធីសាស្ត្រសម្រាប់គណនាសន្ទស្សន៍ឱកាសរបស់ប្រជាជន (Human Opportunity Index), បន្ទាប់មកបង្ហាញពីលទ្ធផលជាក់ស្ដែងនៃអង្កេតគ្រួសារ និងការពិភាក្សាលើលទ្ធផលសំខាន់ៗ ហើយនៅខាងចុងមានផ្ដល់ជាសេចក្ដីសន្និដ្ឋាន។

## សន្ទស្សន៍ឱកាសរបស់ប្រជាជន

វិសមភាពក្នុងការទទួលបានការថែទាំសុខភាព ការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន អាចវាស់វែងបានដោយប្រើសន្ទស្សន៍ឱកាសរបស់ប្រជាជន (HOI) ដែលស្នើឡើងដោយ Paes de Barros et al. (2009)។ HOI ជាសន្ទស្សន៍មានសមាសភាគពីរ៖ (i) ដែនគ្របដណ្ដប់ជាមធ្យមនៃសេវា ឬគ្រឿងសម្រួលការផ្សេងៗ (ដូចជា ការថែទាំសុខភាព ឬការអប់រំ) និង (ii) ការចែកចាយនូវលទ្ធភាពទទួលបានសេវា ឬគ្រឿងសម្រួលការក្នុងចំណោមអថេរនានា ដូចជា ក្រុមប្រជាជនបែងចែកតាមប្រាក់ចំណូល ទីតាំងភូមិសាស្ត្រ និងយេនឌ័រ។

ពិន្ទុ HOI កាន់តែខ្ពស់សម្រាប់សេវាណាមួយ បង្ហាញពីគម្លាតឱកាសកាន់តែតូចក្នុងការទទួលបានសេវា ឬគ្រឿងសម្រួលការនោះ។ ដូច្នេះ HOI អាចមានតួលេខកាន់តែខ្ពស់ នៅពេលដែនគ្របដណ្ដប់ជាមធ្យម នៃសេវាឬគ្រឿងសម្រួលការវាកាន់តែធំ និង/ឬ ឱកាសក្នុងការទទួលបានសេវា ឬគ្រឿងសម្រួលការមានការចែកចាយកាន់តែស្មើភាព រវាងក្រុមគ្រួសារខុសៗគ្នា គិតតាមកម្រិតប្រាក់ចំណូល, តាមតំបន់នៅក្នុងប្រទេសណាមួយ, ឬតាមភេទជាបុរសឬស្ត្រី។ ឧទាហរណ៍ HOI សម្រាប់លទ្ធភាពបានប្រើប្រាស់ទឹកស្អាត នៅតាមតំបន់ទីក្រុង និងជនបទនៅប្រទេសកម្ពុជា អាចមានតួលេខកាន់តែខ្ពស់ ប្រសិនបើភាគរយជាមធ្យមនៃប្រជាជន ដែលមានលទ្ធភាពប្រើប្រាស់ទឹកស្អាតមានកម្រិតខ្ពស់ ឬប្រសិនបើការចែកចាយទឹកស្អាតមានលក្ខណៈកាន់តែស្មើភាពគ្នា នៅតាមតំបន់ទីក្រុង និងជនបទនានា។ គេអាចធ្វើការបកស្រាយស្រដៀងគ្នា អំពី HOI សម្រាប់លទ្ធភាពប្រើប្រាស់ទឹកស្អាត ក្នុងចំណោមក្រុមប្រជាជនគិតតាមប្រាក់ចំណូល ឬយេនឌ័រ។

តាមការបកស្រាយខាងលើ HOI សម្រាប់សេវា ឬគ្រឿងសម្រួលការជាក់លាក់ណាមួយ អាចចាត់ទុកបានថាជា វត្តមានសរុបនៃសេវា ឬគ្រឿងសម្រួលការនោះនៅក្នុងប្រទេស ដោយមានការកែតម្រូវសម្រាប់វិសមភាព ក្នុងការចែកចាយលទ្ធភាពប្រើប្រាស់សេវានោះ ទៅតាមក្រុមប្រាក់ចំណូល តាមតំបន់ និងតាមក្រុមយេនឌ័រ។ HOI បានមកពីសមាសភាគពីរ៖ អត្រាគ្របដណ្ដប់ (C) និង វិសមភាពក្នុងការចែកចាយ (D) ។ HOI អាចសរសេរបានថា៖

$$HOI = C(1-D),$$

ដោយ D មានតម្លៃពី ០ ដល់ ១ ធ្វើឲ្យ HOI មានតម្លៃស្មើ ឬតិចជាង C ជានិច្ច។

---

រៀបរៀងដោយ លន់ ពិដេ និង រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវ នៃកម្មវិធីសេដ្ឋកិច្ចពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI។ ឯកសារនេះគួរយោងថា៖ Lun Pide and Roth Vathana (2014), "How Unequal is Access to Opportunities in Cambodia?" *Cambodia Development Review,* 18(2): 6-11។

តារាង ១៖ វិសមភាពនៃឱកាសទទួលបានការអប់រំ

| | អត្រាចូលរៀនសុទ្ធ (%) | | | | | | អត្រាបំពេញការសិក្សាទាន់ពេល (%) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បឋមសិក្សា ១-៦ | | អនុវិទ្យាល័យ ៧-៩ | | វិទ្យាល័យ ១០-១២ | | បឋមសិក្សា ថ្នាក់ទី៦ | | អនុវិទ្យាល័យ ថ្នាក់ទី៩ | | វិទ្យាល័យ ថ្នាក់ទី១២ | |
| | 2009 | 2011 | 2009 | 2011 | 2009 | 2011 | 2009 | 2011 | 2009 | 2011 | 2009 | 2011 |
| ដែនគ្របដណ្ដប់ | 83.6 | 85.4 | 36.6 | 34.8 | 21.4 | 24.9 | 47.4 | 56.4 | 50.0 | 48.8 | 24.1 | 32.3 |
| សន្ទស្សន៍ D | 1.9 | 1.4 | 13.1 | 15.2 | 21.5 | 25.6 | 10.8 | 12.5 | 9.1 | 17.1 | 22.1 | 22.1 |
| HOI | 82.0 | 84.2 | 31.8 | 29.5 | 16.7 | 18.5 | 42.3 | 49.3 | 45.4 | 40.4 | 18.7 | 25.1 |
| ចំនួន | 8264 | 2119 | 4061 | 999 | 4217 | 1083 | 1218 | 339 | 805 | 206 | 467 | 175 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយប្រើទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ច (CSES 2009, 2011)

តម្លៃកាន់តែខ្ពស់នៃ D មានន័យថា ការចែកចាយលទ្ធភាពប្រើប្រាស់សេវា ឬគ្រឿងសម្រួលការ មានលក្ខណៈកាន់តែមិនស្មើភាពឡើង។ គេអាចបង្កើនតម្លៃ HOI ដោយបង្កើនវត្តមានជាទូទៅនៃសេវា ឬគ្រឿងសម្រួលការ ជាក់លាក់ណាមួយ (អត្រាគ្របដណ្ដប់ C) ឬកាត់បន្ថយវិសមភាពក្នុងការចែកចាយលទ្ធភាពទទួលបានសេវា ឬគ្រឿងសម្រួលការនោះ (សន្ទស្សន៍ចែកចាយ D តែងសំដៅលើសន្ទស្សន៍នៃភាពខុសគ្នា) ឬក៏ធ្វើទាំងពីរមុខ។ ប្រសិនបើឱកាសមានស្រាប់ ត្រូវបានចែកចាយស្មើភាពគ្នានោះ D ខិតទៅជិតសូន្យ ហើយ HOI ខិតទៅជិត C ប៉ុន្តែបើការចែកចាយឱកាសមានលក្ខណៈមិនស្មើភាពគ្នាខ្លាំង នោះ D ខិតទៅជិត ១ ហើយ HOI ចុះទាបខ្លាំងជាង C ។

(សម្រាប់ព័ត៌មានលំអិតអំពីការគណនា C, D និង HOI សូមមើលឧបសម្ព័ន្ធ)។

## លទ្ធផលជាក់ស្ដែង និង ការពិភាក្សា

ការសិក្សានេះ តម្រូវឲ្យមានសំណុំទិន្នន័យអង្កេតគ្រួសារពេញលេញមួយ ដើម្បីមានទិន្នន័យគ្រប់គ្រាន់អំពីអថេរដែលបានជ្រើសរើស។ សំណុំទិន្នន័យទាំងនោះ មានជាអាទិ យេនឌ័ររបស់បុគ្គល, អាយុ យេនឌ័រ និងកម្រិតអប់រំរបស់មេគ្រួសារ, តំបន់ស្នាក់នៅ (ទីក្រុង ឬជនបទ), ទំហំគ្រួសារ, និងចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ។ ទិន្នន័យបានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៩ និង ២០១១ ក៏បានយកមកប្រើប្រាស់ដែរ។

### *ការអប់រំ*

អត្រាចូលរៀនសុទ្ធ និង អត្រាបំពេញការសិក្សាទាន់ពេល ជាអថេរពីរ សម្រាប់វាយតម្លៃពីលទ្ធភាពទទួលបានការអប់រំមូលដ្ឋាន។ អត្រាចូលរៀនសុទ្ធ ជាភាគរយនៃកុមារក្នុងក្រុមអាយុដែលតាមការកំណត់ជាផ្លូវការ ត្រូវចូលរៀនថ្នាក់បឋមសិក្សា/មធ្យមសិក្សា ហើយដែលបានទៅចូលរៀននៅសាលាបឋមសិក្សា/មធ្យមសិក្សា។ អត្រាបំពេញការសិក្សាទាន់ពេលជាភាគរយនៃកុមារក្នុងក្រុមអាយុ ដែលចូលរៀននៅថ្នាក់ចុងក្រោយនៃការអប់រំកម្រិតបឋមសិក្សា/មធ្យមសិក្សា។ អ្នកស្រាវជ្រាវបានបែងចែកការអប់រំជាបីកម្រិត - បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។

តារាង១ បង្ហាញថា សម្រាប់ការអប់រំកម្រិតបឋមសិក្សា ឱកាសជាមធ្យមក្នុងការចូលរៀនកើនឡើងបន្តិច ដល់ ៨៥% ក្នុងឆ្នាំ២០១១ ធៀបនឹង ៨៤% ក្នុងឆ្នាំ២០០៩។ សន្ទស្សន៍ D ក៏បានធ្លាក់ចុះដែរ ពីប្រហែល ២% មកត្រឹម ១% នៅក្នុងរយៈពេលដូចគ្នា ដែលបង្ហាញពីការចែកចាយកាន់តែប្រសើរនូវសេវាមានស្រាប់ ដោយគ្មានការរើសអើងទល់នឹងអថេរស្ថានភាពបុគ្គលឡើយ។ កំណើនលទ្ធភាពទទួលបានការអប់រំជាមធ្យម និង ភាពប្រសើរឡើងក្នុងការចែកចាយសេវាអប់រំ ធ្វើឱ្យ HOI ឡើងខ្ពស់ដល់ ៨៤% ក្នុងឆ្នាំ២០១១ ធៀបនឹង ៨២% ក្នុងឆ្នាំ២០០៩។

តារាង ២៖ ការរួមចំណែកនៃអថេរលក្ខខណ្ឌ នៅក្នុងវិសមភាពនៃលទ្ធភាពទទួលបានការអប់រំ (%) – អត្រាចូលរៀនសុទ្ធ

| ប្រភេទអថេរ (%) | បឋមសិក្សា ថ្នាក់ទី១-៦ | | អនុវិទ្យាល័យ ថ្នាក់ទី៧-៩ | | វិទ្យាល័យ ថ្នាក់ទី ១០-១២ | |
|---|---|---|---|---|---|---|
| | 2009 | 2011 | 2009 | 2011 | 2009 | 2011 |
| ភេទរបស់កុមារ | 8.5*** | 35.1*** | 4.6*** | 5.4*** | 0.6*** | 2.4*** |
| ភេទរបស់មេគ្រួសារ | 17.0*** | 3.5*** | 0.5*** | 2.2*** | 0.3*** | 3.0*** |
| តំបន់ស្នាក់នៅ (ទីក្រុង/ជនបទ) | 13.2*** | 46.4*** | 31.9*** | 19.5*** | 65.0*** | 36.9*** |
| ទំហំគ្រួសារ | 1.4 | 1.8*** | 13.9*** | 10.1*** | 8.7*** | 3.0*** |
| ចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ | 21.8*** | 8.6*** | 39.4*** | 31.6*** | 18.8*** | 10.1*** |
| កម្រិតអប់រំរបស់មេគ្រួសារ | 5.2*** | 2.6*** | 5.0*** | 30.3*** | 4.0*** | 42.9*** |
| អាយុមេគ្រួសារ | 32.8*** | 2.0*** | 4.7*** | 0.8*** | 2.6*** | 1.8*** |

កំណត់សំគាល់៖ មេគុណសមីការ Logistic regression មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត ***១%, **៥% and *១០% ។

ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ដោយប្រើ CSES 2009, 2011

តារាង ៣៖ ការរួមចំណែកនៃអថេរលក្ខខណ្ឌ នៅក្នុងវិសមភាពនៃលទ្ធភាពទទួលបានការអប់រំ (%) – ការបំពេញការសិក្សាទាន់ពេល

| ប្រភេទអថេរ (%) | បឋមសិក្សា ថ្នាក់ទី៦ | | អនុវិទ្យាល័យ ថ្នាក់ទី៩ | | វិទ្យាល័យ ថ្នាក់ទី១២ | |
|---|---|---|---|---|---|---|
| | 2009 | 2011 | 2009 | 2011 | 2009 | 2011 |
| ភេទរបស់កុមារ | 21.3*** | 6.9 | 19.8*** | 22.1** | 2.0*** | 18.8* |
| ភេទរបស់មេគ្រួសារ | 1.6*** | 0.8 | 1.1*** | 10.7* | 0.3*** | 19.3*** |
| តំបន់ស្នាក់នៅ (ទីក្រុង/ជនបទ) | 20.4*** | 15.1 | 33.0*** | 18.5** | 49.3*** | 20.9 |
| ទំហំគ្រួសារ | 10.8*** | 3.6 | 5.2*** | 7.0** | 6.1*** | 8.1 |
| ចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ | 16.8*** | 21.6 | 31.4*** | 4.4 | 6.1 | 15.3 |
| កម្រិតអប់រំរបស់មេគ្រួសារ | 18.0*** | 41.9*** | 2.2*** | 30.6*** | 19.3*** | 15.5** |
| អាយុមេគ្រួសារ | 11.2*** | 10.1 | 7.3*** | 6.6 | 17.1*** | 2.1 |

កំណត់សំគាល់៖ មេគុណសមីការ Logistic regression មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត ***១%, **៥% and *១០% ។

ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ដោយប្រើ CSES 2009, 2011

និន្នាការជារួម មានភាពស្រដៀងគ្នាសម្រាប់ការអប់រំនៅអនុវិទ្យាល័យ និងនៅវិទ្យាល័យ ប៉ុន្តែក៏គួរចង្អុលបង្ហាញពីការសង្កេតឃើញមួយចំនួនដែរ។ ទី១ ឱកាសទទួលបានការអប់រំជាមធ្យម មានអត្រាកាន់តែទាបនៅពេលការអប់រំមានកម្រិតកាន់តែខ្ពស់។ លទ្ធភាពទទួលបានការអប់រំកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យជាមធ្យម គឺ ៣៦% និង ២៣% រៀងគ្នា ក្នុងអំឡុងឆ្នាំ២០០៩-១១។ ទី២ សន្ទស្សន៍ D មាននិន្នាការកើនឡើងដែលបង្ហាញថា អាចមានការរើសអើងប្រឆាំងនឹងក្រុមខ្លះៗ ជាពិសេសក្រុមក្រីក្រ។ ទី៣ ការថយចុះនៃអត្រាលទ្ធភាពទទួលបានការអប់រំ និងការកើនឡើងនៃសន្ទស្សន៍ភាពខុសប្លែកគ្នា ធ្វើឱ្យពិន្ទុ HOI ចុះទាប។

សូចនាករអប់រំមួយផ្សេងទៀត គឺ អត្រាបំពេញការសិក្សាទាន់ពេល នៅថ្នាក់ទី៦ ទី៩ និង ទី១២។ លទ្ធផលក្នុងតារាង ១ បង្ហាញថា កុមាររៀននៅថ្នាក់ទី៦ មានស្ថានភាពល្អជាង កុមារនៅថ្នាក់ទី៩ និង ទី១២ ដោយមានអត្រាខ្ពស់ដល់ ៥៦% ក្នុងឆ្នាំ២០១១ ហើយសន្ទស្សន៍ D ក៏មានកម្រិតទាបដែរត្រឹម ១២%។ លទ្ធភាពទទួលបានការអប់រំ និងការចែកចាយលទ្ធភាពទទួលបានការអប់រំ ជាបញ្ហាចោទមួយ សម្រាប់កម្រិតអប់រំខ្ពស់ៗ ជាពិសេសនៅថ្នាក់ទី១២ ដែលមានអត្រាបំពេញការសិក្សាទាន់ពេល ត្រឹម ៣២% និង សន្ទស្សន៍ D ដល់ ២២% នៅឆ្នាំ២០១១។

តារាង ២ និង តារាង ៣ បង្ហាញពីការចូលរួមនៃអថេរនីមួយៗនៅក្នុងវិសមភាពឱកាសសរុប។ សម្រាប់ការអប់រំកម្រិតអនុវិទ្យាល័យក្នុងឆ្នាំ២០១១ តំបន់ប្រជាជនស្នាក់នៅមានចំណែក ១៩% ក្នុងវិសមភាពឱកាសទទួលបានការអប់រំ រីឯចំណាយប្រើប្រាស់ក្នុងមួយគ្រួសារមានចំណែក ៣២% ហើយកម្រិតអប់រំរបស់មេគ្រួសារមានចំណែក ៣០%។ ក្នុងឆ្នាំដដែលនេះ កត្តាទាំងបីខាងលើ នៅតែមានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិតវិទ្យាល័យ បើធៀបនឹងអថេរដទៃទៀត។ កន្លែងកុមារកើតមានចំណែក ៣៧% រីឯចំណាយប្រើប្រាស់របស់គ្រួសារមានចំណែក ១០%។ កម្រិតអប់រំរបស់មេគ្រួសារ ហាក់មានសារៈសំខាន់នៅក្នុងប្រូបាប៊ីលីតេ នៃកុមារទទួលបានការអប់រំនៅវិទ្យាល័យ។ លទ្ធផលទាក់ទងនឹងអត្រាបំពេញការសិក្សាទាន់ពេល ក៏មាននិន្នាការស្រដៀងគ្នាដែរ។

## *សុខភាព*

ក្រុមស្រាវជ្រាវបានជ្រើសយកអថេរបី សម្រាប់វាស់វែងលទ្ធភាពទទួលបានសេវាថែទាំសុខភាពមូលដ្ឋាន គឺមានការទទួលបានថ្នាំបង្ការ ការថែទាំសុខភាពមុនពេលផ្តល់កំណើត និងការសម្រាលកូននៅមន្ទីរពេទ្យសាធារណៈ។ ការទទួលបានថ្នាំបង្ការ (អត្រា) ជាភាគរយនៃកុមារមានអាយុពី ០-២៣ខែ ដែលបានទទួលថ្នាំបង្ការ។ ការថែទាំសុខភាពមុនពេលផ្តល់កំណើតសំដៅលើ ភាគរយនៃស្ត្រីដែលស្វែងរកសេវាថែទាំសុខភាពមាតាក្នុងអំឡុងពេលមានផ្ទៃពោះ ហើយការសម្រាលកូននៅមន្ទីរពេទ្យសាធារណៈជា ភាគរយនៃស្ត្រីដែលសម្រាលកូននៅមណ្ឌលសុខភាពសាធារណៈ។

តារាង ៤៖ វិសមភាពក្នុងឱកាសទទួលបានសេវាថែទាំសុខភាព (%)

| | ការទទួលបានថ្នាំបង្ការ | | ការថែទាំសុខភាព មុនពេលផ្តល់កំណើត | | ការសម្រាលកូននៅមន្ទីរពេទ្យ សាធារណៈ | |
|---|---|---|---|---|---|---|
| | 2009 | 2011 | 2009 | 2011 | 2009 | 2011 |
| ដែនគ្របដណ្តប់ | 94.3 | 98.7 | 85.0 | 92.2 | 41.5 | 69.6 |
| សន្ទស្សន៍ D | 1.2 | 0.4 | 2.9 | 1.1 | 9.8 | 2.1 |
| HOI | 93.2 | 98.2 | 82.4 | 91.1 | 37.6 | 68.1 |
| ចំនួន | 12443 | 16327 | 23437 | 16327 | 23437 | 16327 |

ប្រភព៖ ការគណនារបស់និពន្ធ ដោយប្រើ CSES 2009, 2011

តារាង ៥៖ ការរួមចំណែកនៃអថេរលក្ខខណ្ឌនៅក្នុងវិសមភាពនៃលទ្ធភាពទទួលបានសេវាថែទាំសុខភាព (%)

| ប្រភេទអថេរ (%) | ការទទួលបានថ្នាំបង្ការ | | ការថែទាំសុខភាព មុនពេលផ្ដល់កំណើត | | ការសម្រាលកូននៅ មន្ទីរពេទ្យសាធារណៈ | |
|---|---|---|---|---|---|---|
| | 2009 | 2011 | 2009 | 2011 | 2009 | 2011 |
| ភេទរបស់កុមារ | 4.6*** | 21.7*** | – | – | – | – |
| ភេទរបស់មេគ្រួសារ | 19.6*** | 15.2 | 3.3*** | 12.4*** | 1.7*** | 2.6*** |
| តំបន់ស្នាក់នៅ (ទីក្រុង/ជនបទ) | 44.2*** | 16.0*** | 40.1*** | 22.5*** | 69.5*** | 52.7*** |
| ទំហំគ្រួសារ | 2.5*** | 9.0*** | 1.7*** | 21.9*** | 2.3*** | 1.9*** |
| ចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ | 13.1*** | 11.5*** | 37.1*** | 32.3*** | 10.7*** | 13.5*** |
| កម្រិតអប់រំរបស់មេគ្រួសារ | 3.8*** | 25.2*** | 3.3*** | 7.2*** | 5.5*** | 14.2*** |
| អាយុមេគ្រួសារ | 12.3*** | 1.3*** | 14.6*** | 3.6*** | 10.3*** | 15.0*** |

កំណត់សំគាល់៖ មេគុណសមីការ Logistic regression មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត ***១%, **៥% and *១០% ។

ប្រភព៖ ការគណនារបស់និពន្ធ ដោយប្រើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ ២០០៩, ២០១១

ដែនគ្របដណ្តប់ និងការចែកចាយលទ្ធភាពទទួលបានថ្នាំបង្ការ ការថែទាំសុខភាពមុនពេលផ្តល់កំណើត និងការសម្រាលកូននៅមន្ទីរពេទ្យសាធារណៈ បានល្អប្រសើរឡើងពីឆ្នាំ២០០៩ ដល់ ២០១១ ដែលនាំឲ្យ HOI មានពិន្ទុខ្ពស់ ដូចមានបង្ហាញក្នុងតារាង ៤។ លទ្ធភាពទទួលបានថ្នាំបង្ការ សឹងតែសម្រេចបានជាសកល ដោយមានដែនគ្របដណ្តប់ ៩៩% ក្នុងឆ្នាំ២០១១ និងមានការចែកចាយ សឹងតែស្មើភាពគ្នានៅគ្រប់ទីកន្លែង (សន្ទស្សន៍ -D ស្មើ ១%)។ ស្ត្រីមានផ្ទៃពោះដែលទទួលបានជាទៀងទាត់នូវ សេវាថែទាំសុខភាពមុនពេលផ្តល់កំណើត ក៏មានភាគរយខ្ពស់ដែរ ដល់ ៩២% នៅឆ្នាំ២០១១ ហើយសេវានេះមានការចែកចាយសឹងតែស្មើភាពគ្នានៅគ្រប់ទីកន្លែង។ ទោះយ៉ាងនេះក្តី នៅឆ្នាំ២០០៩ ភាគរយស្ត្រីសម្រាលកូននៅមណ្ឌលសុខភាពសាធារណៈ មានកម្រិតទាបជាងអថេរទាំងពីរខាងលើ ប៉ុន្តែវាមានលក្ខណៈប្រសើរជាងមុន ដោយកើនដល់ ៧០% នៅឆ្នាំ២០១១។

លទ្ធផលតាមប្រភេទអថេរ នាំឲ្យមានការសង្កេតឃើញសំខាន់ៗមួយចំនួន (តារាង ៥)។ សម្រាប់លទ្ធភាពទទួលបានថ្នាំបង្ការ មិនមានអថេរលក្ខខណ្ឌណាមួយ គ្របដណ្តប់លើប្រូបាប៊ីលីតេនៃលទ្ធភាពទទួលបានថ្នាំបង្ការនោះទេ ទោះបីជាអថេរភេទរបស់កុមារ និងកម្រិតអប់រំរបស់មេគ្រួសារហាក់ដូចជាសារៈសំខាន់ផ្នែកស្ថិតិក្នុងឆ្នាំ២០១១ ក្តី។ ស្ថិតិបែបពណ៌នាក៏គាំទ្រដល់លទ្ធផលរកឃើញនេះដែរ ដោយបង្ហាញថា មិនមានការខុសប្លែកគ្នាជាដុំកំភួនទេក្នុង លទ្ធភាពទទួលបានថ្នាំបង្ការក្នុងចំណោមកុមារក្នុងក្រុមបញ្ចភាគចំណាយប្រើប្រាស់ តំបន់ស្នាក់នៅ និងយេនឌ័រ (លទ្ធផលពុំមានបង្ហាញក្នុងអត្ថបទនេះទេ)។

តំបន់ស្នាក់នៅ និងចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ ជាកត្តារួមចំណែកសំខាន់នៅក្នុងប្រូបាប៊ីលីតេរបស់ស្ត្រី ក្នុងការស្វែងរកការថែទាំសុខភាពមាតា ក្នុងអំឡុងពេលមានផ្ទៃពោះ។ ឧទាហរណ៍ដូចជា នៅតំបន់ជនបទ មានតែ ៧៩% នៃស្ត្រីមានផ្ទៃពោះប៉ុណ្ណោះ ដែលស្វែងរកសេវាថែទាំសុខភាពមុនពេលផ្តល់កំណើត ធៀបនឹង ៩៦% នៃស្ត្រីនៅក្នុងរាជធានីភ្នំពេញ និង ៩៤% នៅក្នុងតំបន់ទីក្រុងផ្សេងទៀត (លទ្ធផលពុំមានបង្ហាញទេ)។ តំបន់ស្នាក់នៅ ចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ និងអាយុរបស់មេគ្រួសារ ក៏រួមចំណែកសំខាន់ដែរនៅក្នុងប្រូបាប៊ីលីតេនៃការសម្រាលកូននៅមន្ទីរពេទ្យសាធារណៈ។

## ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន

លទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដូចជា អគ្គិសនី ទឹកស្អាត និងអនាម័យ ដែលសុទ្ធតែជាសេវាមូលដ្ឋានសម្រាប់មនុស្សនោះ គឺជាមូលដ្ឋានគ្រឹះនៃសុខភាព និងសុខុមាលភាព។ លទ្ធភាពប្រើប្រាស់អគ្គិសនី ជាភាគរយគ្រួសារដែលមានលទ្ធភាពទទួលបានការផ្គត់ផ្គង់អគ្គិសនីរបស់រដ្ឋ, លទ្ធភាពទទួលបានទឹកស្អាត ជាភាគរយគ្រួសារមានលទ្ធភាពទទួលបានប្រភពទឹកស្អាតមានសុវត្ថិភាព[១] ហើយលទ្ធភាពទទួលបានសេវាអនាម័យ ជាភាគរយគ្រួសារមានបង្គន់អនាម័យត្រឹមត្រូវ ក្នុងបរិវេណលំនៅដ្ឋានរបស់ខ្លួន។[២]

តារាង ៦ បង្ហាញថា លទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ បានល្អប្រសើរឡើងពីឆ្នាំ២០០៩ ដល់ ២០១១ ដែលអាចមើលឃើញតាមកំណើនអត្រាគ្របដណ្តប់។ ធៀបនឹងលទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត លទ្ធភាពប្រើប្រាស់អគ្គិសនីកើនឡើងជាខ្លាំង ពីប្រមាណ ៣០% ក្នុងឆ្នាំ២០០៩ ដល់ ៤២% ក្នុងឆ្នាំ២០១១ ប៉ុន្តែដែនគ្របដណ្តប់នៅមានកម្រិតទាបណាស់ បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់។ ធ្ងន់ធ្ងរជាងនេះទៀត ទោះមាននិន្នាការប្រសើរឡើងដូច្នេះក្តី ក៏វិសមភាពលទ្ធភាពប្រើប្រាស់អគ្គិសនី នៅមានគម្លាតយ៉ាងខ្លាំង (៣០%) ដែលបណ្តាលឲ្យ HOI មានកម្រិតទាប (២៩%)។ លទ្ធភាពបានប្រើប្រាស់ទឹកស្អាតមានសន្ទស្សន៍ D ស្មើនឹង ១៦% ក្នុងឆ្នាំ២០១១ ដែលបង្ហាញពីការចែកចាយល្អជាង បើធៀបនឹងអថេរពីរផ្សេងទៀត។

[១] រាប់បញ្ចូលទាំងទឹកផ្គត់ផ្គង់តាមបណ្តាញទុយោទៅដល់លំនៅដ្ឋាន ឬបរិវេណផ្ទះ, អណ្តូងខួងសាធារណៈ, អណ្តូងជីកមានការការពារត្រឹមត្រូវ ឬការប្រមូលយកទឹកភ្លៀងមានអនាម័យល្អ។

[២] រាប់បញ្ចូលទាំងបង្គន់អនាម័យ (បង្គន់ចាក់ទឹកតភ្ជាប់ទៅលូទឹកស្អុយ, និងបង្គន់ចាក់ទឹកតភ្ជាប់ទៅអាងស្តុកអនាម័យ), និងបង្គន់បុរាណ (បង្គន់ប្រើធុង ឬរណ្តៅ ដោយមាន ឬគ្មានគម្រប និង បង្គន់នៅពីលើផ្ទៃដីរាបស្មើ ឬផ្ទៃទឹក)។

តារាង ៦៖ វិសមភាពក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន (%)

| | លទ្ធភាពប្រើប្រាស់អគ្គិសនី | | លទ្ធភាពប្រើប្រាស់ទឹកស្អាត | | លទ្ធភាពប្រើប្រាស់ប្រព័ន្ធអនាម័យ | |
|---|---|---|---|---|---|---|
| | 2009 | 2011 | 2009 | 2011 | 2009 | 2011 |
| ដែនគ្រប ដណ្ដប់ | 29.5 | 41.8 | 45.5 | 48.2 | 43.4 | 50.8 |
| សន្ទស្សន៍ D | 45.0 | 30.0 | 15.5 | 16.4 | 26.6 | 23.3 |
| HOI | 16.2 | 29.3 | 38.4 | 40.2 | 31.8 | 38.9 |
| ចំនួន | 11971 | 3592 | 11971 | 3592 | 11971 | 3592 |

ប្រភព៖ ការគណនារបស់និពន្ធ ដោយប្រើ CSES 2009, 2011

ភាពខុសគ្នាតាមតំបន់ ដូចមានបង្ហាញក្នុង តារាង ៧ ជាមូលហេតុចម្បងនៃវិសមភាព ក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ហើយកត្តាចម្បងបន្ទាប់គ្នា គឺ ចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ ដែលតំណាងឲ្យសុខុមាលភាពខាងសេដ្ឋកិច្ច។ ស្ថិតិបែបពណ៌នា ក៏បានបញ្ជាក់ពីលទ្ធផលនេះដែរ។ ឧទាហរណ៍ ក្នុងឆ្នាំ២០១១ គ្រួសារ ៩៨% នៅរាជធានីភ្នំពេញមានលទ្ធភាពប្រើប្រាស់អគ្គិសនី ធៀបនឹង ២៤% នៅតំបន់ជនបទ។ ជាការពិតណាស់ វិសមភាពមានគម្លាតខ្លាំង ដូចអាចមើលឃើញតាមសន្ទស្សន៍ D។

## សេចក្ដីសន្និដ្ឋាន

អត្ថបទនេះ ប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ និង ២០១១ ដើម្បីគណនាសន្ទស្សន៍ឱកាសរបស់មនុស្ស និងផ្ដល់ការប៉ាន់ស្មានពី វិសមភាពនៃការទទួលបានសេវាថែទាំសុខភាព ការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននៅកម្ពុជា។ លទ្ធផលរកឃើញបង្ហាញថា កម្ពុជាអនុវត្តបានល្អនៅក្នុងការអប់រំកម្រិតបឋមសិក្សា ប៉ុន្តែកម្រិតមធ្យមសិក្សានៅយឺតយ៉ាវខ្លាំង។ លទ្ធភាពទទួលបានការអប់រំនៅកម្រិតបឋមសិក្សាជាមធ្យមមានកម្រិតខ្ពស់គួរសម និងមានវិសមភាពកម្រិតទាប។ ផ្ទុយទៅវិញ លទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សាមានកម្រិតទាប ហើយការចែកចាយលទ្ធភាពនេះមានលក្ខណៈមិនស្មើភាពគ្នាជាខ្លាំង។

លទ្ធភាពទទួលបានការថែទាំសុខភាព បានល្អប្រសើរឡើងគួរឲ្យកត់សំគាល់ ហើយការចែកចាយឱកាសទទួលបានសេវានេះក៏បានល្អឡើងដែរ។ ទោះយ៉ាងនេះក្ដី កម្ពុជានៅខ្វះខាតខ្លាំងក្នុងការផ្ដល់លទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដូចជា អគ្គិសនី ទឹកស្អាត និងអនាម័យ។ ទោះបីការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះបានកើនឡើងក្ដី ប៉ុន្តែដែនគ្របដណ្ដប់នៃសេវាទាំងនោះនៅមានកម្រិតទាប បើធៀបនឹងប្រទេសផ្សេងទៀតក្នុងតំបន់។ ធ្ងន់ធ្ងរជាងនេះទៀត វិសមភាពក្នុងការផ្ដល់លទ្ធភាពប្រើប្រាស់វាមានទំហំធំ ដែលបង្ហាញថា ការគ្របដណ្ដប់បានផ្ដោតខ្លាំងទៅលើតែស្រទាប់ខ្លះនៃប្រជាជនប៉ុណ្ណោះ។ ឧបករណ៍ខាងគោលនយោបាយ គួរផ្ដោតលើបញ្ហាដែនគ្របដណ្ដប់ និងការចែកចាយទាំងពីរមុខក៏ពិតមែន ប៉ុន្តែគួរផ្ដល់អាទិភាពទៅលើការដោះស្រាយបញ្ហាគ្របដណ្ដប់ ពីព្រោះវាធំធេងជាងបញ្ហាខាងការចែកចាយ។

ក្រុមស្រាវជ្រាវបានរកឃើញទៀតថា តំបន់ខុសៗគ្នាជាមូលហេតុចម្បងនៃវិសមភាពជាទូទៅ ក្នុងការទទួលបានឱកាស។ តំបន់ទីក្រុងផ្ដល់ឲ្យប្រជាជនខ្លួន នូវការគ្របដណ្ដប់យ៉ាងល្អនៃឱកាសសំខាន់ៗ ប៉ុន្តែតំបន់ជនបទ ឬតំបន់អន់ថយផ្សេងទៀតនៅកម្ពុជា មិនមានលទ្ធភាពធ្វើដូច្នេះឡើយ។ ស្ថានភាពសេដ្ឋកិច្ចគ្រួសារ ក៏រួមចំណែកកំណត់នូវលទ្ធភាពរបស់ប្រជាជនក្នុងការប្រើប្រាស់សេវាមូលដ្ឋានដែរ ពីព្រោះពួកគេត្រូវចំណាយប្រាក់ដើម្បីទទួលបានសេវាទាំងនោះ។ កម្រិតអប់រំរបស់មេគ្រួសារជា

តារាង ៧៖ ការរួមចំណែកនៃអថេរលក្ខខណ្ឌ នៅក្នុង វិសមភាពនៃលទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន (%)

| ប្រភេទអថេរ (%) | លទ្ធភាពប្រើប្រាស់អគ្គិសនី | | លទ្ធភាពប្រើប្រាស់ទឹកស្អាត | | លទ្ធភាពប្រើប្រាស់ប្រព័ន្ធអនាម័យ | |
|---|---|---|---|---|---|---|
| | 2009 | 2011 | 2009 | 2011 | 2009 | 2011 |
| ភេទរបស់មេគ្រួសារ | 1.9 | 1.2 | 4.6** | 4.3*** | 0.9 | 1.6* |
| តំបន់ស្នាក់នៅ (ទីក្រុង/ជនបទ) | 69.6*** | 51.8*** | 63.0*** | 62.9*** | 48.6*** | 35.2*** |
| ទំហំគ្រួសារ | 1.2*** | 1.2*** | 0.8 | 1.8 | 2.8*** | 3.2*** |
| ចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ | 22.0*** | 27.8*** | 23.5*** | 13.4 | 36.8*** | 37.6*** |
| កម្រិតអប់រំរបស់មេគ្រួសារ | 1.6** | 13.1*** | 3.9*** | 15.7*** | 1.7 | 12.2*** |
| អាយុមេគ្រួសារ | 3.7** | 5.0*** | 4.2 | 1.9 | 9.1*** | 10.2*** |

កំណត់សំគាល់៖ មេគុណសមីការ Logistic regression មានសារៈសំខាន់ផ្នែកស្ថិតិនៅកម្រិត ***១%, **៥% and *១០% ។

ប្រភព៖ ការគណនារបស់និពន្ធ ដោយប្រើ CSES 2009, 2011

មូលហេតុមួយទៀត នៃការចែកចាយមិនបានល្អនូវឱកាសទទួលបានការថែទាំសុខភាព និងការអប់រំ។ កត្តាកំណត់ទាំងនេះ អាចកើតមានព្រមៗគ្នា។ ដូច្នេះហើយ គោលនយោបាយសម្រាប់ទប់ស្កាត់ និងកាត់បន្ថយវិសមភាពឱកាសផ្សេងៗ គួរផ្ដោតលើកត្តារួមចំណែកឲ្យបានសព្វគ្រប់ទាំងអស់។ ការដោះស្រាយបញ្ហាសេដ្ឋកិច្ច អាចជួយជំនះលើឧបសគ្គផ្សេងៗទៀតដែលជាប់ទាក់ទងដល់បញ្ហាលទ្ធភាពប្រើប្រាស់សេវា ដូចជា បញ្ហាភាពខុសគ្នាតាមតំបន់ ជាដើម។ ទាំងអស់នេះ សុទ្ធតែជាបញ្ហាដែលអ្នកបង្កើតគោលនយោបាយគួរលើកយកមកពិចារណា។

សូមអានឧបសម្ព័ន្ធនៅក្នុងអត្ថបទជាភាសាអង់គ្លេស។

### ឯកសារយោង


Paes de Barros, Ricardo, Francisco H.G. Ferreira, Jose, R. Molinas Vega and Jaime Saavedra Chanduvi (2009), "Measuring Inequality of Opportunities in Latin America and the Caribbean" (Washington, DC: World Bank)

Fields, S. Gary (2002), "Accounting for Income Inequality and its Change: A New Method, With Application to the Distribution of Earnings in the United States, http://digitalcommons.ilr.cornell.edu/articles/265/ (accessed 23 May 2014)

Hoyos, Alejandro and Ambar Narayan (2011), "Inequality of Opportunities among Children: How Much Does Gender Matter?" Background paper for the World Development Report 2012

Son, Hyun Hwa (2012), *Inequality of Human Opportunities in Developing Asia,* Asian Development Bank Economics Working Paper Series No.328 (Manila: ADB)

Vega, Jose Molinas, Ricardo Paes de Barros, Jaime Saavedra Chanduvi, Marcelo Giugale with Louise J. Cord, Carola Pessino and Amer Hasan (2010), "Do Our Children Have a Chance? The 2010 Human Opportunity Report for Latin America and the Caribbean", Conference Edition (Washington, DC: World Bank)


---

*តពីទំព័រ ៥* **ចំណងទាក់ទងរវាង...**

### ឯកសារយោង


Ayres, D. (2000), "Tradition, Modernity, and the Development of Education in Cambodia", *Comparative Education Review,* 44(4): 440-463

Chandler, D.P. (1991), *The Tragedy of Cambodian History: Politics, War, and Revolution since 1945* (New Haven, CT: Yale University Press)

Chet, C. (2009), "Higher Education in Cambodia", in Y. Hirosato and Y. Kitamura (eds.), *The Political Economy of Educational Reforms and Capacity Development in Southeast Asia* (Springer Science)

Goh, B.L.(ed.) (2011), *Decentring and Diversifying Southeast Asia Studies: Perspectives from the Region* (Singapore: Institute of Southeast Asian Studies)

Gottesman, E. (2005), *Cambodia after the Khmer Rouge: Inside Politics of Nation Building* (Chiang Mai: Silkworm Books)

Grant, C. (1998), *Cambodia Reborn? The Transition to Democracy and Development* (Washington, DC: Brookings Institute)

Hadiz, V.R. and D. Dhakidae (2005), *Social Science and Power in Indonesia* (Singapore: Equinox Publishing)

Heder, S. (2005), "Hun Sen's Consolidation: Death or Beginning of Reform?" *Southeast Asian Affairs:* 113-130

Hughes, C. (2003), *The Political Economy of Cambodia's Transition 1999-2001* (London: Routledge Curzon)

Hughes, C. (2009), *Dependent Communities: Aid and Politics in Cambodia and East Timor* (Ithaca, New York: Cornell University Press)

Hughes, C. and T. Conway (2003),"Understanding Pro-poor Political Change: The Policy Process in Cambodia" (London: Overseas Development Institute)

Hughes, C. and U. Kheang (2011),"*Cambodia's Economic Transformation:* Historical and Theoretical Frameworks", in C. Hughes and U. Kheang (eds.), Cambodia's Economic Transformation (Copenhagen: NIAS Press)

Kwok K., Chan S., Heng C., Kim S., Neth B. and Thon V. (2010), "Scoping Study: Research Capacities of Cambodia's Universities" (Phnom Penh: Cambodia Development Research Forum)

McCargo, D. (2006),"Rethinking Southeast Asian Politics", in C. Chou and V. Houben (eds.), *Southeast Asian Studies: Debates and New Directions* (Singapore: Institute of Southeast Asian Studies)

Pak K. (2011), "A Dominant Party in a Weak State: How the Ruling Party in Cambodia has Managed to Stay Dominant", PhD thesis, Australia National University, Canberra

Pit, C. and D. Ford (2004), "Cambodian Higher Education: Mixed Visions", in P.G. Altbach and T. Umakoshi (eds.), *Asian Universities: Historical Perspectives and Contemporary Challenge* (Baltimore, MA: Johns Hopkins University Press)

Sok S. (2012), "State Building in Cambodia", PhD thesis, Deakin University, Melbourne

Un K. (2005), "Patronage Politics and Hybrid Democracy: Political Change in Cambodia 1993-2003", *Asian Perspective,* 29(2): 203-230

Un K. (2011), "Cambodia: Moving Away from Democracy?" *International Political Science Review,* 32(5): 546-562

Zeleza, P.T. (2002), "The Politics of Historical and Social Science Research in Africa", *Journal of Southern African Studies,* 28(1): 9-23

# ការផ្តោតលើសមាសភាគបីនៃភាពងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុនៅកម្រិតឃុំ និងដែនរងទឹកភ្លៀង

## សាវតា

ប្រទេសកម្ពុជា ទទួលរងការប៉ះទង្គិចជាបន្តបន្ទាប់ពីគ្រោះធម្មជាតិ ដែលមានជាសំខាន់ ការរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ។ កន្លែងរងការប៉ះពាល់ខ្លាំងបំផុត គេតែងគិតថា តំបន់ទន្លេសាប ដែលមានគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ កំពុងកើនហ្រ្វេកង់ និងអាំងតង់ស៊ីតេ ដូចមានបញ្ជាក់ក្នុងលទ្ធផលនៃការស្រាវជ្រាវកាលពីមុនរបស់វិទ្យាស្ថាន CDRI (Chem and Kim 2014)។ ការប៉ះទង្គិចផ្នែកបរិស្ថានទាំងនេះ គេគិតថានឹងជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរ ទៅលើជីវភាពរស់នៅក្នុងតំបន់ ដោយសារការប៉ះពាល់ជាញឹកញាប់ដោយទឹកជំនន់ និងគ្រោះរាំងស្ងួត, កំណើនភាពងាយរងគ្រោះ (តាមការថយចុះសេវាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ និងការប្រែប្រួលទេសភាពក្នុងតំបន់) និងសមត្ថភាពបន្សាំនៅទាប (Chem and Kim 2014) ។

អត្ថបទនេះ ឈរលើសម្មតិកម្មថា ទាំងការប្រែប្រួលអាកាសធាតុ និងសកម្មភាពមនុស្ស បានបង្កការប្រែប្រួលដល់បរិមាណទឹកនៅក្នុងដែនរងទឹកភ្លៀងទន្លេសាប។ ការប្រែប្រួលអាកាសធាតុ ធ្វើឲ្យការធ្លាក់ភ្លៀងមានលំនាំមិនទៀងទាត់ និងសីតុណ្ហភាពឡើងខ្ពស់ជាងមុន។ ប្រពលវប្បកម្មកសិកម្ម ឧស្សាហូបនីយកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងនគរូបនីយកម្ម កំពុងធ្វើឲ្យប្រែប្រួលដល់ដំណើរការផ្នែកជលសាស្ត្រក្នុងដែនរងទឹកភ្លៀង និងប៉ះពាល់ដល់បរិមាណ និងគុណភាពទឹក។ ការប្រែប្រួលក្នុងបរិមាណ គុណភាព និងពេលដែលមានលំហូរទឹក វាបានប៉ះពាល់ដល់កសិករ និងអ្នកប្រើប្រាស់ទឹកដទៃទៀត។ ជាលទ្ធផល គេឃើញមានកង្វះខាតទឹក និងហានិភ័យខ្ពស់ជាងមុននៃការជន់លិច វត្តមានទឹកច្រើនពេក ឬតិចពេក នៅតាមតំបន់សំខាន់ៗ និងតាមពេលវេលាដ៏ចាំបាច់ៗ។ ហេតុនេះ ការយល់ដឹងពីផលពាក់ព័ន្ធនៃការប្រែប្រួលក្នុងលំហូរស្ទឹងអូរ និងបរិមាណទឹក ទៅលើជីវភាពរស់នៅ វាមានសារៈសំខាន់ណាស់។

ការស្វែងយល់ពី ផលប៉ះពាល់ដែលអាចកើតមានពីការប្រែប្រួលផ្នែកជលសាស្ត្រ ទៅលើជីវភាពរស់នៅ និងកម្រិតនៃភាពងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុនៅកម្រិតដែនរងទឹកភ្លៀង និងឃុំ ត្រូវតែគិតគូរទៅលើសមាសធាតុបីនៃភាពងាយរងគ្រោះ ពោលគឺ ភាពត្រូវរងឥទ្ធិពល ភាពឆាប់រងផលប៉ះពាល់ និងសមត្ថភាពបន្សាំ (MRC 2010: 5)។ ការសិក្សានេះ ប្រើប្រាស់វាក្យស័ព្ទទាំងបី ទៅតាមនិយមន័យកំណត់ដោយក្រុមអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ (IPCC 2001) ដូចមានចុះនៅខាងក្រោម។

- *ភាពត្រូវរងឥទ្ធិពល៖* "លក្ខណៈ និងកម្រិតដែលប្រព័ន្ធមួយត្រូវទទួលរងឥទ្ធិពលពីការប្រែប្រួលគួរឲ្យកត់សំគាល់ នៃអាកាសធាតុ" (p. 987)
- *ភាពឆាប់រងផលប៉ះពាល់៖* "កម្រិតដែលប្រព័ន្ធមួយត្រូវបានប៉ះពាល់ជាអវិជ្ជមាន ឬវិជ្ជមាន ពីកត្តាជំរុញទាក់ទងនឹងអាកាសធាតុ។ ការប៉ះពាល់នេះ អាចដោយផ្ទាល់ (ឧទាហរណ៍. ការប្រែប្រួលទិន្នផលស្រូវ ដោយសារការប្រែប្រួលក្នុងគម្លាត និងល្បឿនឡើងចុះសីតុណ្ហភាព និងសីតុណ្ហភាពមធ្យម) ឬដោយប្រយោល (ឧទាហរណ៍. ការខូចខាតបង្កដោយ កំណើនហ្វ្រេកង់នៃទឹកជន់លិចនៅតាមតំបន់ឆ្នេរ ដោយសារកម្ពស់ទឹកសមុទ្រកើនឡើង)"។ (p. 993)
- *សមត្ថភាពបន្សាំ៖* "សមត្ថភាពនៃប្រព័ន្ធមួយក្នុងការសម្របទៅតាមការប្រែប្រួលអាកាសធាតុ (ដែលមានទាំងការប្រែប្រួលអាកាសធាតុជារឿយៗ និងការប្រែប្រួលខ្លាំង) ដើម្បីកាត់បន្ថយការខូចខាត ទាញយកអត្ថប្រយោជន៍ពីឱកាសផ្សេងៗ ឬដើម្បីទប់ទល់នឹងផលវិបាកនានា។" (p. 982)

ការពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន និងថ្នាក់ក្រោមជាតិ គួរផ្តោតលើសមាសធាតុទាំងបីនេះ។ មុនពេលអនុវត្តការវាយតម្លៃលំអិតនៅកម្រិតឃុំ និងគ្រួសារ ត្រូវកំណត់រកឃុំងាយរងគ្រោះបំផុត តាមរយៈការពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិ និងការចូលរួមពីបណ្តាមន្ទីរជំនាញខេត្ត និងអាជ្ញាធរស្រុក។

អត្ថបទនេះ បង្ហាញពីលទ្ធផលនៃការវាយតម្លៃដោយមានការចូលរួមលើកទី១ ក្នុងចំណោមការវាយតម្លៃមួយស៊េរីមានបីលើក ដែលអនុវត្តឡើង ដើម្បីកំណត់រកឃុំងាយរងគ្រោះជាងគេនៅក្នុងដែនរងទឹកភ្លៀងចំនួន ៣ នៅតំបន់បឹងទន្លេសាប គឺ ស្ទឹងជ្រៃបាក់ ក្នុងខេត្តកំពង់ឆ្នាំង, ស្ទឹងពោធិ៍សាត់ ក្នុងខេត្តពោធិ៍សាត់, និងស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ។ ការសិក្សាវាយតម្លៃជាដំបូងនេះ សំដៅស្វែងយល់ឲ្យបានកាន់តែប្រសើរ ពីភាពងាយរងគ្រោះរបស់សហគមន៍ ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឆ្លងតាមការផ្តោតទៅលើភាពត្រូវរងឥទ្ធិពល ភាពឆាប់រងផលប៉ះពាល់ និងសមត្ថភាពបន្សាំ។ គោលដៅមួយទៀត គឺដើម្បីប្រមូលព័ត៌មាន និងទិន្នន័យបន្ទាប់បន្សំស្តីពីគ្រោះធម្មជាតិ ព្រមទាំងការធ្វើផែនការ និងភាពត្រៀមទប់ទល់នឹងគ្រោះអាសន្ននៅកម្រិតមូលដ្ឋាន និងថ្នាក់ក្រោមជាតិ។ ការសិក្សានេះ ក៏សំដៅ

---

រៀបរៀងដោយ គឹម សួ ជាអ្នកស្រាវជ្រាវ និងបណ្ឌិត ចែម ផល្លា ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI ។ ឯកសារនេះគួរយោងថា៖ Kim Sour and Chem Phalla (2014), "A Triple Focus on Climate Change at Catchment and Commune Level", *Cambodia Development Review,* 18(2): 12-17។

ជម្រាបដល់អាជ្ញាធរស្រុក អំពីក្រុមស្រាវជ្រាវ និងសកម្មភាពគម្រោងដែលត្រៀមអនុវត្តនៅតាមស្រុកនីមួយៗ។

ដើម្បីទទួលបានព័ត៌មានជាក់លាក់ ក្រុមស្រាវជ្រាវបានប្រើសំណួរតម្រង់ទិសមួយចំនួន គឺ តើឃុំណាខ្លះងាយរងគ្រោះជាងគេ នៅក្នុងដែនរងទឹកភ្លៀងនីមួយៗដូចខាងលើ? សំណួរបន្តបន្ទាប់ទៀត ផ្ដោតលើប្រេកង់ និងទំហំនៃផលប៉ះពាល់ និងការខូចខាតផ្នែកសង្គម និងសេដ្ឋកិច្ច បង្កឡើងដោយគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ ព្រមទាំងភាពឆាប់រងផលប៉ះពាល់ និងសមត្ថភាពបន្សាំទៅនឹងវិបត្តិទាំងនោះ នៅកម្រិតមូលដ្ឋាន ឬកម្រិតឃុំ។

គួរកត់សំគាល់ថា ក្នុងស្រុកនីមួយៗអាចមានឃុំខ្លះស្ថិតនៅខាងក្រៅដែនរងទឹកភ្លៀង ដូច្នេះមិនបានដាក់បញ្ចូលក្នុងការវាយតម្លៃនេះទេ។

## វិធីសាស្ត្រវាយតម្លៃ

ការវាយតម្លៃនេះ ផ្អែកលើការពិគ្រោះយោបល់ជាមួយស្ថាប័នជំនាញរបស់រដ្ឋនៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និង កំពង់ធំ មានជាអាទិ៍ មន្ទីរធនធានទឹក និងឧតុនិយម, មន្ទីរបរិស្ថាន, មន្ទីរអភិវឌ្ឍន៍ជនបទ, មន្ទីរសាធារណការ និងដឹកជញ្ជូន, និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ យើងក៏បានពិគ្រោះយោបល់ជាមួយខាង ខ័ណ្ឌរដ្ឋបាលជលផល, ខ័ណ្ឌរដ្ឋបាលព្រៃឈើ, គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ, និង អភិបាលស្រុកនៅក្នុងដែនរងទឹកភ្លៀងទាំងបីផងដែរ។

ព័ត៌មាន និងទិន្នន័យបន្ទាប់បន្សំ ជាពិសេសរបាយការណ៍ទាក់ទងនឹងផែនការគ្រប់គ្រង និងកាត់បន្ថយហានិភ័យនៃគ្រោះធម្មជាតិ ដែលទទួលបានពីមន្ទីរជំនាញនីមួយៗ និងអាជ្ញាធរស្រុកក៏បានយកមកពិនិត្យ និងប្រើប្រាស់ក្នុងការវិភាគផងដែរ។

ការពិគ្រោះយោបល់ ផ្ដល់នូវព័ត៌មានសព្វគ្រប់ ស្ដីពី ភាពត្រូវរងឥទ្ធិពល (ពីទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ជំងឺឆ្លងរាលដាល និងការបំផ្លិចបំផ្លាញផលដំណាំដោយហ្វូងសត្វល្អិត) ភាពឆាប់រងផលប៉ះពាល់ និង សមត្ថភាពបន្សាំ។ សំណួរដើម្បីវាយតម្លៃពីភាពត្រូវរងឥទ្ធិពល ផ្ដោតលើឃុំដែលរងការប៉ះពាល់, ប្រភេទគ្រោះមហន្តរាយ, ប្រេកង់, ទំហំនៃផលប៉ះពាល់ (ការបាត់បង់ដីដាំដំណាំ និង/ឬ ការខូចខាតផលដំណាំគិតជាហិកតា ឬ ជាភាគរយ) និង ការខាតបង់ផ្នែកសង្គមនិងសេដ្ឋកិច្ច។ សំណួរដើម្បីកំណត់ពីភាពឆាប់រងផលប៉ះពាល់ ផ្ដោតលើដង់ស៊ីតេប្រជាជន, ការប្រែប្រួលក្នុងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (តំបន់ដីសើម, ដែនជម្រកត្រី, ការប្រែប្រួលគម្របព្រៃឈើជាហិកតា ឬភាគរយ) និងការយល់ឃើញពីផលពាក់ព័ន្ធនៃកំណើនប្រជាជន។ សំណួរដើម្បីវាយតម្លៃពីសមត្ថភាពបន្សាំ ពិនិត្យលើការយល់ដឹងរបស់ប្រជាជនមូលដ្ឋាន ពីការប្រែប្រួលអាកាសធាតុក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

តាមរយៈដំណើរការពិគ្រោះយោបល់ ក្រុមស្រាវជ្រាវក៏បានយល់ដឹងកាន់តែស៊ីជម្រៅពីវត្តមាន និងប្រសិទ្ធភាពនៃសកម្មភាពផ្សព្វផ្សាយព័ត៌មានស្ដីពីការប្រែប្រួលអាកាសធាតុ, ការដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍, ប្រសិទ្ធភាពនៃអង្គការផ្អែកលើសហគមន៍ ដែលធ្វើការងារទាក់ទងនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់និងគ្រប់គ្រងធនធានធម្មជាតិ, ព្រមទាំងសមត្ថភាព និងលទ្ធភាពរបស់បណ្ដាមន្ទីរជំនាញខេត្ត ក្នុងការទ្រទ្រង់ និងជួយដល់សហគមន៍ និងប្រជាជនមូលដ្ឋានដែលរងផលប៉ះពាល់។

ព័ត៌មាន និងទិន្នន័យប្រមូលបានពីការពិគ្រោះយោបល់ បានយកទៅផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ និងផែនការអភិវឌ្ឍន៍ផ្ដល់ដោយអ្នកចូលរួម និង សំណុំទិន្នន័យឃុំ (MOP 2010) ដើម្បីកំណត់រកឃុំដែលងាយរងគ្រោះជាងគេ ដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុនៅក្នុងដែនរងទឹកភ្លៀងទាំងបី។

## លទ្ធផលសិក្សា

### ដែនរងទឹកភ្លៀងស្ទឹងជ្រៃបាក់ នៅខេត្តកំពង់ឆ្នាំង

*ភាពត្រូវរងឥទ្ធិពល៖* ទឹកជំនន់ និងគ្រោះរាំងស្ងួត ជាហានិភ័យចម្បងនៅដែនរងទឹកភ្លៀងស្ទឹងជ្រៃបាក់។ ទឹកជំនន់ធំៗបានកើតមានក្នុងឆ្នាំ២០០២ និង ២០១១ រីឯគ្រោះរាំងស្ងួតកើតមានស្ទើររាល់ឆ្នាំ។ នៅស្រុកទឹកផុស មាន ៣ឃុំ ដែលរងការប៉ះពាល់ពីគ្រោះរាំងស្ងួត ហើយឃុំទាំងអស់រងឥទ្ធិពលពីទឹកជំនន់។ នៅស្រុករលាប្អៀរ មាន ៥ឃុំ ដែលរងការប៉ះពាល់ពីគ្រោះរាំងស្ងួត។ ឃុំក្បាលទឹក ក្នុងស្រុកទឹកផុស និងឃុំគោកបន្ទាយ ក្នុងស្រុករលាប្អៀរ ជាឃុំងាយទទួលរងគ្រោះជាងគេដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត ហើយក៏មានសំណើឲ្យធ្វើការវាយតម្លៃលំអិតលើនោះ។

*ភាពឆាប់រងផលប៉ះពាល់៖* ជារួម ភាពក្រីក្រមានកម្រិតខ្ពស់នៅឡើយក្នុងខេត្តកំពង់ឆ្នាំង។ ប្រជាជនក្នុងខេត្តកំពុងកើនឡើង ដែលនាំឲ្យមានកំណើនយ៉ាងលឿននូវតម្រូវការទឹក និងដីស្រែ រីឯសេវាប្រព័ន្ធអេកូឡូស៊ីកំពុងតែថយចុះ។ គម្របព្រៃឈើមានការថយចុះគួរឲ្យកត់សំគាល់ ពី ២១៣.៩៤២ហិកតា ក្នុងឆ្នាំ២០០២ មកត្រឹម ២១០.៦៨២ហិកតា ក្នុងឆ្នាំ២០១០ (MOP 2010)។ ការថយចុះនេះបណ្ដាលមកពីការកាប់យកឈើ និងការកែប្រែដីដោយប្រជាជនមូលដ្ឋាន និងក្រុមហ៊ុនសម្បទានដី នៅក្នុងព្រៃធម្មជាតិ, ក្នុងឧទ្យានជាតិ និងតំបន់ការពារនានា។ ការកាប់បំផ្លាញព្រៃឈើជាដើមហេតុចម្បងមួយ នៃបញ្ហាកំណើនសំណឹកដី និងទឹកហូរចុះលឿន។

*សមត្ថភាពបន្សាំ៖* ប្រជាជនដែលរស់នៅក្នុងតំបន់ដីខ្ពស់មិនសូវបានចាប់អារម្មណ៍ ពីការប្រែប្រួលអាកាសធាតុនោះទេ។ អ្នករស់នៅតំបន់ទំនាប ដែលតែងទទួលការប៉ះទង្គិចច្រើនជាងគេពីគ្រោះរាំងស្ងួត គាត់យល់ដឹងពីរបៀបគ្រប់គ្រងទឹកសម្រាប់ការដាំស្រូវនៅរដូវប្រាំង។ គេឃើញមានគណៈកម្មាធិការថ្នាក់ក្រោមជាតិមួយសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ (CDM) ដែលមានអភិបាលខេត្តរងមួយរូបជាប្រធាន មានមន្ត្រីមកពីមន្ទីរជំនាញខេត្តជាសមាជិក និងមានសមាជិកស្ម័គ្រចិត្តជាអ្នកតំណាងនៅតាមភូមិ។ CDM មានផែនការត្រៀមខ្លួនទប់ទល់គ្រោះអាសន្នមួយ

ប៉ុន្តែសមត្ថភាពទាប និងធនធានហិរញ្ញវត្ថុមានកម្រិត ធ្វើឲ្យផែនការនេះមិនអាចអនុវត្តបានពេញលេញ ឬលឿនគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងតម្រូវការបន្ទាន់។ អ្នកចូលរួមនានាបានផ្តល់ព័ត៌មានត្រឡប់ថា នៅពេលជួបគ្រោះអាសន្ន បណ្តាស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយត្រូវចែករំលែកថវិកា ហើយជួនកាលត្រូវខ្ចីសម្ភារៈបរិក្ខារ ដូចជា ត្រាក់ទ័រ និងរថយន្តដឹកទំនិញជាដើម ពីម្ចាស់កម្មសិទ្ធិឯកជនទៀតផង។ ទោះបីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត បានធ្វើសកម្មភាពបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ដើម្បីជំរុញការដាំដំណាំធន់នឹងការរាំងស្ងួតក្តី ក៏គេឃើញមានការផ្លាស់ប្តូរតិចតួចណាស់មកទល់សព្វថ្ងៃនេះ។

## ដែនរងទឹកភ្លៀងស្ទឹងពោធិ៍សាត់ ក្នុងខេត្តពោធិ៍សាត់

*ភាពត្រូវរងឥទ្ធិពល៖* ក្នុង ៤ស្រុក ដែលបានជ្រើសរើស គេកំណត់ឃើញថា មាន ១៣ឃុំ ដែលងាយរងគ្រោះជាងគេ ជាពិសេសនៅពេលមានទឹកជំនន់ និងគ្រោះរាំងស្ងួត ក្នុងឆ្នាំ ១៩៩៦, ២០០០, ២០០១, ២០១៣ និង ២០១៤។ ឃុំអន្លង់រាប និង ឃុំប្រមោយ ក្នុងស្រុកវាលវែង, ឃុំសំរោង ក្នុងស្រុកភ្នំក្រវាញ, និង ឃុំស្នាមព្រះ ក្នុងស្រុកបាកាន, ជាឃុំងាយរងគ្រោះបំផុត ហើយមានសំណើឲ្យធ្វើការសិក្សាបន្ថែមទៀត។ ឃុំស្ថិតក្នុងស្រុកបាកាន និង ស្រុកកណ្តៀង តែងរងការប៉ះពាល់ពីជំនន់ទឹកភ្លៀងផង និងជំនន់ទឹកស្ទឹងផង (ចាល់ពីបឹងទន្លេសាប)។ ពួកអ្នកចូលរួមបានរាយការណ៍ផងដែរ ពីខ្យល់ព្យុះ និងការកើតជំងឺឆ្លងរាលដាល។ ក្នុងឆ្នាំ២០០០-០១ ខ្យល់ព្យុះបានបំផ្លាញដីស្រែអស់ប្រហែល ២០០ហិកតា ក្នុងឃុំប្រមោយ ហើយខ្យល់ព្យុះក្នុងឆ្នាំ២០១៤ បានបំផ្លាញផ្ទះ ៩ខ្នង ក្នុងឃុំអន្លង់រាប។

*ភាពឆាប់រងផលប៉ះពាល់៖* មានរបាយការណ៍ពីការបាត់បង់គម្របព្រៃឈើ ដែលបង្កជាសំណឹកដី និងបញ្ហាទឹកហូរចុះលឿន។ ប្រជាជនក្នុងខេត្តពោធិ៍សាត់បានកើនឡើង ជាពិសេសក្នុងស្រុកបាកាន ដែលបានបង្កើនភាពឆាប់រងផលប៉ះពាល់។ កំណើនប្រជាជន នាំឲ្យមានកំណើនតម្រូវការដីស្រែ និងទឹក។ មានរបាយការណ៍ផងដែរ ពីកំណើនទំនាស់ទាក់ទងនឹងតម្រូវការទឹកសម្រាប់ស្រូវប្រាំង នៅក្នុងប្រព័ន្ធស្រោចស្រពស្ទឹងពោធិ៍សាត់ ពិសេសក្នុងស្រុកបាកាន។

*សមត្ថភាពបន្សាំ៖* សហគមន៍នៅក្នុងស្រុកភ្នំក្រវាញ និងស្រុកបាកាន មានការយល់ដឹងច្រើនពីការប្រែប្រួលអាកាសធាតុ និងត្រៀមខ្លួនបានល្អ សម្រាប់ទប់ទល់នឹងគ្រោះធម្មជាតិ។ ពួកគេបានស្នើឲ្យកសាងសំណង់ស្តុកទឹក ដែលគេហៅថា "ពាងយក្ស" ដើម្បីធានាការផ្គត់ផ្គង់ទឹកនៅរដូវប្រាំង។ប្រជាជននៅស្រុកបាកានបានត្រៀមខ្លួនល្អសម្រាប់ទប់ទល់នឹងជំនន់ទឹកស្ទឹងទន្លេ ហើយ

រូបភាព១៖ ស្រុក និងឃុំ ស្ថិតក្នុងដែនរងទឹកភ្លៀងស្ទឹងជ្រៃបាក់




កំណត់សំគាល់៖ ឃុំងាយរងគ្រោះជាងគេគឺ ក្បាលទឹក និងគោកបន្ទាយ

ពួកគេតាមជានព័ត៌មាន ស្តីពីកម្ពស់ទឹកតាមដងទន្លេមេគង្គ៖ បើសិនកម្ពស់ទឹកនៅខេត្តក្រចេះថយចុះ នោះកម្ពស់ទឹកស្ទឹងនៅស្រុកបាកាន នឹងកើនឡើងក្នុងបីថ្ងៃខាងមុខ។

មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ កម្រិតខេត្តមួយ ដែលមានអភិបាលបាលខេត្តរងមួយរូបជាប្រធាន និងមានសមាជិកជាមន្ត្រីមកពីមន្ទីរជំនាញខេត្ត ព្រមទាំងមានសមាជិកស្ម័គ្រចិត្តនៅតាមភូមិ។ គណៈកម្មាធិការនេះ មានឯកសារមួយហៅថា "ផែនការសម្រាប់ការត្រៀមខ្លួន និងការឆ្លើយតបទៅនឹងគ្រោះអាសន្ន" (Khoy 2013)។ នៅខេត្តពោធិ៍សាត់ មាន ២៩ សមាគមកសិករ ដែលទ្រទ្រង់ដោយរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល (NGOs), សហគមន៍នេសាទ, សហគមន៍កសិករប្រើប្រាស់ទឹក, និង ៧សហគមន៍ព្រៃឈើ, ហើយបណ្តាញទំនាក់ទំនងសង្គមដ៏រឹងមាំរបស់ពួកគេសំខាន់ខ្លាំងណាស់ ក្នុងការជួយគ្នាទៅវិញទៅមក។

រូបភាព ២ បង្ហាញពី ស្រុក និងឃុំ ស្ថិតក្នុងដែនរងទឹកភ្លៀងស្ទឹងពោធិ៍សាត់ និងស្ថានភាពនៅជិតបឹងទន្លេសាប នៃស្រុកឃុំទាំងនោះ។ ស្រុក និងឃុំនៅឆ្ងាយៗជាងគេ ពីបឹងទន្លេសាប គឺស្ថិតនៅក្នុងតំបន់ដីខ្ពស់។

### ដែនរងទឹកភ្លៀងស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ

*ភាពត្រូវរងឥទ្ធិពល៖* ប្រមាណជាង ១០ឃុំ ក្នុង ២ស្រុក (បារាយណ៍ និង សន្ទុក) ទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ និង គ្រោះរាំងស្ងួត។ ឃុំទាំងនេះត្រូវរងឥទ្ធិពលពីហានិភ័យទឹកជំនន់បង្កដោយទឹកភ្លៀង, ទឹកស្ទឹង (ដូចជា ស្ទឹងជីនិត), អូរធំតូច, និង ការរីកសាយបឹងទន្លេសាប ដោយសារទឹកទន្លេមេគង្គ។ ទឹកជំនន់ធំៗកើតមានឡើងក្នុងឆ្នាំ២០០០, ២០០៦, ២០០៧, ២០១១ និង ២០១២ ហើយគ្រោះរាំងស្ងួតបានកើតឡើងក្នុងឆ្នាំ២០០៣។ មានខ្យល់ព្យុះធំមួយបានកើតឡើងក្នុងឆ្នាំ២០១២។ ទឹកជំនន់ក្នុងឆ្នាំ២០០៦ បានបំផ្លាញដំណាំស្រូវអស់ ៩ហិកតា និងដំណាំផ្សេងទៀតអស់ ៣០ហិកតា ក្នុងស្រុកបារាយណ៍ ហើយទឹកជំនន់ក្នុងឆ្នាំ២០០០ និង ២០១១ បានបំផ្លាញដីស្រែស្ទើរតែទាំងអស់ក្នុងស្រុកសន្ទុក និងស្រុកបារាយណ៍។ ទឹកជំនន់ឆ្នាំ ២០០៦ និង ២០០៧ ធ្វើឲ្យខូចខាតស្រូវអស់ ១៣៣ហិកតា និងដំណាំផ្សេងទៀតអស់ ៥៦៦ហិកតា។

ឃុំចុងដូង និង ឃុំត្នោតជុំ ក្នុងស្រុកបារាយណ៍, និង ឃុំកោះ ឃុំជ្រាប់ ឃុំតាំងក្រសាំង និងឃុំព្នៅ ក្នុងស្រុកសន្ទុក, ត្រូវបានកំណត់ជាឃុំងាយរងគ្រោះបំផុត និងត្រូវមានការសិក្សាលំអិតបន្ថែម។

រូបភាព ២៖ ស្រុក និងឃុំ នៅក្នុងដែនរងទឹកភ្លៀងស្ទឹងពោធិ៍សាត់




កំណត់សំគាល់៖ ឃុំងាយរងគ្រោះជាងគេគឺ អន្លង់រាប ប្រមោយ សំរោង និងស្នាមព្រះ

*ភាពឆាប់រងផលប៉ះពាល់៖* នៅឆ្នាំ២០១០ មានប្រជាជន ១៩៤.៨១៩នាក់ (នារី ៩៩.៧៣៦នាក់) រស់នៅក្នុងស្រុកបារាយណ៍ និង ៩៧.១៦៤នាក់ (នារី ៤៩.០៩៨នាក់) ក្នុងស្រុកសន្ទុក (MOP 2010)។ ដង់ស៊ីតេប្រជាជនដ៏ខ្ពស់នេះ ពិសេសក្នុងឃុំទ្រាល នាំឲ្យមានភាពឆាប់រងផលប៉ះពាល់ខ្ពស់។ ការកាប់បំផ្លាញព្រៃឈើ កំពុងកើតមានពាសពេញ និងបង្កឡើងដោយប្រជាជនមូលដ្ឋាន និងក្រុមហ៊ុនសម្បទានដី។ ការបាត់បង់គម្របព្រៃយ៉ាងច្រើន នឹងកើតមានឡើងក្នុងប្រាំឆ្នាំខាងមុខ យោងតាមខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពង់ធំ។ នៅស្រុកសន្ទុក (ឃុំបឹងល្វា) មានការកាប់បំផ្លាញព្រៃឈើខ្លាំងជាងគេ និងមានរបាយការណ៍ផងដែរ ពីសកម្មភាពជីករ៉ែនៅតំបន់ខ្សែទឹកខាងលើ ដែលបង្កនូវការបំពុល ហើយប៉ះពាល់រហូតដល់តំបន់ខ្សែទឹកខាងក្រោម ទោះបីខាងស្ថាប័នបច្ចេកទេស មិនទាន់មានសេចក្ដីបញ្ជាក់ពីវត្តមានសារធាតុបំពុលក្ដី។

*សមត្ថភាពបន្សាំ៖* នៅកំពង់ធំក៏មាន CDM មួយស្រដៀងគ្នានឹងខេត្តពីរទៀតដែរ ព្រមទាំងមានផែនការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ និងចម្លើយតបក្នុងគ្រាអាសន្ន។ គេបានចាត់ទុកកាកបាទក្រហមខេត្តកំពង់ធំ ជាស្ថាប័នចម្បងមួយជួយដោះស្រាយបញ្ហាគ្រោះមហន្តរាយ ព្រោះតែងឆ្លើយតបបានលឿនជាងគេ។ កាកបាទក្រហមប្រើប្រាស់វិទ្យុ (102 MHz), ឧបករណ៍បំពងសំឡេង និងទូរស័ព្ទ ដើម្បីផ្សព្វផ្សាយព័ត៌មាន និងប្រកាសភាពអាសន្នដល់ប្រជាជនក្នុងតំបន់។ CDM ប្រើលិខិតផ្លូវការដើម្បីទាក់ទងជាមួយអាជ្ញាធរស្រុក និងឃុំ ប៉ុន្តែក្នុងករណីបន្ទាន់ អាចទូរស័ព្ទទៅអាជ្ញាធរស្រុកដោយផ្ទាល់ និងបន្ទាប់មកទៅក្រុមប្រឹក្សាឃុំទៀត។

អាជ្ញាធរមូលដ្ឋាន បានធ្វើយុទ្ធនាការបង្កើនចំណេះដឹងប្រជាជន អំពីការគ្រប់គ្រងលើហានិភ័យទឹកជំនន់ និងការលើកកម្ពស់អនាម័យ។ អង្គការផ្សេងៗទៀត (ស្រែខ្មែរ, UNICEF, Oxfam និង CAVAC[៩]) ក៏កំពុងជួយប្រជាជនមូលដ្ឋានក្នុងការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ ការប្រើប្រាស់ទឹក និងបញ្ហាអនាម័យដែរ។

ទោះបីមានការបង្កើតយន្តការជាច្រើនក្ដី ក៏អ្នកចូលរួមក្នុងការពិគ្រោះយោបល់បានរាយការណ៍ថា ការងារចុះផ្ទាល់ជាមួយសហគមន៍មិនទាន់បានអនុវត្តទេ ដោយសារកង្វះធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងសម្ភារៈបរិក្ខារ។ សព្វថ្ងៃមិនទាន់មានទីកន្លែងសុវត្ថិភាពត្រឹមត្រូវទេ ហើយនៅពេលជិតមានទឹកជន់ធំ ជាពិសេស

[៩] កម្មវិធីខ្សែចង្វាក់តម្លៃកសិកម្មកម្ពុជា។

រូបភាព ៣៖ ស្រុក និងឃុំ ក្នុងដែនរងទឹកភ្លៀងស្ទឹងជីនិត




កំណត់សំគាល់៖ ឃុំងាយរងគ្រោះជាងគេគឺ ចុងដូង ត្នោតជុំ កកោះ តាំងក្រសាំង និងព្នៅ។

ជំនន់ទឹកទន្លេស្ទឹងនៅរដូវវស្សា ប្រជាជនត្រូវប្រមូលសត្វចិញ្ចឹម និងសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមដងផ្លូវជាតិលេខ៦ ។ នៅតំបន់ស្ទឹងជីនិត មិនមានបញ្ហាខ្វះទឹកទេ ព្រោះមានប្រព័ន្ធស្រោចស្រពដ៏ធំមួយ។ ប៉ុន្តែមានបញ្ហាធំមួយ គឺ ការរាតត្បាតដោយសត្វល្អិតចង្រៃ និងគុណភាពដី ដែលធ្វើឲ្យប្រជាជនពិបាកដាំស្រូវ ឬដំណាំផ្សេងទៀតនៅក្នុងតំបន់ស្រោចស្រព។ ក្នុងករណីនេះ នៅរដូវប្រាំង កសិករត្រូវចុះទៅដល់តំបន់ក្បែរមាត់បឹង ដែលមានដីមានជីជាតិល្អ និងមានការកាប់រានព្រៃលិចទឹកយ៉ាងច្រើន សម្រាប់ធ្វើការដាំដុះនៅរដូវប្រាំង។

រូបភាព ៣ បង្ហាញពីព្រំដែនរដ្ឋបាលនៃស្រុក និងឃុំ នៅក្នុងដែនរងទឹកភ្លៀងស្ទឹងជីនិត និងតំបន់នានា តាំងពីកន្លែងមានដីខ្ពស់បំផុត ទៅដល់កន្លែងដែលមានដីទំនាបបំផុតនៅតាមមាត់បឹងទន្លេសាប។

## សេចក្តីសន្និដ្ឋាន និងសំណូមពរសម្រាប់ការចុះសិក្សាដល់កន្លែងបន្ថែមទៀត

ស្រដៀងគ្នានឹងលទ្ធផលសិក្សាពីមុនៗដែរ ( Chem and Kim 2014 ) អ្នកចូលរួមភាគច្រើនក្នុងការពិគ្រោះយោបល់ បានចាត់ទុកភាពត្រូវរងឥទ្ធិពល ជាសមាសភាគសំខាន់បំផុត នៃភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសទឹកជំនន់ដ៏ធំក្នុងឆ្នាំ២០០០ និង ២០១១ នៅក្នុងដែនរងទឹកភ្លៀងទាំងបី។ ឃុំនៅតំបន់ដីខ្ពស់ ជួបត្រឹមតែជំនន់ទឹកភ្លៀងភ្លាមៗប៉ុណ្ណោះ ប៉ុន្តែឃុំនៅតំបន់ខ្សែទឹកខាងក្រោម ដែលនៅជិតមាត់បឹងទន្លេសាប ត្រូវប៉ះពាល់ដោយជំនន់ទឹកភ្លៀងផង និងជំនន់ទឹកស្ទឹងទន្លេផង។ គ្រោះរាំងស្ងួត កើតមានឡើងស្ទើររៀងរាល់ឆ្នាំនៅក្នុងដែនរងទឹកភ្លៀងទាំងបី។ ក្រៅពីទឹកជំនន់ និងគ្រោះរាំងស្ងួត ក៏មានរបាយការណ៍ពីខ្យល់ព្យុះ រន្ទះបាញ់ និងការឆ្លងរាលដាលជំងឺមនុស្ស និងសត្វចិញ្ចឹមផងដែរ។

ឃុំ ១២ ដែលរួមមាន ២ឃុំ ក្នុងដែនរងទឹកភ្លៀងស្ទឹងជ្រៃបាក់ (ក្បាលទឹក និង គោកបន្ទាយ) ៤ឃុំ ក្នុងដែនរងទឹកភ្លៀងស្ទឹងពោធិ៍សាត់ (អណ្តូងរាប, ប្រមោយ, សំរោង និង ស្នាមព្រះ) និង ៦ឃុំ ក្នុងដែនរងទឹកភ្លៀងស្ទឹងជីនិត (ចុងដូង, ត្នោតជុំ, កាកោះ, ច្រោប, តាំងក្រសាំង និង ភ្នៅ) គឺជាឃុំរងការប៉ះពាល់ធ្ងន់ធ្ងរជាងគេ ហើយត្រូវមានការវាយតម្លៃលំអិតបន្ថែមទៀត។ ប៉ុន្តែការកំណត់ឃើញនេះ ដែលផ្អែកតែលើភាពត្រូវរងឥទ្ធិពល វាហាក់ដូចជាបានរំលងចោលនូវសមាសភាគពីរផ្សេងទៀត នៃភាពងាយរងគ្រោះពោលគឺ ភាពឆាប់រងផលប៉ះពាល់ និង សមត្ថភាពបន្សាំ។

ថ្វីបើប្រជាជនហាក់បានទទួលស្គាល់ជាទូទៅថា សហគមន៍របស់ខ្លួនងាយរងឥទ្ធិពលពីគ្រោះមហន្តរាយក្តី ប៉ុន្តែក្នុងចំណោមអ្នកពាក់ព័ន្ធដែលបានមកចូលរួមនៅកម្រិតនេះ មានតិចនាក់ណាស់ដែលបានយល់ដឹងពីផលពាក់ព័ន្ធ នៃការប្រែប្រួលអាកាសធាតុ ព្រមទាំងពីទំហំ និងប្រភេទនៃការគំរាមកំហែងដល់បរិស្ថាន។ ចំណុចនេះធ្វើឲ្យលំបាកខ្លាំងដល់ការកំណត់ពីការខូចខាតដោយសារគ្រោះមហន្តរាយ និងការកំណត់ស្តង់ដារទិន្នន័យ សម្រាប់ធ្វើការប្រៀបធៀបគ្នានូវភាពឆាប់រងផលប៉ះពាល់របស់ឃុំនីមួយៗ។ ប្រជាជនរស់នៅក្នុងតំបន់ខ្សែទឹកខាងក្រោម ហាក់មានសមត្ថភាពបន្សាំខ្ពស់ជាងអ្នកដែលរស់នៅតំបន់ខ្សែទឹកខាងលើ។

ដូចគ្នាដែរ នៅថ្នាក់ក្រោមជាតិ គេឃើញមានយន្តការជាច្រើន ដូចជា គោលនយោបាយ និងផែនការគ្រប់គ្រងគ្រោះធម្មជាតិ ក្នុងគ្រាអាសន្ន ជាដើម ប៉ុន្តែសម្រាប់ការអនុវត្តជាក់ស្តែងវិញ សព្វថ្ងៃមិនទាន់ឃើញមានសម្ភារៈបរិក្ខាររូបវន្ត, ធនធានមនុស្ស និងហិរញ្ញវត្ថុ និង ការត្រៀមខ្លួនអនុវត្តផែនការកាត់បន្ថយ និងងើបចេញពីគ្រោះមហន្តរាយនៅឡើយទេ។ ខេត្តទាំងបីដែលបានសិក្សា សុទ្ធតែមានគណៈកម្មាធិការថ្នាក់ក្រោមជាតិមួយៗសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ ដោយមានសមាជិកស្ម័គ្រចិត្តនៅតាមភូមិ។ ទោះយ៉ាងនេះក្តី នៅពេលមានគ្រោះមហន្តរាយកើតឡើង សមាជិកស្ថាប័ននេះត្រូវធ្វើការចែករំលែកធនធាន ហើយជួនកាលត្រូវខ្ចីបរិក្ខារពីផ្នែកឯកជនផង ដើម្បីឆ្លើយតបនឹងតម្រូវការបន្ទាន់។

បន្ទាប់ពីការសិក្សា និងការចុះដល់កន្លែងលើកនេះ ក្រុមស្រាវជ្រាវគួរសិក្សាឲ្យបានស៊ីជម្រៅថែមទៀត ពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដោយផ្តោតលើសមាសភាគទាំងបី គឺភាពត្រូវរងឥទ្ធិពល ភាពឆាប់រងផលប៉ះពាល់ និងសមត្ថភាពបន្សាំ។ ដើម្បីជំនះលើការលំបាកផ្សេងៗក្នុងការចែករំលែកគោលគំនិតស្តីពី ភាពឆាប់រងផលប៉ះពាល់ និងសមត្ថភាពបន្សាំ ហើយចេញផុតពី បែបបទដែលប្រជាជនមូលដ្ឋានតែងកំណត់បញ្ហារបស់ខ្លួនពីមុនមកនោះ ក្រុមស្រាវជ្រាវគួរធ្វើសម្ភាស និងការពិភាក្សាតាមក្រុមស្នូលដោយលំអិត ជាមួយប្រជាជនក្នុងឃុំទាំងឡាយ ដែលត្រូវបានកំណត់ថាជាឃុំងាយរងគ្រោះបំផុត ដើម្បីស្វែងយល់បន្ថែមទៀត ពីបញ្ហាប្រឈមដែលប្រជាជនមូលដ្ឋានជួបប្រទះ ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ លទ្ធផលសិក្សានឹងជួយផ្តល់ព័ត៌មានដល់យន្តការផ្សេងៗ សម្រាប់ធ្វើអន្តរាគមន៍ពង្រឹងសមត្ថភាពបន្សាំនៅកម្រិតឃុំ និងដែនរងទឹកភ្លៀង។

## ឯកសារយោង


Chem P. and Kim S. (2014), "Climate Change: Vulnerability, Adaptive Capacity and Water Governance in the Tonle Sap Basin", *Annual Development Review 2013-14* (Phnom Penh: CDRI) pp. 115–128

IPCC, Intergovernmental Panel on Climate Change (2001), *Climate Change 2001: Impacts, Adaptation and Vulnerability,* Contribution of Working Group II to the Third Assessment Report of the Intergovernmental Panel on Climate Change (Cambridge: Cambridge University Press)

Khoy, S. (2013),"Plan for Preparedness for Response to Urgent Disaster", House of Governor and Chief of Provincial Committee for Natural Disaster Management (PCNDM), Pursat Province

MOP, Ministry of Planning (2010), Commune Database, http://db.ncdd.gov.kh/cdbonline/home/index.castle (accessed 10 January 2014)

MRC, Mekong River Commission (2010), *Review of Climate Change Adaptation Methods and Tools,* MRC Technical Paper No. 34 (Vientiane: Mekong River Commission)

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពិពណ៌នាអំពីសូចនាករសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចធំៗនៅលើពិភពលោក និងបណ្តាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

នៅត្រីមាសទី១ ឆ្នាំ២០១៤ សកម្មភាពសេដ្ឋកិច្ចនៅប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងលេចធ្លោឡើង បានបន្តកើនឡើង ទោះបីមានក្តីបារម្ភពីកំណើនមិនស្មើគ្នា ពិសេសនៅប្រទេសមានសេដ្ឋកិច្ចរីកចម្រើនក្តី។

នៅត្រីមាសទី១ កំណើន ផសស ពិត របស់ប្រទេសម៉ាឡេស៊ីកើនដល់ ៦,២% ធៀបនឹង ៤,១% កាលពីឆ្នាំមុន។ សេដ្ឋកិច្ចប្រទេសសិង្ហបុរី រីកលូតលាស់យ៉ាងខ្លាំងដល់ ៥,១% ធៀបនឹង ០,២% កាលពីឆ្នាំមុន។ កំណើន ផសស ពិត របស់ឥណ្ឌូនេស៊ីធ្លាក់ចុះបន្តិចមកត្រឹម ៥,២%។ នៅត្រីមាសទី១ នេះ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅប្រទេសថៃបាន ធ្លាក់ចុះមកត្រឹម ៣,១% ធៀបនឹង ៥,៤% កាលពីឆ្នាំមុន។ ភាពតានតឹងខាងនយោបាយបានបន្តកើនឡើង រហូតឈានដល់ការធ្វើរដ្ឋប្រហារយោធា។ ស្ថានភាពនេះ វាប៉ះពាល់ជាខ្លាំងដល់បរិយាកាស និងទំនុកចិត្តផ្នែកអាជីវកម្ម។ ឥទ្ធិពលរាលដាលចេញពីនោះមួយ គឺរដ្ឋាភិបាលយោធា បានបញ្ជូនពលករចំណាកស្រុកកម្ពុជាដែលមិនស្របច្បាប់រាប់ម៉ឺននាក់មកកម្ពុជាវិញបានធ្វើឲ្យប៉ះពាល់កាន់តែខ្លាំងឡើងដល់សកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសថៃ និងកម្ពុជា ពិសេសការផ្គត់ផ្គង់កម្លាំងពលកម្មគ្មានជំនាញ។

កំណើន ផសស នៅប្រទេសចិន និងប្រទេសផ្សេងទៀតនៅអាស៊ីបូព៌ា ដូចជា ហុងកុង កូរ៉េខាងត្បូង និងកោះតៃវ៉ាន់ នៅតែខ្លាំងក្លា។ នៅត្រីមាសទី១ កំណើន ផសស ពិត របស់ចិន និងហុងកុង ធ្លាក់ចុះបន្តិចមកត្រឹម ៧,១% និង ២,៥% រៀងគ្នា។ កំណើន ផសស នៅកូរ៉េខាងត្បូង កើនដល់ ៤,១% និងនៅតៃវ៉ាន់កើនដល់ ៣,១% ។

កំណើន ផសស របស់ប្រទេសឧស្សាហកម្មបានល្អប្រសើរឡើង ទោះបីជាមានការប្រមើលឃើញថា តំបន់ចាយប្រាក់អឺរ៉ូនៅមានស្ថានភាពមិនទាន់ច្បាស់លាស់ និងងាយរងគ្រោះដោយសារមានបំណុលច្រើន និងតម្រូវការក្នុងស្រុកតិច។ ក្នុងត្រីមាសទី១ ឆ្នាំ២០១៤ ផសស នៅសហរដ្ឋអាមេរិក កើនដល់ ២,៣% ធៀបនឹង ១,៨% កាលពីឆ្នាំមុន។ ការិយាល័យស្ថិតិការងារសហរដ្ឋអាមេរិក បានឲ្យដឹងថា មានការបង្កើតការងារបន្ថែមប្រមាណ ២១៧.០០០កន្លែង ក្នុងខែឧសភា ដែលនាំឲ្យអត្រាគ្មានការងារធ្វើ មានត្រឹម ៦,៣% ដែលជាអត្រាទាបបំផុតគិតចាប់ពីឆ្នាំ២០០៩ មក។ អន្តរាគមន៍ជួយទ្រទ្រង់ផ្នែករូបិយវត្ថុអាចជាមូលហេតុមួយនៃលទ្ធផលសម្រេចបាន ទោះបីមានការវាយស្មានថា ធនាគារកណ្តាលនឹងកាត់បន្ថយការផ្គត់ផ្គង់រូបិយវត្ថុដើម្បីគ្រប់គ្រងលើអតិផរណា បង្កឡើងដោយកំណើនរូបិយវត្ថុ។ នៅត្រីមាសទី១ ផសស របស់ជប៉ុន កើនយ៉ាងខ្លាំងដល់ ៣,១% ធៀបជាមួយនឹង ០,៤% កាលពីឆ្នាំមុន។ យុទ្ធសាស្ត្របីមុខព្រួញ "Abenonomics" អាចផ្តល់ផលល្អ ប៉ុន្តែវាមិនមែនជាឱសថទិព្វនោះទេ។ សមាសភាគមួយនៃអន្តរាគមន៍នេះ គឺដើម្បីបំបាត់បរិត្តផរណាជាច្រើនទសវត្សរ៍កន្លងមកនេះ ដែលបានបង្កើនប្រាក់សន្សំរបស់ឯកជន និងសហគ្រាស និងពន្យឺតកំណើនតម្រូវការក្នុងស្រុក។ IMF បានព្យាករណ៍ថា ជប៉ុននឹងមានកំណើន ផសស កម្រិតមធ្យម ក្នុងឆ្នាំ២០១៤-១៥ ។

## អតិផរណាពិភពលោក និងអត្រាប្តូរប្រាក់

អត្រាអតិផរណាក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន រីឯក្នុងប្រទេសជឿនលឿនមួយចំនួន វាមានកម្រិតទាបជាងការរំពឹងទុក។ អតិផរណានៅកម្ពុជា កើនដល់ ៤,៥% ធៀបនឹង ១,៥% កាលពីឆ្នាំមុន ហើយនៅឥណ្ឌូនេស៊ី កើនដល់ ៧,៧% ធៀបនឹង ៥,៣% កាលពីឆ្នាំមុន។ ជប៉ុនបានគេចផុតពីបរិត្តផរណា ក្នុងបីត្រីមាសចុងក្រោយនេះ។ គេសង្ឃឹមថា គោលនយោបាយក្តៅគគុកបង្កើនរូបិយវត្ថុ និងសារពើពន្ធរបស់លោកនាយករដ្ឋមន្ត្រី អាបេ អាចបំបាត់បរិត្តផរណាបាន។ អត្រាអតិផរណា ក៏មានកម្រិតទាបដែរនៅប្រទេសចិន និងប្រទេសខ្លាអាស៊ីនានា។ អតិផរណានៅក្នុងតំបន់ចាយប្រាក់អឺរ៉ូ និងសហរដ្ឋអាមេរិក បន្តមានកម្រិតទាបដែលបង្ហាញថា គោលនយោបាយបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ (Quantitative Easing II) មិនមានឥទ្ធិពលអ្វីខ្លាំងទៅលើកម្រិតថ្លៃជារួមទេ ហើយការកាត់បន្ថយបរិមាណរូបិយវត្ថុ ក៏មិនទាន់គួរចាប់ផ្តើមដែរ។

នៅត្រីមាសទី១ ឆ្នាំ២០១៤ ប្រាក់រៀល ឡើងថ្លៃ ០,៦% ធៀបនឹងត្រីមាសមុន និង ០,០៣% ធៀបនឹងមួយឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ ដល់ ៣៩៩៣,៨រៀល/ដុល្លារអាមេរិក។ ប្រាក់បាតថៃធ្លាក់ថ្លៃ ២,៨% ធៀបនឹងត្រីមាសមុន (៩,៥% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ។ ប្រាក់ដុងវៀតណាមនៅថេរ ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ថ្លៃ ០,១% ធៀបនឹងមួយឆ្នាំមុន។ ប្រាក់យ៉ន់ចិន ឡើងថ្លៃ ២,០% រីឯប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ១១,៣% ធៀបនឹងមួយឆ្នាំមុន។

## ថ្លៃទំនិញក្នុងទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១៤ ពោតឡើងថ្លៃ ៥,២% ធៀបនឹងត្រីមាសមុន ដល់ ២០៩,៦ដុល្លារ/តោន ប៉ុន្តែធ្លាក់ថ្លៃ ៣១,៣% ធៀបនឹងឆ្នាំមុន។ កៅស៊ូធ្លាក់ថ្លៃ ១៤,៥% ធៀបនឹងត្រីមាសមុន (៣២,៨% ធៀបនឹងឆ្នាំមុន) មកត្រឹម ២០៣៤,៧ដុល្លារ/តោន ហើយអង្ករថៃ ធ្លាក់ថ្លៃ ១,១% (២៥,៨% ធៀបនឹងឆ្នាំមុន) មកត្រឹម ៤៥០,៧ដុល្លារ/តោន។ សណ្តែកសៀងធ្លាក់ថ្លៃ ៤,៦% ធៀបនឹងមួយឆ្នាំមុន, ប្រេងឆៅធ្លាក់ថ្លៃ ៤,៣%, សាំងធ្លាក់ថ្លៃ ៦,៣% ហើយប្រេងម៉ាស៊ូតធ្លាក់ថ្លៃ ៤,៨%។ ជារួម ថ្លៃទំនិញសំខាន់ៗលើពិភពលោកមាននិន្នាការធ្លាក់ចុះ។

---

អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.8 | 10.2 | 6.8 | 0.1 | 6.0 | 6.1 | 6.2 | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 5.4 | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.25 | 6.0 | 5.8 | 5.6 | 5.7 | 5.2 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 5.43 | 4.1 | 4.3 | 5.0 | 5.1 | 6.2 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.33 | 0.2 | 3.7 | 5.8 | 5.5 | 5.1 |
| ថៃ | 4.8 | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 6.75 | 5.4 | 2.6 | 2.6 | 0.4 | 3.1 |
| វៀតណាម | 8.1 | 8.5 | 6.2 | 4.7 | 6.7 | 6.1 | 5.03 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 7.75 | 7.7 | 7.5 | 7.8 | 7.7 | 7.1 |
| ហុងកុង | 6.6 | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 2.90 | 2.8 | 3.3 | 2.9 | 3.0 | 2.5 |
| កូរ៉េខាងត្បូង | 5 | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 2.13 | 1.5 | 2.3 | 3.3 | 4.0 | 4.1 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 1.23 | 1.7 | 2.3 | 1.7 | 2.9 | 3.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -3.8 | 1.6 | 1.6 | -0.48 | 1.1 | -0.7 | -0.4 | 0.5 | 0.9 |
| ជប៉ុន | 2.1 | 2 | -0.7 | -5.4 | 4.1 | -0.8 | 1.73 | 0.4 | 0.9 | 2.7 | 2.6 | 3.1 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.10 | 1.8 | 1.4 | 1.6 | 2.5 | 2.3 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 1.5 | 2.2 | 3.8 | 4.3 | 4.5 |
| ឥណ្ឌូណេស៊ី | 13.4 | 6.4 | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 5.3 | 5.7 | 8.6 | 8.4 | 7.7 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 1.4 | 1.8 | 2.2 | 3.0 | 3.5 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 3.6 | 1.6 | 1.8 | 2.0 | 1.0 |
| ថៃ | 4.7 | 2.2 | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 3.1 | 2.3 | 1.7 | 1.7 | 2.0 |
| វៀតណាម | 7.7 | 8.3 | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.9 | 6.6 | 7.0 | 5.9 | 4.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.4 | 2.4 | 2.8 | 2.9 | 2.1 |
| ហុងកុង | 2.2 | 2.0 | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 2.2 | 4.0 | 5.3 | 4.3 | 4.1 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.4 | 1.1 | 1.2 | 0.9 | 1.1 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 1.8 | 0.8 | 0.0 | 0.5 | 1.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.8 | 1.5 | 1.3 | 0.6 | 0.6 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -1.3 | -0.7 | 0.1 | -0.03 | -0.3 | -0.3 | 0.9 | 1.4 | 1.5 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.7 | 1.4 | 1.6 | 1.2 | 1.4 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.2 | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 3995.0 | 4032.9 | 4062.0 | 4018.9 | 3993.8 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9134.0 | 9419.0 | 9699.0 | 10413.8 | 9089.9 | 4374.0 | 9363.0 | 9681.9 | 9783.6 | 10,666.0 | 11,545.1 | 11,765.8 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.7 | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 3.1 | 3.0 | 3.2 | 3.2 | 3.3 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 1.4 | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.2 | 1.3 | 1.3 | 1.3 |
| ថៃ (បាត) | 37.9 | 32.22 | 33.4 | 34.3 | 31.7 | 30.5 | 31.1 | 29.8 | 29.9 | 31.4 | 31.7 | 32.6 |
| វៀតណាម (ដុង) | 15,994.0 | 16,030.0 | 16,382.0 | 17,725.2 | 19,200.8 | 20,574.3 | 20,856.9 | 20,829.6 | 20,828.0 | 20,908.7 | 21,036.0 | 21,036.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 7.97 | 8.03 | 6.9 | 6.8 | 6.76 | 3.3 | 7.8 | 6.2 | 6.2 | 6.1 | 6.1 | 6.1 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.8 | 7.8 | 7.8 | 7.77 | 7.8 | 1126.6 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 955 | 929.04 | 1137.2 | 1277.8 | 1156.3 | 1108.6 | 29.6 | 1085.9 | 1123.4 | 1108.8 | 1062.0 | 1069.7 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.5 | 32.85 | 31.5 | 33.0 | 31.3 | 29.4 | | 29.5 | 29.9 | 29.9 | 29.6 | 30.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 79.8 | 0.8 | 0.8 | 0.8 | 0.7 | 0.7 |
| ជប៉ុន (យ៉េន) | 116.4 | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 9363.0 | 92.3 | 98.8 | 98.9 | 100.5 | 102.8 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - USA (USD/តោន) | 111.0 | 149.1 | 218.2 | 167.3 | 167.3 | 291.4 | 296.5 | 305.2 | 291.4 | 246.2 | 199.3 | 209.6 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.9 | 707.7 | 912.2 | 686.8 | 834.7 | 1125.4 | 999.3 | 852.7 | 850.3 | 827.3 | 897.3 | 911.3 |
| កៅស៊ូ SMR 5 (USD/តោន) | 1996.3 | 2202.3 | 2586.3 | 1884.8 | 3152.2 | 4630.6 | 3200.7 | 3029.5 | 2497.2 | 2394.6 | 2380.0 | 2034.7 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.0 | 305.4 | 615.3 | 524.5 | 456.2 | 558.5 | 594.8 | 607.0 | 570.0 | 502.3 | 455.7 | 450.7 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 213.9 | 294.6 | 460.4 | 414.0 | 375.4 | 507.9 | 566.1 | 558.4 | 569.8 | 545.1 | 514.9 | 533.0 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.6 | 69.3 | 95.4 | 60.5 | 71.6 | 106.2 | 109.5 | 109.5 | 100.9 | 106.9 | 106.4 | 104.7 |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.7 | 53.6 | 62.2 | 42.9 | 49.8 | 71.9 | 74.6 | 74.8 | 71.2 | 73.3 | 65.7 | 70.1 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.4 | 55.5 | 51.6 | 75.7 | 83.8 | 77.8 | 80.7 | 80.3 | 81.5 | 75.6 | 79.6 | 77.5 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចចម្បងៗ

ការអនុម័តគម្រោងវិនិយោគ គិតជាទ្រព្យសកម្មជាប់លាប់ ក្នុងត្រីមាសទី១ ឆ្នាំ២០១៤ កើនឡើង ៩៥,១% ដល់ ៤២៦,៩ លានដុល្លារអាមេរិក ធៀបនឹងមួយឆ្នាំមុន។ កំណើននេះកើតមានឡើង ក្នុងពេលកំពុងមានភាពតានតឹង និងការទាល់ច្រក ផ្នែកនយោបាយ បន្ទាប់ពីការបោះឆ្នោតថ្នាក់ជាតិរួច។ វិនិយោគភាគច្រើន ស្ថិតក្នុងវិស័យឧស្សាហកម្ម (៤១,៩%) និងសេវាកម្ម (៥១,៣%)។ វិនិយោគខាងឧស្សាហកម្ម ក្នុងនេះមាន ៦១% សម្រាប់ផ្នែកកាត់ដេរ បានធ្លាក់ចុះ ៨,៤% ធៀបនឹងមួយឆ្នាំមុន ដល់ទៅ ១៧៩លានដុល្លារអាមេរិក។ វិនិយោគផ្នែកកាត់ដេរថយចុះ ០,២% ធៀបនឹងមួយឆ្នាំមុន។ តួលេខនេះហាក់បង្ហាញថា ការទាមទារបៀវត្សរ៍អប្បបរមា ១៦០ដុល្លារអាមេរិក/ខែ និងការតវ៉ាជាបន្តបន្ទាប់ មិនបានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ទំនុកចិត្តរបស់វិនិយោគិនទេ។ ទោះយ៉ាងណាក្តី បញ្ហានេះត្រូវតែមានដំណោះស្រាយយ៉ាងឆាប់តាមអាចធ្វើបាន។ វិនិយោគក្នុងវិស័យសេវាកម្ម បានកើនឡើងដល់ ២១៩,១លានដុល្លារអាមេរិក។

តម្លៃគម្រោងសាងសង់បានអនុម័ត ធ្លាក់ចុះអស់ ២១,៨% ដល់ ៣២៣,៦លានដុល្លារអាមេរិក ធៀបនឹងឆ្នាំមុន។ វិនិយោគលើភូមិគ្រឹះ និងផ្ទះបានធ្លាក់ចុះ ៨១,% និងផ្ទះល្វែងធ្លាក់ចុះ ៦,៧%។ ចំនួនភ្ញៀវទេសចរបរទេសមកដល់ បានកើនឡើង ៨,២% ធៀបនឹងមួយឆ្នាំមុន, ក្នុងនេះភ្ញៀវមកតាមផ្លូវអាកាសកើន ១៤,៤% និងតាមផ្លូវគោកឬទឹកកើន ១,៤%។ វិនិយោគលើសណ្ឋាគារ និងសកម្មភាពជាប់ទាក់ទងនឹងទេសចរណ៍ កើនដល់ ១៦៣,៣លានដុល្លារអាមេរិក។ កម្ពុជាអាចទាញយកប្រយោជន៍ពីការរីករវើផ្នែកនយោបាយ និងរដ្ឋប្រហារយោធានៅប្រទេសថៃ និងភាពតានតឹងរវាងប្រទេសវៀតណាម នឹងប្រទេសចិន លើបញ្ហាសមុទ្រចិនភាគខាងត្បូង ដើម្បីទាក់ទាញភ្ញៀវទេសចរឲ្យបានកាន់តែច្រើន។

ការនាំចេញនៅតែមមាញឹក ដោយកើន ២៥,៣% ធៀបនឹងឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ដែលមានចំណែក ៧៤,១% ក្នុងការនាំចេញសរុប បានកើនឡើង ១៩,៥% ដល់ ១,៥ពាន់លានដុល្លារអាមេរិក ក្នុងនេះការនាំចេញទៅ សហរដ្ឋអាមេរិកកើន ០,៨% និងទៅសហភាពអឺរ៉ុបកើនឡើង ៣៤,០%។ ទោះបីជាការនាំចេញសម្លៀកបំពាក់ទៅកាន់បណ្តាប្រទេសអាស៊ានមានត្រឹមតែ ១,៥% នៃចំនួនសរុបក្តី ប៉ុន្តែវាបានកើនឡើង ៦៧,៧% ធៀបនឹងឆ្នាំមុន។ កំណើននេះ ជាសញ្ញាប្រាប់ដល់រដ្ឋាភិបាលឲ្យពន្លឿនកិច្ចប្រឹងប្រែងធ្វើពិពិធកម្មទីផ្សារ និងជៀសវាងការពឹងផ្អែកខ្លាំងពេកទៅលើប្រទេសមួយចំនួនតូច។ ការធ្វើពិពិធកម្ម អាចជួយការពារសេដ្ឋកិច្ចក្នុងស្រុកអំពីវិបត្តិខាងក្រៅ។ ការនាំចេញទំនិញកសិកម្មក៏ខ្លាំងក្លាដែរក្នុងត្រីមាសទី១ ដោយកើន ៣៤,៩% ធៀបនឹងឆ្នាំមុន ប៉ុន្តែក្នុងនេះការនាំចេញកៅស៊ូបានធ្លាក់ចុះ ១៣,៣% និងអង្ករធ្លាក់ចុះ ១២,០%។ ថ្លៃកៅស៊ូក្នុងពិភពលោកបានបន្តធ្លាក់ចុះដល់ ២០៣៤,៧ដុល្លារអាមេរិក/តោន នៅត្រីមាសទី១ ហើយថ្លៃអង្ករ ក៏មាននិន្នាការស្រដៀងគ្នាដែរ។ វិស័យកសិកម្មមានចំណែកត្រឹមតែ ៨,៤% នៃតម្លៃនាំចេញសរុបប៉ុណ្ណោះ។

ការនាំចូលបានកើនឡើង ២,១% ធៀបនឹងឆ្នាំមុន ដល់ ២,២ ពាន់លានដុល្លារអាមេរិក។ ដោយឡែក ការនាំចូលប្រេងសាំងបានធ្លាក់ចុះ ១,៩% រីឯការនាំចូលប្រេងម៉ាស៊ូតកើនឡើង ៦,៨%។

## ហិរញ្ញវត្ថុសាធារណៈ

ប្រាក់ចំណូលសរុបក្នុងត្រីមាសទី៤ បានកើនឡើង ១៧,១% ធៀបនឹងឆ្នាំមុន ដល់ ២៣៦១,២ពាន់លានរៀល។ ចំណូលចរន្តដែលមានចំនួន ៩៨,១% នៃចំណូលសរុប បានកើនឡើង ១៦,២%។ ចំណូលពន្ធបានកើនឡើង ១៨,៣% និងចំណូលមិនមែនពន្ធកើនឡើង ៦,២%។ ក្នុងត្រីមាសដដែល ចំណាយសរុបរបស់រដ្ឋាភិបាលបានកើនឡើង ៥០,៧% ដល់ ១៤៦,៤ពាន់លានរៀល ក្នុងនេះចំណាយចរន្តមាន ៥៥,៧%។ ចំណាយលើបៀវត្សរ៍បានកើនឡើង ៥២,៦% រីឯការចំណាយលើឧបត្ថម្ភធន និងជំនួយសង្គម ធ្លាក់ចុះ ១១,២%។ ចំណាយមូលធនបានកើនឡើង ៨០,៣%។

## អតិផរណា និងអត្រាប្តូរប្រាក់

អតិផរណាមាននិន្នាការកើនឡើងចាប់ពីឆ្នាំ២០១៣ មក ហើយកើន ៤,៦% នៅត្រីមាសទី១ ឆ្នាំ២០១៤ ធៀបនឹង ១,៥% កាលពីឆ្នាំមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា បានកើនឡើង ៥,៧%។ រដ្ឋាភិបាលគួរយកចិត្តទុកដាក់លើការឡើងថ្លៃនេះ ពីព្រោះវាប៉ះពាល់អវិជ្ជមានទៅលើជីវភាពរស់នៅ ជាពិសេស ប្រជាជនក្រីក្រ។ ការផ្គត់ផ្គង់រូបិយវត្ថុគួរតែពិនិត្យតាមដានឲ្យបានដិតដល់ ពីព្រោះការផ្គត់ផ្គង់ច្រើនពេក ជាពិសេសក្នុងកម្រិតមួយដែលធំជាងផលិតភាព វាអាចនាំឱ្យមានការឡើងថ្លៃខ្ពស់ក្នុងរយៈពេលវែង។

ក្នុងត្រីមាសទី១នេះ ប្រាក់រៀលស្ទើរគ្មានការប្រែប្រួលសោះ ទល់នឹងប្រាក់ដុល្លារអាមេរិក បើធៀបនឹងឆ្នាំមុន ប៉ុន្តែបានឡើងថ្លៃ បើធៀបនឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម។ មាសបានធ្លាក់ថ្លៃ២០,៥%ធៀបនឹងឆ្នាំមុន ដល់១៥៦,៩ដុល្លារអាមេរិក/ជី។ ប្រេងម៉ាស៊ូតបានធ្លាក់ថ្លៃ ៣,២% ដល់ ៤៩៧១,២រៀល/លីត្រ ហើយប្រេងសាំង ធ្លាក់ថ្លៃ ៤,៤% ដល់ ៥១៧១,៥ដុល្លារអាមេរិក/លីត្រ។ ការធ្លាក់ថ្លៃប្រេងម៉ាស៊ូត និងប្រេងសាំងក្នុងពិភពលោក អាចជាមូលហេតុមួយនៃការធ្លាក់ថ្លៃទំនិញក្នុងស្រុក។

អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

**ការវិវត្តរូបិយវត្ថុ**

នៅត្រីមាសទី៤ រូបិយវត្ថុទូទៅសរុបបានកើន ១៤% ធៀបនឹងឆ្នាំមុន, រូបិយវត្ថុ បានកើន ២០% និងរូបិយវត្ថុផ្សេងៗ បានកើន ១៣,៦%។ ទ្រព្យសកម្មបរទេសសុទ្ធបានកើន ១៧,១% ធៀបនឹងឆ្នាំមុន ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធកើន ១០,៣%។ ឥណទានសម្រាប់វិស័យឯកជនកើន ១៧,% ធៀបនឹងឆ្នាំមុន។ កំណើននេះជាដំណឹងល្អ សម្រាប់សហគ្រាសឯកជនក៏ពិតមែន ប៉ុន្តែកំណើនការផ្គត់ផ្គង់រូបិយវត្ថុ អាចបង្កអតិផរណាក្នុងរយៈពេលវែង។ ទោះបីកម្រិតថ្លៃជារួមនៅអាចគ្រប់គ្រងបានក្តី ប៉ុន្តែវាកំពុងមាននិន្នាការកើនឡើងហើយ។

**ស្ថានភាពក្រីក្រ**

នៅខែឧសភា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយ និងអ្នកស៊ីឈ្នួលធ្វើស្រែធ្លាក់ចុះជាខ្លាំង ធៀបនឹងឆ្នាំមុន, ប្រាក់ចំណូលរបស់អ្នកលីសែង និងអ្នកបម្រើគុភោជនីយដ្ឋានធ្លាក់ចុះស្រាលជាង រីឯពលករងាយរងគ្រោះ ៦ក្រុមផ្សេងទៀតមានចំណូលកើនឡើង ក្នុងនេះមាន ៥ក្រុម បានកើនចំណូលយ៉ាងខ្លាំង។

បើធៀបនឹងខែកុម្ភៈ ប្រាក់ចំណូលរបស់អ្នករើសអេតចាយបានធ្លាក់ចុះ ៤,១% ដល់ ៩១៩៨រៀល/ថ្ងៃ ដោយសារចំនួនរបស់ពួកគេបានកើនឡើង ហើយកាត់បន្ថយឱកាសរកបានរបស់អេតចាយ។ អ្នកឆ្លើយសម្ភាសន៍ ៩៥% ប្រាប់ថា របស់អេតចាយបានចុះថ្លៃ ដោយសារមានអ្នកទិញតិចជាងមុន។ អ្នកឆ្លើយសម្ភាសន៍ ៩៣% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ប៉ុន្តែប្រាក់ចំណូលរបស់ពួកគេ ស្ទើរតែមិនគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់គ្រួសារដែលមានសមាជិកជាមធ្យម ៥នាក់នោះទេ។ អ្នកឆ្លើយសម្ភាសន៍ ៧៥% បានខ្ចីប្រាក់គេសម្រាប់ទ្រទ្រង់ជីវិត។

ប្រាក់ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ បានថយចុះយ៉ាងខ្លាំង អស់ប្រមាណ ៣៥% ធៀបនឹងអង្កេតលើកមុន ដល់ត្រឹម ៥៨៣៦រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ ៤០% ប្រាប់ថា ទោះបីពួកគាត់មានចំនួនតិចជាងមុនក្តី ក៏នៅតែមិនសូវមានការងារធ្វើច្រើនដែរ។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នា (៤០នាក់) មានដីស្រែតិចជាងមួយហិកតា។ ពួកគាត់បេះប្រមូលធនធានទ្រព្យរួមសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។ ពួកគាត់ធ្វើការជាមធ្យម ២១ថ្ងៃ/ខែ និង ៧ម៉ោង/ ថ្ងៃ។

ប្រាក់ចំណូលរបស់អ្នកបម្រើគុភោជនីយដ្ឋាន បានថយចុះ ១០% ដល់ ៦៦៩៦រៀល/ថ្ងៃ។ ចំនួនពួកគេនៅថេរ ប៉ុន្តែមានការងារម៉ោងបន្ថែមតិចជាងមុន។ ពលករ ៤០% ជាអ្នកមកពីខេត្តព្រៃវែង និង ២៣% មកពីខេត្តកំពត។ ពួកគេទទួលបានកន្លែងស្នាក់នៅ និងអាហារបីពេលក្នុងមួយថ្ងៃពីភោជនីយដ្ឋាន។ ពួកគេ ៩០% មិនមានប្រាក់ចំណូលគ្រប់គ្រាន់ សម្រាប់ទ្រទ្រង់គ្រួសារ ឬសន្សំទុកនោះទេ។

ឯផ្នែកវិជ្ជមានវិញ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែ បានកើនឡើង ១១% ដល់ ១៣.៥៨១រៀល។ អ្នកឆ្លើយសម្ភាសន៍ ៨៥% ប្រាប់ថា កំណើននេះ គឺដោយសារការថយចុះនៃចំនួនអ្នកលក់បន្លែ ព្រោះអ្នកខ្លះបានទៅប្រកបរបរផ្សេង ឬក៏ទៅលក់ដូរនៅកន្លែងផ្សេង។ អ្នកលក់មកពីខេត្តព្រៃវែង មាន ២៨%, ខេត្តកណ្តាល ២៥% និងស្វាយរៀង ២០%។ ពួកគេមិនអាចធ្វើដំណើរទៅមករាល់ថ្ងៃទេ ដូច្នេះបានជួលផ្ទះស្នាក់នៅរួមគ្នាបីនាក់ជាមធ្យម ហើយអាចកាត់បន្ថយចំណាយលើថ្លៃឈ្នួលមកត្រឹមជាមធ្យម ៥២.០០០រៀល/ខែ/នាក់។ ពួកគេមិនមានប្រាក់សន្សំទេ ពីព្រោះប្រាក់សល់ពីចំណាយ ត្រូវប្រើទាំងអស់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។ អ្នកឆ្លើយសម្ភាសន៍ ៨៣% ប្រាប់ថា គាត់ចង់មានដើមទុនច្រើនគ្រប់គ្រាន់ ដើម្បីអាចទិញបន្លែបានច្រើនមុខសម្រាប់លក់។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញ បានកើន៤,០%ដល់១៥.៧៦៥រៀល/ថ្ងៃ។ការងារបន្ថែមច្រើនជាងមុន និងចំនួនកម្មករតិចជាងមុន បានជួយជម្រុញកំណើននេះ ហើយការផ្តល់ប្រាក់ឈ្នួល ក៏មានលក្ខណៈប្រកួតប្រជែងខ្លាំងឡើងដែរ។ អ្នកផ្តល់ចម្លើយទាំងអស់សុទ្ធតែមកពីតាមខេត្ត ជាពិសេសព្រៃវែង (៣៥%) និងកំពង់ស្ពឺ (២០%) ហើយពួកគេអាចស្នាក់នៅកន្លែងការដ្ឋាន ដូច្នេះអាចសំចៃប្រាក់លើការចំណាយជួលផ្ទះស្នាក់នៅ។ ពួកគេមិនអាចទ្រទ្រង់គ្រួសារបានទាំងស្រុងទេ បើសិនគ្មានការចិញ្ចឹមសត្វនៅឯផ្ទះ បើតាមសំដីរបស់ ៥៣% នៃអ្នកផ្តល់ចម្លើយ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង បានកើន ៣,៥% ដល់ ១២.៥៦៨រៀល/ថ្ងៃ។ អ្នកផ្តល់ចម្លើយទាំងអស់នោះសុទ្ធតែមកពីតាមខេត្តនានា ជាពិសេសស្វាយរៀង (៤៣%) និងព្រៃវែង (៣៨%)។ ពួកគេបានមកធ្វើការនៅភ្នំពេញតែម្នាក់ឯងដោយគ្មានសាច់ញាតិណាម្នាក់ទេ។ អ្នកឆ្លើយសម្ភាសន៍ ៨៣% ត្រូវជួលផ្ទះស្នាក់នៅរួមគ្នាជាមួយមនុស្ស ៦នាក់ទៀតជាមធ្យម។ ពួកគេចំណាយអស់ប្រមាណ ១.០០០រៀល/ថ្ងៃ លើឈ្នួលផ្ទះ ឬ ៩% នៃចំណាយប្រចាំថ្ងៃរបស់ពួកគេ រីឯចំណាយលើម្ហូបអាហារមានប្រហែល ៨៧%។

នៅខែឧសភា ប្រាក់ចំណូលពិតរបស់កម្មករកាត់ដេរ បានកើន ១៩% ធៀបនឹងខែកុម្ភៈ ដល់ ១១.៣៩៣/ថ្ងៃ ដោយសារមានការងារបន្ថែមម៉ោងច្រើនជាងមុន។ ក្នុងចំណោមអ្នកផ្តល់ចម្លើយទាំង ១២០នាក់ គ្មានម្នាក់ណាបានបញ្ចប់ថ្នាក់ទី៥ ទេ ប៉ុន្តែមាន ៥៦% បានរៀនវគ្គបណ្តុះបណ្តាលឯកជនមុនពេលបានការងារធ្វើ។ ពួកគេសុទ្ធតែបានធ្វើការចាប់ពីបីខែឡើងទៅនៅក្នុងរោងចក្រ។ អ្នកផ្តល់ចម្លើយ ៨៥% អាចផ្ញើប្រាក់បៀវត្សរ៍មួយចំនួនទៅឲ្យក្រុមគ្រួសារ។ ទោះជាយ៉ាងដូច្នេះក្តី ក៏ ៥១% មិនចង់ផ្លាស់ប្តូរការងារទេ។ ពួកគេមិនដឹងថា ខ្លួនគេអាចធ្វើអ្វីផ្សេងបាន ហើយក៏មិនមានប្រាក់សន្សំ សម្រាប់ចាប់ផ្តើមអាជីវកម្មអ្វីផ្សេងទៀតដែរ។

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៦-១៤*

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 498.0 | 135.6 | 92.0 | 615.0 | 530.68 | 725 | 531.6 | 2.3 | 57.8 | 133.1 | 738.3 | 28.9 |
| ឧស្សាហកម្ម | 365.3 | 709.1 | 724.9 | 818.5 | 403.66 | 2860.1 | 829.3 | 195.4 | 1928.3 | 119.5 | 1014.1 | 179.0 |
| *កាត់ដេរ* | 89.4 | 170.7 | 142.8 | 90.1 | 122.81 | 393.9 | 497 | 109.5 | 76.4 | 65.15 | 73.1 | 109.3 |
| សេវាកម្ម | 2939.1 | 1742.5 | 10,003.2 | 4432.0 | 1337.34 | 3425.4 | 916.6 | 21.2 | 106.0 | 5.3 | 8.3 | 219.1 |
| *សណ្ឋាគារ និងទេសចរណ៍* | 345.0 | 1048.3 | 8758.1 | 3980.1 | 1105.14 | 2850.9 | 691.5 | 0.0 | 106.0 | 0.0 | 0.0 | 163.3 |
| សរុប | 3802.4 | 2587.2 | 10,570.9 | 5865.5 | 2271.7 | 7010.42 | 2278 | 218.9 | 2091.1 | 257.9 | 1760.7 | 426.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -81.1 | 855.5 | -87.7 | 582.8 | -75.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 246.6 | -32.0 | 308.6 | -44.5 | -61.3 | 209 | -67.5 | -47.5 | 666.0 | -39.9 | 52.2 | 95.1 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៦-១៤

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 33.1 | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 175.2 | 145.2 | 10.3 | 51.6 | 110.2 | 27.1 |
| ផ្ទះល្វែង | 213.3 | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 372.1 | 114.1 | 33.0 | 62.7 | 131.9 | 106.5 |
| ផ្សេងៗ | 76.8 | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 463.6 | 154.4 | 238.3 | 336.0 | 130.8 | 190.0 |
| សរុប | 323.3 | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 443.7 | 281.6 | 450.3 | 372.9 | 323.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 590.9 | -36.5 | 59.9 | -17.2 | -13.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | | 96.7 | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | -15.6 | 157.5 | 107.6 | -21.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៦-១៤

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1026.3 | 1280.2 | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 611.2 | 398.1 | 428.0 | 580.4 | 699.0 |
| តាមផ្លូវគោក និងទឹក | 673.0 | 740.5 | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 560.9 | 522.5 | 536.6 | 572.5 | 569.0 |
| សរុប | 1699.3 | 2020.7 | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 1172.1 | 920.5 | 964.6 | 1153.0 | 1268.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 16.4 | -21.5 | 4.8 | 19.5 | 10.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 20.2 | 18.9 | 5.3 | 0.5 | 13.6 | 20.1 | 24.4 | 17.8 | 20.9 | 17.5 | 14.5 | 8.2 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៦-១៤*

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 2810.9 | 3050.3 | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 1576.9 | 1620.1 | 1969.9 | 1815.4 | 1976.5 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2698.8 | 2938.9 | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 1225.2 | 1259.0 | 1568.5 | 1333.4 | 1464.0 |
| *- សហរដ្ឋអាមេរិក* | 1847.2 | 1956.5 | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 526.8 | 474.6 | 597.9 | 476.0 | 531.1 |
| *- សហភាពអឺរ៉ុប* | 601.0 | 654.3 | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 397.5 | 477.5 | 572.8 | 521.9 | 532.7 |
| *- អាស៊ាន* | 2.6 | 3.2 | 10.76 | 6.9 | 9.9 | 17.6 | 39.4 | 13.0 | 12.7 | 17.4 | 17.2 | 21.9 |
| *- ជប៉ុន* | 29.4 | 28.5 | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 57.6 | 51.4 | 98.1 | 71.6 | 101.4 |
| *- ប្រទេសផ្សេងៗ* | 218.7 | 296.4 | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 230.3 | 242.8 | 282.4 | 247.4 | 277.0 |
| កសិកម្ម | 59.7 | 55.7 | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 123.8 | 128.9 | 362.4 | 173.0 | 167.0 |
| *- កៅស៊ូ* | 41.5 | 41.0 | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 36.6 | 38.7 | 282.4 | 51.1 | 31.7 |
| *- ឈើ* | 8.6 | 8.7 | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 14.5 | 8.9 | 16.9 | 33.3 | 55.9 |
| *- ត្រី* | 5.9 | 3.2 | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 0.3 | 0.5 | 0.2 | 0.2 | 0.3 |
| *- អង្ករ* | 2.5 | 1.5 | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 65.8 | 56.5 | 57.3 | 82.7 | 57.9 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 1.2 | 1.2 | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 6.6 | 24.4 | 5.7 | 5.7 | 21.2 |
| ផ្សេងៗ | 52.3 | 55.8 | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 274.9 | 232.2 | 272.6 | 308.5 | 345.5 |
| ការនាំចូលសរុប | 3048 | 3770 | 4272.5 | 4331.5 | 5190.6 | 6375.9 | 8593.3 | 2192.1 | 2211.4 | 2059.7 | 2130.1 | 2238.2 |
| ក្នុងនេះ៖ | | | | | | | | | | | | |
| សាំង | 49.39 | 73.65 | 84.8 | 91.13 | 108.6 | 294.4 | 308.0 | 1225.2 | 77.2 | 71.3 | 80.5 | 77.4 |
| ម៉ាស៊ូត | 121.6 | 133.7 | 19.5 | 180.67 | 203.8 | 447 | 559.5 | 526.8 | 137.4 | 150.9 | 132.2 | 148.5 |
| សម្ភារៈសំណង់ | 33.8 | 44.31 | 56.3 | 49.74 | 57.6 | 48.1 | 66.1 | 397.5 | 17.8 | 18.0 | 17.2 | 27.8 |
| ផ្សេងៗ | 2843 | 3519 | 4011.8 | 4010 | 4820.6 | 5586.4 | 7659.1 | 13.0 | 1979 | 1819.4 | 1899.6 | 1984.5 |
| ជញ្ជីងពាណិជ្ជកម្ម | -237.0 | -719.9 | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -615.2 | -591.2 | -89.8 | -314.7 | -261.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | - | 7.4 | 2.8 | 24.6 | -15.0 | 9.8 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 8.4 | 2.7 | 21.6 | -7.8 | 8.9 |
| ការនាំចូលសរុប | - | - | - | - | - | - | - | 13.1 | 0.9 | -6.9 | 3.4 | 5.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 19.8 | 8.9 | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 14.4 | -14.6 | 18.0 | 16.9 | 19.5 |
| ការនាំចេញសរុប | 19.5 | 8.5 | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 23.2 | -8.8 | 23.4 | 24.8 | 25.3 |
| ការនាំចូលសរុប | 21.5 | 23.7 | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 36.2 | 17.3 | 2.2 | 9.9 | 2.1 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១៣ ( ពាន់លានរៀល )

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 1820.2 | 2204.8 | 1868.9 | 2361.2 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 1817.4 | 2241.3 | 1858.1 | 2316.3 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 1577.7 | 2024.0 | 1646.0 | 1950.4 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 1254.5 | 1652.9 | 1300.6 | 1520.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 323.1 | 371.1 | 345.4 | 430.3 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 239.8 | 217.4 | 212.2 | 365.9 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 8.4 | 18.1 | 24.3 | 33.2 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 153.3 | 173.3 | 178.8 | 245.0 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 78.1 | 25.9 | 9.0 | 87.7 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 6.2 | 11.5 | 10.7 | 45.0 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 2114.8 | 3181.6 | 3093.0 | 4146.4 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 1108.4 | 1273.7 | 1350.6 | 1834.8 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 1006.4 | 1907.8 | 1742.4 | 2311.6 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 505.0 | 757.0 | 827.3 | 908.0 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 252.0 | 652.5 | 285.0 | 373.4 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 249.4 | 498.3 | 630.1 | 1030.2 |
| សមតុល្យជាទូទៅ | -670 | -915.5 | -543.6 | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -294.6 | -976.7 | -1224.1 | -1785.2 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | -396.0 | -445.1 | 741.5 | 2055.10 | 1746.1 | 1845.2 | -2781.0 | 2457.8 | 906.0 | 1150.6 | 1032.2 | 1237.4 |
| ហិរញ្ញប្បទានក្នុងស្រុក | - | - | -185.8 | -127.00 | 474.9 | 938.6 | 2379.2 | -332.9 | -470.6 | 270.3 | 113.0 | 65.8 |

Source: MEF website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៦-១៤

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.7 | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 1.5 | 2.3 | 3.7 | 4.7 | 4.6 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 1.6 | 3.3 | 4.8 | 5.8 | 5.7 |
| - ដឹកជញ្ជូន | 9.1 | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -0.7 | -1.0 | -0.1 | -0.4 | -1.1 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.0 | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 3995 | 4033.1 | 4062 | 4059 | 3993.8 |
| រៀលក្នុង ១ បាតថៃ | 108.7 | 122.8 | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 134.7 | 135.74 | 131.4 | 130.7 | 123.0 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.1 | 25.0 | 24.8 | 23.4 | 21.72 | 19.7 | 19.4 | 19.3 | 19.34 | 19.3 | 19.4 | 19.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 70.6 | 83.2 | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 197.3 | 173.4 | 161.1 | 171.8 | 156.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3140.0 | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 5134.4 | 4992 | 5022.5 | 4927 | 4971.2 |
| ថ្លៃសាំង (រៀល/លីត្រ) | 4004.0 | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5410.5 | 5274.5 | 5245.2 | 5126.7 | 5171.5 |

Sources: NIS, NBC and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៨-១៣ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,345.0 | 14,655.0 | 16,697.9 | 17,893.9 | 19,976.7 | 18,729.6 | 18,463.8 | 18,154.5 | 19,976.7 | 21,772.9 | 18,720.7 | 21,260.1 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1513.3 | 1573.0 | 2778.9 | 5760.8 | 7931.8 | 7922.3 | 8400.3 | 10,437.4 | 10,504.1 | 9886.1 | 10,634.8 | 11,508.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2987.0 | -2252.0 | -2126.6 | -2123.1 | -2991.6 | -2399.9 | -2440.6 | -2486.4 | -2991.6 | -3012.6 | -2804.4 | -2794.9 |
| ឥណទានដល់ផ្នែកឯកជន | 9894.0 | 10,532.0 | 13,331.2 | 17,552.8 | 24,820.2 | 20,081.4 | 21,398.2 | 23,536.6 | 24,820.2 | 25,146 | 26,445.3 | 27,608.8 |
| រូបិយវត្ថុទូទៅ M2 | 11,858.0 | 16,228.0 | 19,476.8 | 23,654.7 | 30,480.8 | 26,651.9 | 26,864.1 | 28,591.9 | 30,480.8 | 31,659.1 | 29,355.5 | 32,768.4 |
| រូបិយវត្ថុ M1 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4500.6 | 3871.8 | 3818.2 | 4045.7 | 4500.6 | 4585.9 | 4720.8 | 4878.2 |
| រូបិយវត្ថុផ្សេងៗ | 9459.0 | 13,108.0 | 16,255.9 | 19,698.5 | 25,980.2 | 22,780.1 | 23,046.0 | 24,546.2 | 25,980.2 | 27,073.2 | 24,634.8 | 27,890.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 4.8 | 36.9 | 20.0 | 17.8 | 22.4 | 21.1 | 18.6 | 20.9 | 22.6 | 18.8 | 9.3 | 14.6 |
| រូបិយវត្ថុ M1 | 16.9 | 30.1 | 3.2 | 16.9 | 12.9 | 9.4 | 3.7 | 2.3 | 12.9 | 18.4 | 23.6 | 20.6 |
| រូបិយវត្ថុផ្សេងៗ | 2.2 | 38.6 | 24.0 | 17.9 | 24.4 | 23.4 | 21.5 | 44.6 | 24.4 | 18.8 | 6.9 | 13.6 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលកររងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2010 | 2011 | 2012 | 2013 | | | | 2014 | | 2013 | 2014 | |
| | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 9055 | 9532 | 10,303 | 9592 | 10,681 | 10,636 | 10,842 | 10,832 | 10,746 | 3.7 | 12.9 | 0.6 |
| អ្នកលីសែង | 9964 | 10,785 | 12,143 | 12,749 | 12,823 | 14,157 | 13,260 | 12,141 | 12,568 | 5.5 | -4.8 | -2.0 |
| អ្នកលក់បន្លែតូចតាច | 8266 | 8337 | 10,771 | 9953 | 11,571 | 11,490 | 12,449 | 12,294 | 13,581 | 18.1 | 23.5 | 17.4 |
| អ្នករើសអេតចាយ | 6698 | 8388 | 8680 | 9487 | 10,440 | 9620 | 9732 | 9593 | 9198 | 4.3 | 1.1 | -11.9 |
| អ្នកបម្រើភោជនីយដ្ឋាន* | 5607 | 5986 | 6111 | 6529 | 6744 | 6791 | 6723 | 7449 | 6696 | 4.4 | 14.1 | -0.7 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5691 | 5695 | 6151 | 5811 | 6427 | 7771 | 6388 | 8932 | 5836 | 27.8 | 53.7 | -9.2 |
| កម្មកររោងចក្រកាត់ដេរ | 7746 | 8409 | 8932 | 10,004 | 9776 | 10,420 | 10,442 | 9548 | 11,393 | 16.4 | -4.6 | 16.5 |
| អ្នករត់ម៉ូតូឌុប | 10,623 | 11,568 | 12,930 | 14,433 | 12,522 | 13,656 | 13,189 | 13,227 | 13,378 | 1.1 | -8.4 | 6.8 |
| កម្មករសំណង់គ្មានជំនាញ | 8790 | 10,307 | 11,078 | 12,554 | 13,728 | 13,023 | 13,431 | 15,162 | 15,316 | 18.1 | 20.8 | 11.6 |
| កម្មករសំណង់មានជំនាញ | 11,952 | 13,159 | 13,743 | 15,162 | 14,136 | 15,822 | 16,647 | 15,163 | 15,765 | 16.7 | 0.0 | 11.5 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI

# ផ្នែកស្រាវជ្រាវ

## កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ (DGPSR)

ពីខែមីនា ដល់ មិថុនា ២០១៤ កម្មវិធី DGPSR បានបញ្ចប់ការស្រាវជ្រាវសំខាន់ៗប្រាំ។ សម្រាប់របាយការណ៍ "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការចូលរួមរបស់យុវជនក្នុងសកម្មភាពនយោបាយ" ក្រុមស្រាវជ្រាវកំពុងឆ្លើយតបនឹងមតិយោបល់របស់អ្នកជួយពិនិត្យខ្លឹមសារ។ របាយការណ៍ព្រាងលើគម្រោង "ដំណោះស្រាយនយោបាយ និងកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា" និង "ដំណោះស្រាយនយោបាយ និងវិស័យសុខាភិបាលនៅកម្ពុជា" អ្នកស្រាវជ្រាវមួយចំនួននៅក្នុង និងនៅក្រៅវិទ្យាស្ថានកំពុងជួយពិនិត្យឡើងវិញ។ គម្រោង "រដ្ឋកម្ពុជា៖ តើមានលក្ខណៈល្អយ៉ាងណាសម្រាប់ការអភិវឌ្ឍ?" ដែលបានប្រើម៉ូដែលរដ្ឋសម្រាប់ការអភិវឌ្ឍ ដើម្បីធ្វើការវាយតម្លៃពីផលប៉ះពាល់នៃកំណែទម្រង់អភិបាលកិច្ច ទៅលើសមត្ថភាពស្ថាប័នរបស់រដ្ឋក្នុងការជំរុញការអភិវឌ្ឍនោះ ក៏ស្ថិតក្នុងដំណាក់កាលឆ្លើយតបនឹងការជួយមតិរបស់អ្នកស្រាវជ្រាវខាងក្នុង និងខាងក្រៅវិទ្យាស្ថានដែរ។ឯកសារពិភាក្សាព្រាងនៃការសិក្សាស្តីពី"ការអនុវត្តជាក់ស្តែងនូវវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស៖ កត្តាកំណត់ និងការប្រមើលឃើញនៅកម្ពុជា" បានបញ្ជូនចេញរួចហើយ ទៅជូនអ្នកពាក់ព័ន្ធមួយចំនួនឲ្យជួយផ្តល់មតិ។ របាយការណ៍ស្តីពី "ការសិក្សាពីការរួមចំណែក នៃសេវាកម្មមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការកែលំអទំនាក់ទំនងឧស្សាហកម្មនៅកម្ពុជា" ដែលជាគម្រោងស្រាវជ្រាវមានកម្មវិធីច្រើនសហការគ្នានោះ បានយកមកចងក្រង និងកែសម្រួល ដើម្បីឆ្លើយតបនឹងមតិយោបល់របស់អ្នកខាងក្រៅដែលជួយពិនិត្យខ្លឹមសារ។

គម្រោងសិក្សាថ្មីៗបួន បានចាប់ផ្តើម និងកំពុងអនុវត្តទៅមុខ។ ការសិក្សាស្តីពី "ការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា" សំដៅបង្ហាញពីកត្តា និងលក្ខខណ្ឌដ៏ចាំបាច់ៗ ដើម្បីសម្រេចបានគណនេយ្យភាព។ ក្រុមស្រាវជ្រាវកំពុងពិនិត្យឡើងវិញលើការសិក្សាមានស្រាប់ និងរចនារៀបចំក្របខ័ណ្ឌ និងវិធីសាស្ត្រស្រាវជ្រាវ។ គម្រោងស្តីពី "អភិបាលកិច្ច និងការផ្តល់សេវា៖ ករណីសិក្សាលើវិស័យសុខាភិបាល" កំពុងស្ថិតក្នុងដំណាក់កាល កសាងគោលគំនិត និងរចនារៀបចំប្លង់ស្រាវជ្រាវដោយមានការពិគ្រោះយោបល់ ជាមួយនឹងអ្នកពាក់ព័ន្ធជាច្រើន។ ការសិក្សាឯកសារមានស្រាប់ កំពុងដំណើរការទៅមុខ សម្រាប់ការសិក្សាស្តីពី "ការធ្វើសេចក្តីសម្រេចចិត្ត និងការអភិវឌ្ឍសមត្ថភាពខាងធនធានទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា"។ សម្រាប់គម្រោង "របាយការណ៍ពិសេសរបស់វិទ្យាស្ថាន CDRI ស្តីពីការអប់រំនៅកម្ពុជា" ដែលជាការងាររួមគ្នារបស់កម្មវិធីស្រាវជ្រាវទាំងប្រាំនៃ CDRI នោះ គឺកម្មវិធី DGPSR ទទួលការងារចងក្រងជំពូកស្តីពី ការអប់រំកម្រិតបឋម ហើយបច្ចុប្បន្នកំពុងបង្កើយផែនការទូទៅ ការសិក្សានៅការិយាល័យ និងការធ្វើសម្ភាសន៍នៅថ្នាក់ជាតិ។

## កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC)

"អង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះ" និង "អង្កេតប្រចាំខែលើថ្លៃទំនិញតាមខេត្ត" កំពុងបន្តទៅមុខយ៉ាងទៀងទាត់។

ការសិក្សាពី "ទំនាក់ទំនងរវាងការងារ និងភាពក្រីក្រនៅកម្ពុជា" បានបោះពុម្ពផ្សាយជាឯកសារពិភាក្សាលេខ ៩២ របស់ CDRI។ ការសិក្សាពីរបន្ថែមទៀត ស្តីពី "ភាពជួយដល់ជនក្រីក្រនៃគោលនយោបាយហិរញ្ញវត្ថុ" និង "កំណើនសេដ្ឋកិច្ច វិសមភាព និងការកាត់បន្ថយភាពក្រីក្រ" ក្នុងគម្រោងស្រាវជ្រាវរយៈពេលប្រាំឆ្នាំ ទ្រទ្រង់ដោយ Sida ស្តីពី "កំណើនសម្រាប់គ្រប់គ្នា" កំពុងចងក្រងបង្ហើយ សម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សា។ ដំណើរការចាត់ចែងទិន្នន័យ សម្រាប់អង្កេតគ្រួសារតាមដានបន្តដែលបានអនុវត្តនៅខែមីនា ២០១៤ បានចប់សព្វគ្រប់ ហើយក្រុមស្រាវជ្រាវកំពុងធ្វើការលើប្រធានបទខុសៗគ្នា ដូចជា ភាពក្រីក្រ កម្លាំងពលកម្ម ចំណាកស្រុក និងមីក្រូហិរញ្ញវត្ថុ ដើម្បីផ្តល់នូវការយល់ដឹងបន្ថែមសម្រាប់គម្រោង "កំណើនសម្រាប់គ្រប់គ្នា"។

បន្ទាប់ពីទទួលបានមតិបន្ថែម ក្នុងពេលធ្វើសិក្ខាសាលាកាលពីថ្ងៃទី៥-៨ ឧសភា នៅប្រទេស Bolivia នោះ របាយការណ៍ស្តីពី "ចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជា៖ មូលហេតុ និងផលប៉ះពាល់លើភាពក្រីក្រ វិសមភាព និងផលិតភាព" ត្រូវបានកែសម្រួល ដើម្បីផ្ញើជូនជាថ្មីម្តងទៀតទៅ អង្គការភាពជាដៃគូដើម្បីសិក្សាពីគោលនយោបាយសេដ្ឋកិច្ច (PEP)។ ការចុះសិក្សាដល់កន្លែងសម្រាប់គម្រោង ស្តីពី "ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈនៃប្រទេសជាដៃគូ ចំណាកស្រុក និងការអភិវឌ្ឍ៖ ករណីសិក្សា និងអនុសាសន៍ផ្អែកគោលនយោបាយ" ដែលទទួលមូលនិធិពី អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) នោះ បានចប់រួចរាល់ ហើយទិន្នន័យប្រមូលបានកំពុងយកមកចាត់ចែង។ ការចុះសិក្សាដល់កន្លែងជុំទី២ សម្រាប់ "គម្រោងអង្កេតដើម្បីជំរុញ SMEs" បានហើយស្រេចបាច់។ គម្រោងនេះ អនុវត្តឡើងតាមកិច្ចសន្យាជាមួយ JICA និងរួមមាន ការសម្ភាសជាមួយអ្នកតំណាងមកពីសហគ្រាសធុនតូច និងមធ្យម (ក្នុងនេះមាន ៣៥ SMEs ជ្រើសរើសសម្រាប់អង្កេតបែបគុណភាព និង ២៦៥ SMEs ទៀត សម្រាប់អង្កេតបែបបរិមាណ) ក្នុងខេត្តបាត់ដំបង កំពង់ចាម កំពង់ស្ពឺ សៀមរាប ព្រះសីហនុ និងស្វាយរៀង។ ក្រុមស្រាវជ្រាវកំពុងចងក្រងព្រាងរបាយការណ៍សំយោគ ស្តីពីលទ្ធផលអង្កេត និងផលពាក់ព័ន្ធផ្សេងៗដែលបានរកឃើញ តាមរយៈការចុះសិក្សាដល់ទីកន្លែងទាំងពីរលើក។

កម្មវិធី ETRC បានទទួលកិច្ចសន្យាពីកម្មវិធីស្បៀងអាហារពិភពលោក (WFP) ដើម្បីធ្វើការពិនិត្យបូកសរុបជាយុទ្ធសាស្ត្រលើ "ការសិក្សាសាកល្បងរបស់កម្មវិធីស្បៀងអាហារពិភពលោកស្តីពីប្រទេសមានចំណូលមធ្យម "ករណីប្រទេសកម្ពុជា"។

## កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE)

ក្រុមស្រាវជ្រាវ កំពុងអនុវត្តគម្រោងស្រាវជ្រាវបួន ក្នុងនេះមាន២គម្រោងទទួលបានការទ្រទ្រង់ពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida)។ គម្រោងស្តីពី "សមត្ថភាពបន្សាំរបស់ប្រជាជនជនបទក្នុងតំបន់កសិអេកូឡូស៊ីចម្រុះៗ" បានបោះពុម្ពផ្សាយរបាយការណ៍ជាឯកសារពិភាក្សាលេខ ៩៣ របស់វិទ្យាស្ថាន CDRI។ ក្រុមស្រាវជ្រាវ ក៏កំពុងចុះសិក្សាដល់កន្លែងនៅខេត្តកំពង់ឆ្នាំង កំពង់ធំ តាកែវ និងព្រៃវែង សម្រាប់គម្រោងស្តីពី "បច្ចេកវិទ្យាកសិកម្ម៖ ការអនុវត្ត និងចន្លោះខ្វះខាតក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ"។ ការសិក្សាដល់កន្លែងសម្រាប់គម្រោងទទួលមូលនិធិពី ក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ច និងសង្គម (ESRC) ស្តីពី "ប្រទេសចិនឈានឡើងកម្រិតសាកល" បានចប់សព្វគ្រប់ ហើយជំហានបន្ទាប់ គឺការវិភាគទិន្នន័យប្រមូលបាន និងការចងក្រងនិងចែកចាយលទ្ធផលសិក្សា។

ឯកសារពិភាក្សាទី១ សម្រាប់គម្រោង "ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា" ដែលទទួលមូលនិធិពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា កំពុងចងក្រងបង្ហើយ បន្ទាប់ពីទទួលបានមតិយោបល់ពីទីប្រឹក្សាស្រាវជ្រាវ។ ក្រុមស្រាវជ្រាវគម្រោងសិក្សាតូចទី២ បានបង្កើតម៉ូដែលមួយ និងធ្វើការបណ្តុះបណ្តាលពីការប្រើម៉ូដែលនោះ សម្រាប់វាយតម្លៃពីលក្ខណៈធារាសាស្ត្រនៃដែនរងទឹកភ្លៀង។ ការសិក្សាដល់កន្លែង ដើម្បីប្រមូលទិន្នន័យកំពុងអនុវត្តក្នុងដែនរងទឹកភ្លៀងបី នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងកំពង់ធំ។ ក្រុមស្រាវជ្រាវក្នុងគម្រោងសិក្សាតូចទី៣ បានបញ្ចប់ការសិក្សាលើឯកសារមានស្រាប់ និងកំពុងរៀបចំព័ត៌មានមុននឹងចាប់អនុវត្តការសិក្សាដល់កន្លែង។ ចំពោះផ្នែកកសាងសមត្ថភាពវិញ និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាប័ត្រ ១៣រូប និងថ្នាក់អនុបណ្ឌិត ៥រូប កំពុងទទួលការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) និងសាកលវិទ្យាល័យបច្ចេកវិទ្យាកម្ពុជា (ITC)។ ក្រៅពីបំពេញការងារក្នុងវគ្គសិក្សានិស្សិតទាំងនេះ កំពុងចងក្រងគោលគំនិតស្តីពីការរចនារៀបចំ និងវិធីសាស្ត្រស្រាវជ្រាវ សម្រាប់ប្រធានបទស្រាវជ្រាវផ្ទាល់របស់ពួកគេ។

កម្មវិធី NRE បានរួមគ្នាជាមួយដៃគូជាច្រើនទៀត ដាក់ស្នើទៅម្ចាស់ជំនួយនូវសំណើស្រាវជ្រាវចំនួន ៥ លើប្រធានបទដូចតទៅ៖ "ការឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធធានាភាពស្របច្បាប់នៃអាជីវកម្មព្រៃឈើនៅកម្ពុជា" ដែលបានដាក់ស្នើទៅកម្មវិធីការពង្រឹងអនុវត្តន៍ច្បាប់ព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្ម (FLEGT) របស់ EU-FAO, "SERVIR Mekong[1]" បានដាក់ទៅ USAID, "ថាមពលវារីអគ្គិសនីនៅអាងមេគង្គក្រោម៖ ការបង្កើតបណ្តាញទាក់ទង ការកំណត់បញ្ហា និងការចែករំលែកចំណេះដឹង" ដាក់ទៅ អង្គការសង្គមអាល្លឺម៉ង់ដើម្បីសហប្រតិបត្តិការអន្តរជាតិ (GIZ), "ការសិក្សាតាមដានបន្ត លើការសិក្សាទូទាំងប្រទេសនៅឆ្នាំ២០១១ ស្តីពី ចំណេះដឹង ឥរិយាបថ និងរបៀបរបបអនុវត្តន៍ទាក់ទិននឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (KAP2)" ដាក់ទៅផ្នែកសម្ព័ន្ធភាពបម្រែបម្រួលអាកាសធាតុនៅកម្ពុជា នៃក្រសួងបរិស្ថាន, និង "ការតភ្ជាប់វិធីសាស្ត្រជាសាកល និងផ្អែកតាមបរិបទជាក់លាក់ ទៅនឹងការអប់រំអំពី ចីរភាព" (CDRI ចូលរួមជាអ្នកសហការស្រាវជ្រាវ) ដាក់ទៅ សាកលវិទ្យាល័យបច្ចេកវិទ្យា Nangyang (NTU) នៃប្រទេសសិង្ហបុរី។ សំណើមួយទៀតស្តីពី "ការគ្រប់គ្រងកាកសំណល់ នៅតាមភូមិបណ្តែតទឹកនៅបឹងទន្លេសាប" កំពុងរៀបចំឡើង ដោយរួមសហការជាមួយអាជ្ញាធរទន្លេសាប សម្រាប់ដាក់ស្នើទៅកម្មវិធីជំនួយឥតសំណងរបស់ប្រទេសជប៉ុន នៅចុងឆ្នាំនេះ។

[1] សមាគមសម្រាប់ការសង្កេតពីផែនដី៖ SERVIR ជាគម្រោងរួមសហការគ្នាមួយរវាង កម្មវិធីវិទ្យាសាស្ត្រអនុវត្តន៍ផ្នែកវិទ្យាសាស្ត្រផែនដីនៃអង្គការ NASA, USAID, និង បណ្តាស្ថាប័នដៃគូទូទាំងពិភពលោក។ SERVIR លើកកម្ពស់ការគ្រប់គ្រងបរិស្ថាន និងចម្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយជួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ឲ្យដាក់បញ្ចូលបច្ចេកវិទ្យាវិភាគទិន្នន័យភូមិសាស្ត្រ និងការសង្កេតពីផែនដី ទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត (www.servirglobal.net/)។

## កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD)

កម្មវិធី PARD កំពុងអនុវត្តគម្រោងស្រាវជ្រាវ ១០ ក្នុងនោះមាន ៤គម្រោង ជាកិច្ចសហការជាមួយកម្មវិធី SD, ETRC, DGPSR និងក្រុមការងារផ្នែកយេនឌ័រ។ ក្នុងគម្រោង ស្តីពី "ការបង្កើតគោលនយោបាយកសិកម្មសម្រាប់ ប្រព័ន្ធដាំដុះផ្តោតលើដំណាំស្រូវនៅកម្ពុជា និងឡាវ" ដែលទទួលមូលនិធិពី មជ្ឈមណ្ឌលអូស្ត្រាលីដើម្បីការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ក្រុមស្រាវជ្រាវបានធ្វើបទបង្ហាញ លើលទ្ធផលស្រាវជ្រាវសំខាន់ៗ ស្តីពី បញ្ហាប្រឈមខាងគោលនយោបាយ ដែលវិស័យស្រូវនៅកម្ពុជាកំពុងជួបប្រទះ ក្នុងកិច្ចសន្ទនាផ្នែកគោលនយោបាយ ស្តីពីជំនួញលើស្រូវអង្ករមុនការប្រមូលផល៖ ការស្រាវជ្រាវពីប្រព័ន្ធដាំដុះផ្តោតលើដំណាំស្រូវនៅតំបន់មេគង្គ ដែលរៀបចំដោយការិយាល័យកណ្តាលរបស់ ACIAR កាលពីថ្ងៃទី៧-៩ ឧសភា នៅទីក្រុងភ្នំពេញ។ របាយការណ៍ព្រាងទី២ ស្តីពី "ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យា ទៅលើជីវភាពរបស់ម្ចាស់ដីតូចៗ" ដែលទទួលបានមូលនិធិពី Sida ជិតចប់រួចរាល់។ របាយការណ៍សម្រាប់គម្រោងទទួលបានមូលនិធិពី Sida ស្តីពី "យន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មនៅក្នុងវិស័យកសិកម្ម" នៅបន្តផ្អាកដំណើរការ ដោយសារមានការពន្យាពេលកំណត់រហូតដល់ខែធ្នូ ២០១៤។ របាយការណ៍ព្រាងទី១ សម្រាប់គម្រោងទទួលមូលនិធិពី WFP ស្តីពី "ការរចនារៀបចំក្របខ័ណ្ឌវាយតម្លៃ និងការត្រួតពិនិត្យលើអង្កេតគោល និងអង្កេតចុងបញ្ចប់ សម្រាប់ការជួយទ្រទ្រង់ដល់ជីវភាព និងទ្រព្យផលិតកម្ម" បានចប់សព្វគ្រប់ ហើយរបាយការណ៍ស្តីពី "អង្កេតគោលសម្រាប់គម្រោងផ្តល់អាហារនៅតាមសាលារៀន និងរបបអាហារយកទៅផ្ទះ របស់ McGovern-Dole នៅកម្ពុជា" បានចងក្រងស្រេចបាច់ និងផ្ញើជូនទៅ WFP រួចហើយ។ របាយការណ៍ព្រាងទី២ ស្តីពី "អង្កេតពីការចម្លងតាមគ្នាក្នុងផលិតកម្មផ្កា បន្លែ ផ្លែឈើ ស្រូវ និងវារីវប្បកម្ម" ដែលទទួលមូលនិធិពី USAID តាមរយៈ Fintrac ក៏បានបញ្ជូនទៅម្ចាស់ជំនួយរួចហើយដែរ។

របាយការណ៍លើ គម្រោងស្រាវជ្រាវមានកិច្ចសហការពីច្រើនកម្មវិធី គឺមាន "ReBUILD" ដែលដឹកនាំដោយ SD, "ចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជា" ដឹកនាំដោយ ETRC និង "អង្កេតចុងបញ្ចប់ លើការរួមចំណែកនៃសេវាកម្មមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល (ACF) ក្នុងការកែលំអទំនាក់ទំនងក្នុងឧស្សាហកម្មនៅកម្ពុជា" ដឹកនាំដោយ DGPSR នោះ មានលើកឡើងនៅក្នុងកម្មវិធីនីមួយៗថែមទៀត។

**កម្មវិធីអភិវឌ្ឍន៍សង្គម** (SD)

គម្រោងស្រាវជ្រាវធំៗបួន កំពុងដំណើរការ។ សម្រាប់ ៣ អនុគម្រោង ក្នុងគម្រោង "ReBUILD" ដែលទទួលមូលនិធិពី DFID គឺមាន "ហិរញ្ញប្បទានផ្នែកសុខភាព", "ធនធានមនុស្សផ្នែកសុខាភិបាល" និង "ការចុះកិច្ចសន្យាផ្នែកសុខាភិបាល" ក្រុមស្រាវជ្រាវបានបញ្ចប់ការដាក់លេខកូដទិន្នន័យ និងការកំណត់គោលគំនិតក្នុងការសិក្សា ហើយកំពុងចងក្រងរបាយការណ៍ព្រាងដំបូង។ គម្រោង "ការសិក្សាពីពលកម្មកុមារ" ដែលរួមមាន ៤ អនុគម្រោង សម្រាប់រយៈពេល ២ឆ្នាំនោះ កំពុងរង់ចាំយោបល់ត្រឡប់ពីអ្នកខាងក្រៅ ដែលជួយពិនិត្យរបាយការណ៍ព្រាង ស្តីពី "កុមារបម្រើការងារតាមផ្ទះ" និង "ផលប៉ះពាល់នៃចំណាកស្រុករបស់មនុស្សពេញវ័យ ទៅលើសុខុមាលភាពរបស់កុមារ"។ ដំណាលគ្នានេះ អនុគម្រោងទី៣ ស្តីពី "ភាពគ្មានដីធ្លី និងពលកម្មកុមារ" បានចាប់អនុវត្ត។ ការសិក្សាពីពលកម្មកុមារនេះ ជាផ្នែកមួយនៃគម្រោង Cambodian-EXCEL របស់អង្គការទស្សនៈពិភពលោកកម្ពុជា (World Vision Cambodia) និងទទួលមូលនិធិពី ក្រសួងការងារសហរដ្ឋអាមេរិក (USDOL) សម្រាប់រយៈពេល ៤ឆ្នាំ ដល់ឆ្នាំ២០១៦។ ក្រុមស្រាវជ្រាវក្នុងគម្រោង "ReBUILD ដំណាក់កាលទី២" ដែលទទួលមូលនិធិពី DFID ដែរ បានអនុវត្តរួចរាល់នូវការសាកល្បងកម្រងសំណួរ ដោយបានលុបបំបាត់ ចំណុចអាចមានកំហុសក្នុងការកត់ត្រាពីការសន្ទនា និងកំពុងរៀបចំការសិក្សាដល់កន្លែង ដែលគ្រោងធ្វើឡើងក្នុងខែសីហា។ កម្មវិធី SD ក៏បានបញ្ចប់ការសិក្សាស្តីពី "ផលប៉ះពាល់នៃគម្រោងផ្តល់មូលនិធិដោយ CARF" ដែលជាការសិក្សាអនុវត្តឡើងតាមកិច្ចសន្យាជាមួយ ACIAR។

កម្មវិធី SD បានរៀបចំ និងដាក់សំណើស្រាវជ្រាវជាច្រើនទៅជូនបណ្តាស្ថាប័នដៃគូផ្តល់មូលនិធិ មានជាអាទិ៍ គម្រោងស្តីពី "សេវាកម្មតាមកិច្ចសន្យាក្នុងវិស័យសុខាភិបាលនៅកម្ពុជា" តើសេវាកម្មណាខ្លះមានដំណើរការល្អ?" ដាក់ស្នើ ទៅអង្គការសុខភាពពិភពលោក (WHO), "ការស្រាវជ្រាវលើការយល់ឃើញរបស់អ្នកប្រើប្រាស់អំពី ការប្រើកងពន្យាកំណើតដើម្បីធ្វើផែនការគ្រួសាររយៈពេលវែង" ដាក់ទៅ អង្គការមូលនិធិប្រជាជនសហប្រជាជាតិ (UNFPA) និង "អង្កេតពីការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល" ដាក់ទៅ ធនាគារពិភពលោក។

*ក្រុមការងារផ្នែកយេនឌ័រ (GWG)*

នៅក្នុងដំណើរការដាក់បញ្ចូលនូវ ការគិតគូរពីបញ្ហាយេនឌ័រទៅក្នុងការស្រាវជ្រាវផ្នែកអភិវឌ្ឍន៍ និងដើម្បីដាក់បញ្ចូលការយល់ដឹងអំពីយេនឌ័រទៅក្នុងគ្រប់ទិដ្ឋភាព នៃការស្រាវជ្រាវ និងសកម្មភាពធ្វើប្រតិបត្តិការនោះ CDRI បានចុះកិច្ចសន្យាជាមួយនឹងទីប្រឹក្សាផ្នែកយេនឌ័រមួយរូប។ ទីប្រឹក្សាផ្នែកយេនឌ័រនេះនឹងផ្តល់ការប្រឹក្សាយោបល់ ពីថ្ងៃទី ១ មិថុនា ដល់ ៣០ សីហា ២០១៤ ហើយមានមុខងារជាក់លាក់ ដូចតទៅ៖ (១) ពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្ររបស់ CDRI, យុទ្ធសាស្ត្រស្រាវជ្រាវ និងផែនការបច្ចុប្បន្នផ្នែកយេនឌ័រ, (២) ពិនិត្យពីគោលនយោបាយយេនឌ័ររបស់កម្ពុជា និងកំណត់រកអាទិភាពគោលនយោបាយខាងផ្នែកយេនឌ័រ (ការវិភាគគោលនយោបាយ), (៣) កំណត់រកចន្លោះខ្វះខាតក្នុងការស្រាវជ្រាវផ្នែកយេនឌ័រ (ឬ ប្រធានបទស្រាវជ្រាវផ្នែកយេនឌ័រដែលបានស្នើឡើង) សម្រាប់កម្មវិធីស្រាវជ្រាវទាំងប្រាំរបស់ CDRI ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ, (៤) ធ្វើការវាយតម្លៃលើផ្នែកយេនឌ័រនៅក្នុងស្ថាប័ន ដើម្បីកំណត់ពីតម្រូវការកសាងសមត្ថភាពស្រាវជ្រាវ ក្នុងចំណោមបុគ្គលិកផ្នែកស្រាវជ្រាវនៅ CDRI និង (៥) បង្កើត ក្របខ័ណ្ឌ/ផែនការកសាងសមត្ថភាពផ្នែកយេនឌ័រឆ្លើយតបតាមតម្រូវការ។ ជាលទ្ធផលការងារទីប្រឹក្សាផ្នែកយេនឌ័រ នឹងកសាងផែនការផ្នែកយេនឌ័រថ្មីទាន់ពេលមួយសម្រាប់ CDRI, ធ្វើការកែសម្រួលឲ្យបានស្របគ្នានូវផែនការយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រស្រាវជ្រាវរបស់ CDRI ព្រមទាំងក្របខ័ណ្ឌកសាងសមត្ថភាពផ្នែកយេនឌ័រ សម្រាប់អ្នកស្រាវជ្រាវនៅ CDRI ។

**NEW FROM CDRI**

**Adaptation Capacity of Rural People in the Main Agro-Ecological Zones in Cambodia**




There is a growing need for vulnerability and adaptation assessment in the wake of today's challenge of climate change. The study sought to gain a better understanding of how farmers across Cambodia's four main agro-ecological regions are coping with increasingly irregular climate/weather conditions. The paper examines the implications of climate change and its impacts on natural resources and rural livelihoods, and assesses current adaptive capacities and climate adaptation strategies to identify measures to build local communities' capabilities to manage existing risks and potential hazards. The paper concludes that there is need for initiatives that enhance household assets including access to institutions and entitlement, disseminate knowledge and information, foster local innovation and participatory decision making, and promote forward-looking, flexible governance. All of these elements are critical to building the adaptive capacity of farmers, their households, and rural communities.

*WP 93 in English, 60 p. 2014: $2.00*
*www.cdri.org.kh/webdata/download/wp/wp93e*

# សេចក្តីប្រកាស

## ការផ្លាស់ប្តូរថ្នាក់ដឹកនាំនៃវិទ្យាស្ថាន CDRI នៅខែកញ្ញា ២០១៤

ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI បានប្រកាសថា ឆ្លងតាមដំណើរការជ្រើសរើសជាអន្តរជាតិ និងមានលក្ខណៈប្រកួតប្រជែងពេញលេញ ក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន CDRI បានសម្រេចជ្រើសតាំង បណ្ឌិត ឆែម គាត រិទ្ធី ជាអ្នកបន្តវេនពីលោក Larry Strange ក្នុងតំណែងជានាយកប្រតិបត្តិនៃ CDRI ចាប់ពីថ្ងៃទី០១ កញ្ញា ២០១៤ តទៅ។ លោក Larry Strange ដឹកនាំវិទ្យាស្ថាន CDRI បានជាង ១០ឆ្នាំ មុននឹងលាលែងពីតំណែងនេះ ហើយលោកនឹងបន្តតួនាទីជាទីប្រឹក្សាជាន់ខ្ពស់នៃ CDRI ដើម្បីជួយផ្តល់ការគាំទ្រក្នុងកម្មវិធី និងបញ្ហាជាក់លាក់មួយចំនួនផ្នែកគោលនយោបាយ។

បណ្ឌិត ឆែម គាត រិទ្ធី នឹងវិលមកប្រទេសកម្ពុជាវិញ បន្ទាប់ពីបានបំពេញតួនាទីបច្ចុប្បន្នរបស់លោក ជានាយកផ្នែកសុខភាពមនុស្ស នៃនាយកដ្ឋានវិទ្យាសាស្ត្របរមាណូនិងការប្រើប្រាស់ នៃទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ នៅទីក្រុង Vienna។ បណ្ឌិត ឆែម គាត រិទ្ធី បានទទួលការអប់រំនៅប្រទេសកម្ពុជា, កាណាដា, បារាំង និងសហរដ្ឋអាមេរិក ហើយបានសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកប្រវត្តិសាស្ត្រនិងការអប់រំ និងផ្នែកសុខាភិបាល។ លោកមានអាជីពវិជ្ជាជីវៈយូរឆ្នាំ និងប្រកបដោយជោគជ័យខាងសុខាភិបាលនិងអប់រំ និងធ្លាប់ទទួលបានការតែងតាំងក្នុងតំណែងផ្នែកអប់រំ នៅតាមប្រទេសជាច្រើន ដូចជា កាណាដា សិង្ហបុរី និងជប៉ុន។

ជាមួយនឹងការធ្វើសេចក្តីប្រកាស ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ជាប្រធានគណៈកម្មាធិការជ្រើសរើសនៃក្រុមប្រឹក្សាភិបាល បានបញ្ជាក់ថា "គណៈកម្មាធិការជ្រើសរើសនៃក្រុមប្រឹក្សាភិបាល CDRI បានជ្រើសយកបណ្ឌិត ឆែម គាត រិទ្ធី អំពីវិស័យអន្តរជាតិដ៏រឹងមាំមួយ ដើម្បីឲ្យមកដឹកនាំ CDRI ឆ្ពោះទៅមុខនៅក្នុងដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍរបស់វិទ្យាស្ថាន ដោយបន្តកសាងលើមូលដ្ឋានគ្រឹះរឹងមាំ បន្សល់ទុកពីនាយកមុនទាំងពីររូបរបស់វិទ្យាស្ថាន គឺលោកស្រី Eva Mysliwiec និង លោក Larry Strange។ វិទ្យាស្ថានទាំងមូលមានសេចក្តីសោមនស្សរីករាយជាអនេកដោយ ការតែងតាំងលោកនាយកថ្មី ជួយឲ្យ CDRI សម្រេចបាននូវ "កម្ពុជាភាវូបនីយកម្ម" នៃថ្នាក់ដឹងនាំ ដែលវិទ្យាស្ថានបានព្យាយាមអនុវត្តចំនួនមួយទសវត្សរ៍កន្លងមកហើយ។ ប្រវត្តិការងារដ៏ខ្លាំងក្លារបស់បណ្ឌិត ឆែម គាត រិទ្ធី ខាងសុខាភិបាល និងអប់រំ ដែលជាអាទិភាពអភិវឌ្ឍន៍ចម្បងពីរនៅកម្ពុជា ព្រមទាំងបទពិសោធន៍ និងបណ្តាញអន្តរជាតិរបស់លោក គឺជាទ្រព្យដ៏មានតម្លៃសម្រាប់វិទ្យាស្ថាន CDRI ។"

លោក Larry Strange ជានាយកប្រតិបត្តិចប់ពីតំណែង បានលើកពីការជ្រើសតាំងនេះថា "បន្ទាប់ពីបំពេញការងារបានជាង ១០ឆ្នាំ នូវតួនាទីពោរពេញដោយបញ្ហាត្រូវដោះស្រាយ និងលទ្ធផលជាទីពេញចិត្តនេះ ខ្ញុំមានសេចក្តីរីករាយនឹងផ្ទេរតំណែងដឹកនាំ CDRI ជូនបណ្ឌិត ឆែម គាត រិទ្ធី ដែលមានគុណសម្បត្តិប្រវត្តិការងារ និងការប្តេជ្ញាចិត្តរឹងមាំ សក្តិសមនឹងទទួលតួនាទីនេះ ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជា។ ខ្ញុំតែងសង្ឃឹមជានិច្ចថា នឹងទទួលបានអ្នកបន្តវេនជាជនកម្ពុជាដែលមានគុណសម្បត្តិល្អវិសេស សក្តិសមនឹងមុខតំណែង ហើយខ្ញុំរីករាយណាស់ដែលក្រុមប្រឹក្សាភិបាលរបស់ CDRI បានសម្រេចធ្វើការជ្រើសតាំងនេះ។ ខ្ញុំទន្ទឹងត្រៀមធ្វើការងាររួមជាមួយលោកនាយកថ្មី, ក្រុមប្រឹក្សាភិបាលនៃ CDRI និងសហសេវិកទាំងឡាយក្នុងឋានៈជាទីប្រឹក្សាជាន់ខ្ពស់នៅក្នុងវិទ្យាស្ថាន CDRI ដើម្បីជួយសម្រួលឲ្យការផ្លាស់ប្តូរថ្នាក់ដឹកនាំរបស់វិទ្យាស្ថាន អាចអនុវត្តបានយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាព។

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា
ឯកសារបោះពុម្ពផ្សាយរបស់
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*
ឆ្នាំទី១៨ លេខ២ ខែមិថុនា ឆ្នាំ២០១៤

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ Fax (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួល: ខេង សេង
សហគ្រាសបោះពុម្ព សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៤ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ វិទ្យាស្ថាន CDRI ទេ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh